# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

## ភាគ ៣៩

## មហាវារវគ្គ ឯកាទសមភាគ

ពុទ្ធសករាជ ២៥៦៦

អធិប្បាយ

ឈាន អានាបាន សោតាបត្តិ សច្ចសំយុត្ត

ព្រះអដ្ឋកថាកែសេចក្តី ៧០ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

# សារត្ថប្បកាសិនី

## ភាគ ៣៩

## មហាវារវគ្គ ឯកាទសមភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

ឈាន អានាបាន សោតាបត្តិ សច្ចសំយុត្ត

ព្រះអដ្ឋកថាកែសេចក្តី ៧០ សូត្រ

# មហាវារវគ្គ

## ឯកានសមភាគ មាន ៤ សំយុត្ត

១-ឈានសំយុត្ត មិនមានអដ្ឋកថាកែសេចក្តីទេ

២-អានាបានស្សតិសំយុត្ត

មាន ២ វគ្គ

អដ្ឋកថាកែ ៨ សូត្រ

៣-សោតាបត្តិសំយុត្ត

មាន ៧ វគ្គ

អដ្ឋកថាកែ ៣៣ សូត្រ

៤-សច្ចសំយុត្ត

មាន ១០ វគ្គ

អដ្ឋកថាកែ ២៩ សូត្រ

រួមក្នុងឯកានសមភាគនេះ មាន

៤សំយុត្ត ព្រះអដ្ឋកថាចានកែសេចក្តីដែល

លំបាកសរុបមានចំនួន ៧០ សូត្រ

# ស្រៈនិងស្រ័យ

# *Signes et accents:*



# ស្រះពេញតួ
# Voyelles.

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឡូប Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | ไอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

# *Consonnes.*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡាតាំង Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡាតាំង<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

វិតក្កាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្វាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ **ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដកពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

*សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖*

*១ ភិក្ខុទុកដាក់អំបិលក្នុងក្អាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។*

*២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។*

*៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។*

*៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។*

*៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។*

*៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណា ប្រព្រឹត្តតាម គួរ ។*

*៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។*

*៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។*

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់ វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរស របស់ ព្រះចៅសុសុនាគៈធ្វើជាសម្ងាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយ គ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែល ជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហា សង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះ ម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ- វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងវាងនិកាយពហុលិយៈ នោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យ ទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍- សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់ហួតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានសាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះសាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុឋៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យនាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទិអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីបាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នូវ ប៊ូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តវក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ផុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះធម៌ ទំព័រ

## ឈានសំយុត្តទី ១

មិនមានអដ្ឋកថា ជួយកែសេចក្ដីទេ ។

## អានាបានសំយុត្តទី ២

### ឯកធម្មវគ្គទី ១

| | | |
|---|---|---|
| អដ្ឋកថា ឯកធម្មសូត្រ | ទី ១ | ២ |
| អដ្ឋកថា អរិដ្ឋសូត្រ | ទី ៦ | ៣ |
| អដ្ឋកថា កប្បិនសូត្រ | ទី ៧ | ៥ |
| អដ្ឋកថា ទីបសូត្រ | ទី ៨ | ៦ |
| អដ្ឋកថា វេសាលីសូត្រ | ទី ៩ | ៩ |
| អដ្ឋកថា កិមិលសូត្រ | ទី ១០ | ២៤ |

### ទុតិយវគ្គទី ២

| | | |
|---|---|---|
| អដ្ឋកថា ឥច្ឆានង្គលសូត្រ | ទី ១ | ៣២ |
| អដ្ឋកថា បឋមអានន្ទសូត្រ | ទី ៣ | ៣៤ |

## សោតាបត្តិសំយុត្តទី ២

### វេឡុទ្វារវគ្គទី ១

| | | |
|---|---|---|
| អដ្ឋកថា រាជសូត្រ | ទី ១ | ៣៨ |
| អដ្ឋកថា ឱគធសូត្រ | ទី ២ | ៤៣ |

អដ្ឋកថា ទីឃាវុសូត្រ ទី ៣ ៤៥
អដ្ឋកថា ទុតិយសារីបុត្តសូត្រ ទី ៥ ៤៦
អដ្ឋកថា ថបតិសូត្រ ទី ៦ ៤៨
អដ្ឋកថា វេឡុទ្វាសេូត្រ ទី ៧ ៥៦
អដ្ឋកថា បឋមគិញ្ជ...សូត្រ ទី ៨ ៥៧
អដ្ឋកថា តតិយគិញ្ជ..សូត្រ ទី ១០ ៦២

## រាជការាមវគ្គទី ២

អដ្ឋកថា សហាស្សសូត្រ ទី ១ ៦៤
អដ្ឋកថា ព្រាហ្មណសូត្រ ទី ២ ៧១
អដ្ឋកថា បឋមទុគ្គតិសូត្រ ទី ៤ ៧២
អដ្ឋកថា ទុតិយទុគ្គតិសូត្រ ទី ៥ ៧៣
អដ្ឋកថា បឋមមិត្តាមច្ចសូត្រ ទី ៦ ៧៤
អដ្ឋកថា ទុតិយមិត្តមច្ចសូត្រ ទី ៧ ៧៥

## សរកានិវគ្គទី ៣

អដ្ឋកថា បឋមមហានាមសូត្រទី ១ ៧៧
អដ្ឋកថា គោធាសូត្រ ទី ៣ ៧៩
អដ្ឋកថា បឋមសរកានិសូត្រ ទី ៤ ៨១
អដ្ឋកថា ទុតិយសរកានិសូត្រទី ៥ ៨៣
អដ្ឋកថា បឋមទុស្សីលយសូត្រទី ៦ ៨៤
អដ្ឋកថា ទុតិយសីលយសូត្រ ទី ៧ ៨៥

## បុញ្ញាភិសន្ទវគ្គទី ៤

អដ្ឋកថា បឋមអភិសន្ទសូត្រ ទី ១ ៨៦

អដ្ឋកថា ទេវបទសូត្រ ទី ៤ ៨៧
អដ្ឋកថា វិសូរសូត្រ ទី ៨ ៨៨
អដ្ឋកថា ឆន្ទិយសូត្រ ទី ១០ ៨៩

**សគាថកបុញ្ញាភិសន្ទវគ្គទី ៥**
អដ្ឋកថា បឋមអភិសន្ទសូត្រ ទី ១ ៩០
អដ្ឋកថា ទុតិយអភិសន្ទសូត្រទី ២ ៩១
អដ្ឋកថា តតិយអភិសន្ទសូត្រទី ៣ ៩២
អដ្ឋកថា បឋមមហាទ្ធនសូត្រ ទី ៤ ៩៣

**សប្បបញ្ញវគ្គទី ៦**
អដ្ឋកថា វិសូរវុត្តសូត្រ ទី ២ ៩៤
អដ្ឋកថា ធម្មទិន្នសូត្រ ទី ៣ ៩៥
អដ្ឋកថា គិលាយនសូត្រ ទី ៤ ៩៧
អដ្ឋកថា បដិលាភសូត្រ ទី ៩ ៩៩

**មហាបញ្ញវគ្គទី ៧**
អដ្ឋកថា មហាបញ្ញវគ្គ ១០០

## សច្ចសំយុត្តទី ៤

**សមាធិវគ្គទី ១**

អដ្ឋកថា សមាធិសូត្រ ទី ១ ១០១
អដ្ឋកថា បដិសល្លានសូត្រ ទី ២ ១០៣
អដ្ឋកថា បឋមកុលបុត្តសូត្រទី ៣ ១០៤
អដ្ឋកថា បឋមសមណា..សូត្រ ទី ៥ ១០៥

អដ្ឋកថា ទុតិយសមណ..សូត្រទី ៦ ១០៦
អដ្ឋកថា តិរច្ឆានកថាសូត្រ ទី ១០ ១០៧

## ធម្មចក្កប្បវត្តនវគ្គទី ២

អដ្ឋកថា បឋមតថាគតសូត្រទី ១ ១១៣
អដ្ឋកថា សង្កាសនសូត្រ ទី ៩ ១២០
អដ្ឋកថា តថសូត្រ ទី ១០ ១២១

## កោដិគាមវគ្គទី ៣

អដ្ឋកថា វជ្ជីសូត្រ ទី ១ ១២២
អដ្ឋកថា ទុតិយវជ្ជីសូត្រ ទី ២ ១២៣
អដ្ឋកថា តថសូត្រ ទី ៧ ១២៤
អដ្ឋកថា លោកសូត្រ ទី ៨ ១២៥
អដ្ឋកថា គវម្បតិសូត្រ ទី ១០ ១២៦

## សីសបាបណ្ណវគ្គទី ៤

អដ្ឋកថា សីសបាសូត្រ ទី ១ ១២៧
អដ្ឋកថា ខទិរសូត្រ ទី ២ ១២៨
អដ្ឋកថា ទណ្ឌសូត្រ ទី ៣ ១២៩
អដ្ឋកថា សត្តិសតសូត្រ ទី ៥ ១៣០
អដ្ឋកថា ឥន្ទខីលសូត្រ ទី ៩ ១៣១
អដ្ឋកថា វាទីសូត្រ ទី ១០ ១៣២

## បបាតវគ្គទី ៥

អដ្ឋកថា ចិន្តសូត្រ ទី ១ ១៣៣
អដ្ឋកថា បបាតសូត្រ ទី ២ ១៣៥
អដ្ឋកថា បរិឡាហសូត្រ ទី ៣ ១៣៦

| | | |
|---|---|---|
| អដ្ឋកថា កូដសូត្រ | ទី ៤ | ១៣៧ |
| អដ្ឋកថា វាលសូត្រ | ទី ៥ | ១៣៨ |
| អដ្ឋកថា បឋមជិគ្គច្ឆសូត្រ | ទី ៧ | ១៤០ |
| អដ្ឋកថា ទុតិយជិគ្គច្ឆសូត្រ | ទី ៨ | ១៤១ |

**អភិសមយវគ្គទី ៦**

អដ្ឋកថា អភិសមយវគ្គ ១៤៤

**អាមកធញ្ញបេយ្យាលទី ៧-១០**

អដ្ឋកថា អាមកធញ្ញបេយ្យាល ១៤៥

**និគមកថា** ១៥៧

# ព្រះសុត្តន្តបិដក
# សំយុត្តនិកាយ មហាវារវគ្គ
# ឈ្មោះ
# សារត្ថប្បកាសិនី
# ឯកាទសមភាគ
# ភាគ ៣៩

## ឈានសំយុត្តទី ១

## អ ដ្ឋ ក ថា

## ឈានសំយុត្ត

*ក្នុងអដ្ឋកថាឈានសំយុត្តនេះ មានសេចក្ដីវិនិច្ឆ័យទាំងនោះឯង ។*

# អានាបានស្សតិសំយុត្តទី ២

## ឯកធម្មវគ្គទី ១

## អ ដ្ឋ ក ថា

### ឯកធម្មសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឯកធម្មសូត្រទី ១ ។*

[១] *ធម៌ឯក (ឯកធម្ម) ឈ្មោះថា ធម៌ឯក ។ ពាក្យណាដ៏សេស ដែលនឹងគប្បីពោលក្នុងទីនេះ ពាក្យទាំងអស់នោះ បានពោលទុកស្រេច ហើយក្នុងនិទ្ទេសដែលពោលអំពីអានាបានស្សតិកម្មដ្ឋាន ក្នុងវិសុទ្ធិមគ្គ ។*

ចប់អដ្ឋកថា ឯកធម្មសូត្រទី ១

# អ ដ្ឋ ក ថា

## អរិដ្ឋសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអរិដ្ឋសូត្រទី ៦ ។

[១៨] ពាក្យថា *ភាវេថ នោ* គឺ *ភាវេថ នុ* (ប្រែថា ពួកលោករមែងចម្រើនឬ) ។

[២០] ពាក្យថា **កាមឆន្ទ** (**កាមឆន្ទោ**) បានដល់ សេចក្តីស្រឡាញ់ដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។ ពាក្យថា **ក្នុងធម៌ទាំងឡាយ ដែលជាចំណែកខាងក្នុង និងខាងក្រៅ** (**អជ្ឈត្តពហិទ្ធា ច មេ ធម្មេសុ** បានដល់ ក្នុងធម៌ គឺ អាយតនៈ ១២ ទាំងខាងក្នុង និងខាងក្រៅ ។ ពាក្យថា **បដិឃសញ្ញា... ដែលខ្ញុំព្រះអង្គកម្ចាត់ចេញហើយ** (**បដិឃសញ្ញា សុប្បដិវិនីតា**) បានដល់ សេចក្តីសម្គាល់ដែលប្រកបដោយដឹងក្នុងការប៉ះខ្ទប់ បានត្រូវនាំចេញទៅចំពោះដោយល្អ មានន័យថា ត្រូវកាត់ផ្តាច់ហើយ ។ ដោយបទនេះ លោកសម្តែងដល់អនាគាមិមគ្គរបស់ខ្លួន ។

ឥឡូវនេះ កាលនឹងសម្តែងដល់វិបស្សនានៃអរហត្តមគ្គ លោកទើបពោលពាក្យជាដើមថា ខ្ញុំព្រះអង្គ មានសតិដកដង្ហើមចេញ (សោ សតោវ

*អស្សាសិស្សាមិ)* ដូច្នេះ ។

ចប់អដ្ឋកថា អរិដ្ឋសូត្រទី ៦

# អ ដ្ឋ ក ថា

## កប្បិនសូត្រទី ៧

[២២] *គប្បីជ្រាបវិនិច្ឆ័យក្នុង កប្បិនទី ៧ ។*

[២៣] *លោកសម្តែងដល់សេចក្តីញាប់ញ័រនុំះឯង ដោយបទសូម្បីទាំងពីរថា សេចក្តីញាប់ញ័រ ឬសេចក្តីអន្ទះអន្ទែង (ឥញ្ជិតត្តំ វា ផន្ទិតត្តំ វា) ។*

ចប់អដ្ឋកថា កប្បិនសូត្រទី ៧

# អ ដ្ឋ ក ថា

## ទីបសូត្រទី ៨

[២៨] គប្បីជ្រាបវិនិច្ឆ័យក្នុង ទីបសូត្រទី ៨ ។

[៣០] បទថា **កាយមិនលំបាក ចក្ខុមិនលំបាក (នេវ មេ កាយោបិ កិលមតិ ន ចក្ខូនិ)** សេចក្ដីថា ដោយទូទៅ កាលកំពុងធ្វើការងារក្នុងកម្មដ្ឋានដទៃ កាយរមែងនឿយហត់ខ្លះ ចក្ខុក៏រមែងលំបាកខ្លះ ។ ពិតណាស់ កាលកំពុងធ្វើការងារក្នុងធាតុកម្មដ្ឋាន កាយរមែងលំបាក ដូចដល់អាការចាប់ដាក់ក្នុងគ្រឿងយន្ត ហើយកិន ។ កាលកំពុងធ្វើការងារក្នុងកសិណកម្មដ្ឋាន ចក្ខុក៏សម្ពឹង រមែងនឿយហត់ ដូចដល់អាការធ្លាក់ចុះទៅ ។ តែកាលធ្វើការងារក្នុងកម្មដ្ឋាននេះ កាយក៏មិននឿយហត់ឡើយ ចក្ខុទាំងពីរខាង ក៏មិនលំបាកផង ដូច្នោះ លោកទើបពោលយ៉ាងនោះ ។

សួរថា ហេតុដូចម្ដេច លោកទើបពោលពាក្យជាដើមថា **រូបសញ្ញាដោយប្រការទាំងពួង (សព្វសោ រូបសញ្ញានំ)** យើងនឹងបើកកសិណក្នុងអានាបានៈ (ខ្យល់ដកដង្ហើមចេញចូល) បានឬ ។

ឆ្លើយថា បាន ។ សម្រាប់ព្រះចូឡាភយត្ថេរអ្នកជំនាញព្រះត្រៃបិដក

ពោលថា ព្រោះហេតុដែលនិមិត្តរបស់អានាបានៈ រមែងប្រាកដដូចជាផ្កាយ ឬកែវមុក្តា ដូច្នោះ ក្នុងអានាបានៈនោះ យើងទើបបើកកសិណាចេញបាន ។ ព្រះចូឡនាគត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលជំទាស់ថា មិនបានឡើយ ។ កុំឡើយ លោកម្ចាស់ ហេតុដូចម្ដេច យើងទើបនឹងកាន់យកប្រភេទដែលមានឫទ្ធិរបស់ព្រះអរិយៈជាដើមនេះបានហ្ន៎ ។ ដើម្បីបង្ហាញដល់អានិសង្ស គឺថា ភិក្ខុអ្នកត្រូវការឫទ្ធិដែលជាអរិយៈក្តី រូបាវចរឈាន ៤ ក្តី អរូបសមាបត្តិ ៤ ក្តី និរោធសមាបត្តិក្តី ត្រូវធ្វើសេចក្តីពេញចិត្តក្នុងសមាធិ ដែលជាប់ទាក់ទងនឹងការរឭកអានាបានៈនេះឲ្យល្អ ។ ដូច (ទាហាន) កាលបានក្រុងហើយ វត្ថុណាដែលត្រូវប្រើសេចក្តីឧស្សាហ៍ ទើបនឹងបានមកក្នុងទិសទាំងបួន វត្ថុនោះ ក៏រមែងចូលកាន់ក្រុងដោយទ្វារទាំងបួនទុ៎ះឯង ក៏ជាការបានទាំងជនបទផង នេះឯងជាអានិសង្សរបស់ក្រុងនោះឯង យ៉ាងណា ប្រភេទមានអរិយឫទ្ធិជាដើមនេះ ក៏ដូច្នោះ ជាអានិសង្សរបស់អានាបានស្សតិសមាធិភាវនា កាលបានចម្រើនអានាបានស្សតិសមាធិដោយអាការទាំងអស់ហើយ វត្ថុទាំងអស់នេះ ក៏រមែងសម្រេចដល់ព្រះយោគី ដូច្នោះ លោកទើបបានពោលទុក ដើម្បីបង្ហាញដល់អានិសង្ស ។

[៤៧] ដូចម្ដេចក្នុងពាក្យថា *សុខញ្ចេ* នេះ (បើលោកសោយសុខ-

*វេទនា) លោកទើបពោលថា លោក (សោ) ព្រោះក្នុងវារៈនេះ ពាក្យថា ភិក្ខុ មិនបានមក ។*

ចប់អដ្ឋកថា ទីបសូត្រទី ៨

# អ ដ្ឋ ក ថា

## វេសាលីសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង **វេសាលីសូត្រទី ៩** ។*

*[៤៩] ពាក្យថា ជិតក្រុងសាវត្ថី (វេសាលិយំ) គឺ ជិតក្រុងដែលមានវោហារ (ឈ្មោះហៅ) ដែលប្រព្រឹត្តទៅដោយអំណាចឥត្ថីលិង្គ ដែលមានឈ្មោះយ៉ាងនោះ ។ ពិតហើយ ក្រុងនោះហៅថា វេសាលី ព្រោះជានគរដែលធំទូលាយ ដោយការពង្រីកកំពែងលោមព័ទ្ធជុំវិញដល់ ៣ ដង ។ និងកាលព្រះសម្មាសម្ពុទ្ធទ្រង់បានសម្រេចភាពជាព្រះសព្វញ្ញុតញ្ញុំ្ញះឯង ក្រុងនេះក៏គប្បីជ្រាបថា បានដល់ភាពបរិបូណ៌ដោយអាការទាំងពួង ។ កាលព្រះអានន្ទបានសម្តែងគោចរគ្រាមយ៉ាងនេះស្រេចហើយ ក៏បានពោលដល់ស្ថានទីប្រថាប់ថា **ក្នុងកូដាគារសាលា នាព្រៃមហាវ័ន** ។ ក្នុងពាក្យទាំងនោះ ព្រៃដ៏ធំមានដែនកំណត់ មិនមាននរណាដាំទុក កើតឡើងឯង ឈ្មោះ មហាវ័ន (ព្រៃធំ) ។ ចំណែកព្រៃធំ ដែលនៅជិតក្រុងកបិលកវត្ថុ ជាព្រៃដែលមានដែនកំណត់ ជាប់ជាជួរជាមួយគ្នានឹងព្រៃហិមពាន្ត ទៅដរាបជាប់មហាសមុទ្រ ។ ព្រៃធំនេះ មិនដូច្នោះទេ ជាព្រៃធំដែលនៅមានព្រំដែន ដូច្នោះទើបហៅថា*

**មហាវ័ន** ។ ចំណែកសាលាផ្ទះកំពូល គឺ សាលាដែលបានសាងជាផ្ទះមានកំពូលទុកខាងក្នុងសួនដែលអាស្រ័យព្រៃធំ សាងទុកដោយជំបូលមូលដូចហង្ស ។ សម្បូរណ៍ដោយអាការគ្រប់យ៉ាង គប្បីជ្រាបថា ជាព្រះគន្ធកុដិរបស់ព្រះដ៏មានព្រះភាគ ។

ពាក្យថា **ត្រាស់អសុភកថាដោយអនេកបរិយាយ (អនេកបរិយាយេន អសុភកថំ កថេតិ)** គឺ ទ្រង់សម្ដែងពាក្យដែលធ្វើឲ្យអស់សេចក្ដីពេញចិត្តក្នុងកាយ ប្រព្រឹត្តទៅដើម្បីបង្ហាញឲ្យឃើញច្បាស់ដល់អាការដែលមិនស្អាតដោយហេតុជាច្រើន ដូចជា មានក្នុងរាងកាយនេះ គឺ សក់ រោម ក្រចក ធ្មេញ ។ល។ ទឹកមូត្រ ដូច្នេះ ។ ពាក្យនេះ ទ្រង់អធិប្បាយទុកយ៉ាងណា? ។ (ទ្រង់អធិប្បាយទុកថា) ភិក្ខុទាំងឡាយ ក្នុងសាកសពមានប្រមាណមួយព្យាមនេះ នរណាៗ កាលពិចារណាដោយសព្វគ្រប់ហើយ រមែងមិនឃើញរបស់ស្អាតអ្វីៗ សូម្បីតែបន្តិចបន្តួច ដូចជាមុក្តា មណី ពិទូរ្យ ក្រឹស្នា ចន្ទន៍ ចន្ទន៍ក្រហម កាបូរ ឬកម្ទេចផង់គ្រឿងអប់ជាដើមឡើយ ។ ដែលពិត នឹងឃើញតែរបស់ដែលស្មោកគ្រោក មានប្រការផ្សេងៗ ដូចជា សក់ រោម ក្រចកជាដើម ដ៏សែនស្អុយ សម្ញឹងមើលគួរខ្ពើម និងគ្មានសិរិ ដូច្នោះ កុំគប្បីធ្វើសេចក្ដីពេញចិត្ត ឬសេចក្ដីស្រឡាញ់ក្នុងរាងកាយនេះឡើយ ។ ឈ្មោះ

ថា សក់ទាំងឡាយដែលកើតលើសីសៈ ដែលជាចំណែកខ្ពស់បំផុត ហើយ ក៏នៅមិនស្អាត ជារបស់ស្មោកគ្រោក និងគួរខ្ពើមរអើមទុំះឯង ។ មួយទៀត ភាពមិនស្អាត ស្អុយ គួរខ្ពើមរអើមរបស់សក់ទាំងឡាយនោះ គប្បីជ្រាប ដោយអាការ ៥ យ៉ាង គឺ ដោយពណ៌ ដោយសណ្ឋាន ដោយ ក្លិន ដោយ ទីអាស្រ័យ និងដោយឱកាស ។ សូម្បីរោមជាដើម ក៏ដូច្នោះ ។ នេះជា សេចក្ដីសង្ខេបក្នុងសូត្រនេះ ចំណែកសេចក្ដីពិស្ដារ គប្បីជ្រាបតាមន័យដែល ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងអសុភកថា ដោយអនេកបរិយាយ ចែកមួយចំណែកៗ ៥ យ៉ាង ។

ពាក្យថា **អសុភាយ វណ្ណំ ភាសតិ** (ត្រាស់សរសើរគុណនៃអសុភៈ) គឺ កាលទ្រង់សម្ដែងមាតិកានៃអសុភៈដោយអំណាចសាកសព ដែលឡើង ហើមប៉ោងជាដើមហើយ ក៏ទ្រង់ចែកសាកសពនោះដោយបទភាជនីយ៍ ត្រាស់ ដល់គុណរបស់អសុភៈ ។

ពាក្យថា **អសុភភាវនាយ វណ្ណំ ភាសតិ** (ត្រាស់សរសើរគុណនៃ ការចម្រើនអសុភៈ) គឺ ការអប់រំ ការចម្រើនចិត្ត ដែលកាន់យកអាការ ដែលមិនស្អាតក្នុងសក់ជាដើម ឬក្នុងវត្ថុទាំងខាងក្នុង និងខាងក្រៅ មាន សាកសពដែលហើមប៉ោងជាដើម ហើយប្រព្រឹត្តទៅ ។ ការអប់រំ និងការ

ចម្រើនចិត្តនោះ ជាអានិសង្សរបស់ភិក្ខុនោះ ។ កាលទ្រង់សម្តែងដល់អានិសង្សនៃការចម្រើនអសុភៈនោះ ទើបត្រាស់ដល់គុណ គឺ បញ្ជាក់ដល់គុណ គឺ ត្រាស់ថា ភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបយ៉ាងក្រៃលែងក្នុងការចម្រើនអសុភៈ ក្នុងសាក់ជាដើម ឬក្នុងវត្ថុ មានសាកសពដែលហើមប៉ោងជាដើម រមែងបានចំពោះនូវបឋមជ្ឈានដែលមានអង្គ ៥ ប្រកបដោយអង្គ ៥ មានសេចក្តីស្អាត ៣ យ៉ាង សម្បូរណ៍ដោយលក្ខណៈ ១០ យ៉ាង ដែលអាស្រ័យហិប គឺ ចិត្ត ពោលគឺ បឋមជ្ឈាននោះ ចម្រើនវិបស្សនាហើយ រមែងសម្រេចអរហត្ត ដែលជាប្រយោជន៍ដ៏ខ្ពស់បំផុត ។

ពាក្យថា **ឥច្ឆាមហំ ភិក្ខវេ អឌ្ឍមាសំ បដិសល្លិតុំ** (ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាពួនសម្ងំនៅតែម្នាក់ឯងអស់កន្លះខែ) សេចក្តីថា ភិក្ខុទាំងឡាយ តថាគតត្រូវការសម្រាក គឺ ពួនសម្ងំ បានដល់ នៅត្រឹមតែម្នាក់ឯងរហូតអស់កន្លះខែ ។ ពាក្យថា **នម្ហិ កេនសិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេនាតិ** (កុំឲ្យនរណាមួយចូលមករកតថាគតឡើយ វៀរលែងតែភិក្ខុដែលនាំចង្ហាន់បិណ្ឌបាតមួយរូប) សេចក្តីថា ភិក្ខុណា មិនធ្វើពាក្យនិយាយដែលមិនគួរដល់ខ្លួន នាំបិណ្ឌបាតដែលគេចាត់ទុកក្នុងត្រកូលដែលមានសទ្ធា មកដើម្បីប្រយោជន៍ដល់តថាគត ហើយបង្អោនចូលទៅថ្វាយ

លើកលែងតែភិក្ខុមួយរូបដែលនាំយកបិណ្ឌបាតមកថ្វាយហើយ បុគ្គលដទៃណា មិនថា ជាភិក្ខុ ឬគ្រហស្ថ មិនគប្បីចូលទៅរកតថាគត ។

ហេតុដូចម្តេច ទើបត្រាស់យ៉ាងនោះហ្ន៎? ។

បានឮមកថា ក្នុងអតីតកាល មានពួកព្រានម្រឹគ ៥០០ នាក់ យកកំណាត់ឈើ និងអន្ទាក់ជាដើម ខ្នាតធំៗ មកឡោមព័ទ្ធព្រៃ ម្នាក់ៗ ពេញចិត្តពេញថ្លើម ចិញ្ចឹមជីវិតដោយធ្វើការសម្លាប់ម្រឹគ និងបក្សី រហូតអស់ជីវិត (ស្លាប់ហើយ) ក៏កើតក្នុងនរក ។ ពួកគេឆេះក្នុងនរកនោះហើយ ដោយកុសលកម្មឯណាមួយដែលធ្វើទុកកាលមុនន៉ុះឯង ក៏មកកើតក្នុងពួកមនុស្សដោយអំណាចឧបនិស្ស័យល្អ គ្រប់គ្នាក៏បានបព្វជ្ជា និងឧបសម្បទាក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ ព្រោះអកុសលកម្មពីដើមនោះ របស់លោកទាំងនោះ អបរាបរចេតនាដែលឲ្យផលនៅមិនទាន់ឲ្យផល ក៏បានឱកាសចូលទៅកាត់ជីវិត ដោយសេចក្តីព្យាយាមរបស់ខ្លួនឯង និងដោយសេចក្តីព្យាយាមរបស់អ្នកដទៃ ខាងក្នុងកន្លះខែនោះ ព្រះដ៏មានព្រះភាគទ្រង់បានជ្រាបហេតុការណ៍នោះ ។ មួយយ៉ាងទៀត ដែលឈ្មោះថា វិបាករបស់កម្ម មិនមាននរណានឹងអាចការពារបាន ក៏ក្នុងភិក្ខុទាំងនោះ បុថុជ្ជនក៏មាន ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះខីណាស្រពក៏មាន ។ ក្នុងលោកទាំងនោះ ភិក្ខុជា

ព្រះទីណាស្រេព មិនមានការបន្តភពជាតិ អរិយសាវកក្រៅពីនេះ មានគតិដ៏ពិតប្រាកដជាទីទៅក្នុងភពខាងមុខ[១] ។ គតិពួកបុថុជ្ជន មិនពិតប្រាកដ ។ តើដូចម្តេច?

ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះ ព្រោះសេចក្តីពេញចិត្តក្នុងអត្តភាព ខ្លាចមរណភ័យហើយ នឹងមិនសិក្សាដើម្បីជម្រះគតិ ណ្ហើយចុះ តថាគតនឹងសម្តែងអសុភកថា ដើម្បីឲ្យភិក្ខុ ទាំងនោះលះបង់សេចក្តីពេញចិត្ត ពួកគេ កាលបានស្តាប់អសុភកថានោះហើយ ព្រោះការប្រាសចាកសេចក្តីពេញចិត្តក្នុងអត្តភាពហើយ នឹងធ្វើការជម្រះគតិ ហើយនឹងកាន់យកបដិសន្ធិក្នុងសួគ៌ បើដូច្នេះ ការបួសក្នុងសំណាក់របស់ពួកគេ ក៏នឹងមានប្រយោជន៍ ព្រោះហេតុនោះ ដើម្បីអនុគ្រោះពួកគេ ទើបទ្រង់សម្តែងអសុភកថា ដោយទ្រង់ប្រាថ្នាកម្មដ្ឋានជាសំខាន់ មិនមែនទ្រង់ប្រាថ្នានឹងពណ៌នាគុណនៃសេចក្តីស្លាប់ ។ លុះទ្រង់សម្តែងហើយ ព្រះអង្គក៏ទ្រង់ព្រះតម្រិះយ៉ាងនេះថា ប្រសិនបើកន្លះខែនេះ ពួកភិក្ខុឃើញតថាគត ក៏នឹងនាំគ្នាប្រាប់ថា ថ្ងៃនេះមានភិក្ខុ ១ រូប មរណភាពហើយ ថ្ងៃនេះ ២ រូប ។ល។ ថ្ងៃនេះ ១០ រូប មរណភាពហើយ ក៏ផលរបស់កម្មនេះ ទោះជាតថាគត ឬបុគ្គលដទៃក៏ដោយ មិនអាចនឹងហាមបាន តថាគតសូម្បីបានដឹងកម្មវិបាកនោះ ក៏

នឹងធ្វើអ្វីបាន ។ ប្រយោជន៍អ្វីដល់តថាគត ដោយការស្តាប់រឿងបាត់បង់ រឿងវិនាស ណ្ហើយចុះ តថាគតនឹងចៀសចេញមិនឲ្យភិក្ខុទាំងឡាយឃើញ ព្រោះដូច្នោះ ទើបបានត្រាស់យ៉ាងនោះថា "ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាពួនសម្ងំនៅតែម្នាក់ឯងអស់កន្លះខែ នរណាៗ មិនគប្បីចូលមករកតថាគត វៀរលែងតែភិក្ខុដែលនាំបិណ្ឌបាតទៅថ្វាយមួយរូប" ។

តែអាចារ្យពួកដទៃ ពោលថា ពួនសម្ងំ (សម្រាក) យ៉ាងនោះ ក៏ដើម្បីវៀរចាកការតិះដៀលរបស់អ្នកដទៃ ។ គេថា បុគ្គលពួកដទៃនឹងនាំគ្នាតិះដៀលព្រះដ៏មានព្រះភាគថា "បុគ្គលនេះប្តេជ្ញាថា យើងជាសព្វញ្ញូ ជាអ្នកញុំាងព្រះធម្មចក្កដ៏ប្រសើរ គឺ ព្រះសទ្ធម្មឲ្យប្រព្រឹត្តទៅ មិនអាចសូម្បីតែហាមប្រាមពួកសាវករបស់ខ្លួនដែលកំពុងសម្លាប់ខ្លួនឯងបាន នឹងអាចហាមប្រាមអ្នកដទៃបានឬ" ។ ក្នុងចំណោមនោះ ដែលជាបណ្ឌិតនឹងពោលថា "ព្រះដ៏មានព្រះភាគស្តេចត្រូវការពួនសម្ងំ (សម្រាក) ទ្រង់រមែងមិនជ្រាបការប្រព្រឹត្តទៅនេះ សូម្បីនរណាៗ ដែលជាអ្នកក្រាបទូលឲ្យទ្រង់ជ្រាប ក៏មិនមាន ប្រសិនបើទ្រង់ជ្រាប ទ្រង់នឹងគប្បីហាមប្រាមពិត" ប៉ុន្តែ នេះគ្រាន់តែជាសេចក្តីត្រូវការប៉ុណ្ណោះ ជាហេតុការណ៍គ្រាដំបូងប៉ុណ្ណោះ ក្នុងរឿងនេះ ។ ពាក្យថា **អស្សុជា** ក្នុងបទថា **នាស្សុជា** នេះ ជាពាក្យចុះជ្រៀតចូល

មកក្នុងអត្ថ ត្រឹមតែធ្វើឲ្យពេញបទ ឬក្នុងអត្ថហាមសេចក្តីយ៉ាងដទៃ សេចក្តីក៏គឺ មិនមាននរណាៗ ចូលទៅគាល់ព្រះដ៏មានព្រះភាគឡើយ ។

[៩០] ដែលឈ្មោះថា **អនេកាការវោការេ** (ដោយអាការខ្វាត់ខ្វាយជាអនេក) ក៏ព្រោះការខ្វល់ខ្វាយតាមប្រកបការចម្រើនអសុភៈនោះ ដោយហេតុពត់រាយជាអនេក មានពណ៌ និងសណ្ឋានជាដើម ។ មានពាក្យអធិប្បាយថា លាយឡំទៅដោយអាការជាអនេក គឺ លាយឡំទៅដោយហេតុជាអនេក ។ នោះគឺអ្វី គឺ ការខ្វល់ខ្វាយប្រកបការចម្រើនអសុភៈ ។ ពាក្យថា **អសុភភាវនានុយោគមនុយុត្តា វិហរន្តិ** (ខ្វល់ខ្វាយប្រកបការចម្រើនអសុភៈដែលពត់រាយ ដោយអាការជាអនេកនោះឯង) គឺ ជាអ្នកប្រកបហើយប្រកបទៀត ។ ពាក្យថា **អដ្ដិយមានា** (នឿយណាយ) សេចក្តីថា ជាទុក្ខព្រោះកាយនោះ ។ ពាក្យថា **ហរាយមានា** (ធុញទ្រាន់) បានដល់ សេចក្តីខ្មាស ។ ពាក្យថា **ជិគុច្ឆមានា** (ខ្ពើមរអើម) បានដល់ ញុំាងសេចក្តីខ្ពើមឲ្យកើតឡើង ។

ពាក្យថា **សត្ថហារំ បរិយេសន្តិ** (ស្វែងរកគ្រឿងសស្ត្រាសម្រាប់ផ្តាច់ជីវិត) បានដល់ ស្វែងរកគ្រឿងសស្ត្រានាំយកជីវិតទៅ ភិក្ខុទាំងនោះមិនមែនតែស្វែងរកសស្ត្រាមកតែម្យ៉ាងប៉ុណ្ណោះ តែផ្តាច់ជីវិតខ្លួនផង ក៏ពួក

ភិក្ខុបានចូលទៅរក សូម្បីនាយមិគលណ្ឌិកអ្នកតែងខ្លួនស្រដៀងសមណៈ ហើយនិយាយថា "លោកម្ចាស់ ល្អហើយ សូមលោកជួយផ្តាច់ជីវិតពួកអាត្មាផងចុះ" ។ ក៏ក្នុងទីនេះ ពួកអរិយៈមិនបានធ្វើបាណាតិបាតឡើយ មិនបានបបួល មិនបានយល់ញល្អ យល់ញស្អាតទៅជាមួយផង ។ តែបុថុជ្ជនបានធ្វើគ្រប់យ៉ាង ។

[៥១] ពាក្យថា ***បដិសល្លានា វុដ្ឋិតោ*** (ស្តេចចេញចាកការពួនសម្ងំ) គឺ កាលទ្រង់បានជ្រាបពួកភិក្ខុទាំង ៥០០ រូបនោះ ដល់ការអស់ជីវិតហើយ ទ្រង់ក៏ចេញចាកទីពួនសម្ងំតែមួយអង្គឯងនោះ សូម្បីទ្រង់ជ្រាប ក៏ដូចទ្រង់មិនជ្រាប ដើម្បីឲ្យពាក្យតាំងឡើងព្រម ទើបត្រាស់ហៅព្រះអានន្ទមក ។ បទថា ***កឹ នុ ខោ អានន្ទ តនុភូតោ វិយ ភិក្ខុសង្ឃោ*** (ម្នាលអានន្ទ ព្រោះហេតុដូចម្តេចហ្ន៎ បានជាពួកភិក្ខុសង្ឃហាក់ដូចជាស្តួចស្តើងទៅ) សេចក្តីថា អានន្ទ មុននេះ ពួកភិក្ខុដ៏ច្រើននាំគ្នាមកកាន់ទីទំនុកបម្រុងជាមួយគ្នា កាន់យកឧទ្ទេស និងបរិបុច្ឆា អារាមប្រាកដដូចជារុងរឿង តែឥឡូវនេះ ដោយកន្លងទៅនៃវេលាគ្រាន់តែកន្លះខែ ភិក្ខុសង្ឃដូចជាមានចំនួនតិច គឺ ដូចជាស្តួចស្តើង តិចទៅ រលោះទៅ ហេតុអ្វីហ្ន៎ ឬថា ពួកភិក្ខុដទៃនាំគ្នាចៀសចេញទៅកាន់ទិសទាំងឡាយ ។

ពេលនោះ ព្រះអានន្ទ កាលមិនទាន់ជ្រាបដល់ការអស់ជីវិតរបស់ភិក្ខុទាំងនោះ ព្រោះផលកម្ម តែយល់ថា ព្រោះការតាមប្រកបក្នុងអសុភកម្មដ្ឋានជាបច្ច័យ ទើបក្រាបទូលពាក្យថា **បពិត្រព្រះអង្គដ៏ចម្រើន ពិតដូច្នោះឯង ព្រះមានព្រះភាគ** ជាដើម កាលនឹងទូលសូមកម្មដ្ឋានយ៉ាងដទៃ ដើម្បីឲ្យភិក្ខុទាំងឡាយបានសម្រេចជាព្រះអរហន្ត ទើបក្រាបទូលពាក្យជាដើមថា **សូមព្រះដ៏មានព្រះភាគប្រទានព្រះវរោកាស** សេចក្តីរបស់ពាក្យក្រាបទូលសូមនោះ (គប្បីជ្រាបដូចតទៅនេះ) បពិត្រព្រះអង្គដ៏ចម្រើន ដូចខ្ញុំព្រះអង្គសូមព្រះវរោកាស សូមព្រះដ៏មានព្រះភាគ មេត្តាត្រាស់ប្រាប់ការណ៍យ៉ាងដទៃ ដែលជាហេតុឲ្យភិក្ខុសង្ឃគប្បីតាំងនៅក្នុងព្រះអរហត្តចុះ មានអធិប្បាយថា កម្មដ្ឋានដែលឈានចុះកាន់ព្រះនិព្វានបាននៅមានច្រើន បានដល់ ប្រភេទអនុស្សតិ ១០ កសិណ ១០ ចតុធាតុវវត្ថាន: ព្រហ្មវិហារ និងអានាបានស្សតិ សូម្បីពួកដទៃ ដូចជាទរទឹកសម្រាប់ហូរចុះកាន់មហាសមុទ្រ ។ ក្នុងបណ្តាកម្មដ្ឋានទាំងនោះ សូមព្រះដ៏មានព្រះភាគ ទ្រង់ល្មងលោមពួកភិក្ខុនិងទ្រង់មេត្តាត្រាស់ប្រាប់កម្មដ្ឋានប្រការណាមួយចុះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបំណងនឹងធ្វើយ៉ាងនោះ កាលនឹងទ្រង់បញ្ជូនព្រះថេរៈទៅ ទើបត្រាស់ពាក្យជាដើមថា (ម្នាលអានន្ទ

បើដូច្នោះ) ។

[៥២] ក្នុងពាក្យទាំងនោះ ពាក្យថា **វេសាលឹ ឧបនិស្សាយ** (អាស្រ័យក្រុងវេសាលី) សេចក្តីថា ពួកភិក្ខុមានប្រមាណប៉ុនណាដែលចូលទៅអាស្រ័យក្រុងវេសាលី នៅចម្ងាយមួយគាវុតខ្លះ កន្លះយោជន៍ខ្លះ ដោយជុំវិញ អ្នកចូរឲ្យពួកភិក្ខុទាំងអស់នោះប្រជុំគ្នា ។ ពាក្យថា **សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេត្វា** (ឲ្យភិក្ខុទាំងអស់នោះ ប្រជុំគ្នាក្នុងឧបដ្ឋានសាលា) សេចក្តីថា កន្លែងដែលល្មមនឹងទៅដោយខ្លួនឯងក៏ទៅឯង បញ្ជូនភិក្ខុកម្លោះៗ ទៅក្នុងទីដទៃ គ្រាតែមួយប៉ុណ្ណោះ ក៏ធ្វើពួកភិក្ខុឲ្យមកមិនមានសល់ ឲ្យប្រជុំគ្នាត្រង់ឧបដ្ឋានសាលា ។ តទៅនេះ ជាពាក្យអធិប្បាយក្នុងពាក្យថា **បពិត្រព្រះ-អង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ចូរជ្រាបកាលដែលសមគួរក្នុងកាលឥឡូវនេះចុះ** នេះ ។ បពិត្រព្រះដ៏មានព្រះភាគ ភិក្ខុសង្ឃប្រជុំគ្នាហើយ នេះជាវេលានៃទេសនា ដើម្បីទ្រង់ធ្វើធម្មកថា ឥឡូវនេះ សូមព្រះអង្គទ្រង់ជ្រាបវេលាដើម្បីវត្តណា ទ្រង់គប្បីធ្វើវត្តនោះចុះ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ សមាធិដែលសម្បយុត្តដោយអានាបានស្សតិ** នេះឯង លុះត្រាស់ហៅមកហើយ កាលនឹងទ្រង់ប្រាប់បរិយាយដទៃក្រៅពី

អសុភកម្មដ្ឋានដែលបានទ្រង់ប្រាប់មកហើយក្នុងកាលមុន ដើម្បីការសម្រេចព្រះអរហត្តរបស់ពួកភិក្ខុ ទើបទ្រង់ត្រាស់ពាក្យជាដើមថា **អានាបានស្សតិ-សមាធិ** ។

ក្នុងពាក្យទាំងនោះ ពាក្យថា **អានាបានស្សតិសមាធិ** បានដល់ ការតម្កល់ចិត្តមាំដែលប្រកបព្រមជាមួយសេចក្តីរឭក ដែលកំណត់កាន់យកខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល ឬសេចក្តីតាំងចិត្តមាំក្នុងការរឭកដល់ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល ជាសមាធិដែលមានការរឭកដល់ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលជាអារម្មណ៍ ។

បទថា **ចម្រើនហើយ (ភាវិតោ)** បានដល់ ដែលឲ្យកើតឡើងហើយ ឬដែលឲ្យចម្រើនហើយ ។

បទថា **ធ្វើឲ្យច្រើនហើយ (ពហុលីកតោ)** បានដល់ ដែលធ្វើរឿយៗ ។

បទថា **សន្តោ ចេវ បណីតោ ច** ប្រែថា ស្ងប់ និងប្រណីតនោះឯង ។ គប្បីជ្រាបសេចក្តីពិតប្រាកដដោយ **ឯវ** សព្ទទាំង ២ កន្លែង ។ លោកអធិប្បាយទុកយ៉ាងណា អធិប្បាយថា ក៏អសុភកម្មដ្ឋាន ស្ងប់ និងប្រណីតដោយអំណាចការចាក់ធ្លុះតែម្យ៉ាង តែព្រោះមានអារម្មណ៍គ្រោតគ្រាត និងព្រោះជាអារម្មណ៍ក្នុងខណៈកើតឡើង ដោយអំណាចនៃអារម្មណ៍ ទើបមិនស្ងប់

មិនប្រណីត យ៉ាងណា **អានាបានស្សតិសមាធិ** នេះ មិនដូច្នោះទេ បរិយាយខ្លះអាចមិនស្ងប់ ឬមិនប្រណីតក៏បាន ប៉ុន្តែថា ឈ្មោះថា **ស្ងប់រំងាប់** រលត់ហើយ ព្រោះអារម្មណ៍ស្ងប់ខ្លះ ឈ្មោះថា **ប្រណីត** ធ្វើឲ្យមិនឆ្អែត ព្រោះអង្គស្ងប់ ពោលគឺ សេចក្ដីចាក់ដូះខ្លះ ព្រោះអារម្មណ៍ប្រណីតខ្លះ ព្រោះធម៌ប្រណីតខ្លះ ។ ហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ថា **សន្តោចេវ បណីតោ ច (ស្ងប់ និងប្រណីតនោះឯង)** ដូច្នេះ ។

ក៏ក្នុងពាក្យថា **រីករាយចិត្ត ធម៌ជាគ្រឿងនៅជាសុខ) អសេចនកោ ច សុខោ ច វិហារោ)** នេះ ឈ្មោះថា **រីករាយ** ព្រោះអានាបានស្សតិសមាធិនោះមិនគ្រោតគ្រាត មិនប្រឡូកប្រឡំ មិនផ្សេងគ្នា បានតែចំពោះខ្លួន មានន័យថា ក្នុងអានាបានស្សតិសមាធិនេះ បរិកម្ម ឬសេចក្ដីស្ងប់ដោយឧបចារៈដោយសេចក្ដីស្ងប់ មិនមានអានាបានស្សតិសមាធិនោះ ស្ងប់ និងប្រណីតតាមធម្មជាតិរបស់ខ្លួនឯង ផ្ដើមអំពីការរួបរួមចិត្តក្នុងខាងដើមមកតែម្ដង ។ អាចារ្យខ្លះពោលថា ពាក្យថា **រីករាយ** គឺ មិនត្រូវដាក់ឱជៈចូលទៅ ក៏មានសេចក្ដីឆ្ងាញ់បាន ផ្អែមតាមធម្មជាតិដោយពិត ។ គប្បីជ្រាបថា អានាបានស្សតិសមាធិនេះ ឈ្មោះថា **រីករាយ** និងឈ្មោះថា ធម៌ជាគ្រឿងនៅជាសុខព្រោះប្រព្រឹត្តទៅដើម្បីបានទទួលសេចក្ដីសុខ ទាំងផ្លូវកាយ និងផ្លូវចិត្ត ក្នុង

ខណៈដែលចិត្តតម្កល់មាំហើយ ដោយប្រការដូច្នេះ ។

ពាក្យថា **ឧប្បន្នុប្បន្នេ** (ដែលកើតឡើងហើយៗ) មានសេចក្តីថា ដែលនៅមិនទាន់បានគ្របសង្កត់ហើយ ។

ពាក្យថា **បាបកេ** គឺ លាមក ។

ពាក្យថា **អកុសលធម៌** (**អកុសលេ ធម្មេ**) គឺ ធម៌ដែលកើតឡើងព្រមដោយសេចក្តីមិនឆ្លាត ។

ពាក្យថា **ឲ្យអន្តរធាន ស្ងប់ទៅដោយឆាប់រហ័ស** (**ឋានសោ អន្តរធាបេតិ**) គឺ ឲ្យវិនាសទៅ បានដល់ គ្របសង្កត់បានភ្លាមក្នុងខណៈនោះនោះឯង ។

ពាក្យថា **ស្ងប់ទៅ** (**វូបសមេតិ**) បានដល់ ស្ងប់បានដោយល្អ មានពាក្យដែលលោកអធិប្បាយទុកថា អានាបានស្សតិសមាធិដែលដល់សេចក្តីចម្រើននៃអរិយមគ្គហើយ ឈ្មោះថា រមែងកាត់ផ្តាច់ គឺ ស្ងប់រម្ងាប់បានដោយលំដាប់ ព្រោះប្រព្រឹត្តទៅក្នុងចំណែកនៃការបាក់ធ្លុះ[១] ។

ពាក្យថា **ក្នុងចុងខែនៃរដូវក្តៅ** (**គិម្ហានំ បច្ឆិមេ មាសេ**) គឺ ក្នុងខែអាសាឍ្ហ: ។

---

១-ភូមា : ព្រោះអារម្មណ៍ជារបស់បដិកូល ។

ពាក្យថា **កំទេចធូលីដែលហុយឡើង (ឧហតំ រជោល្លំ)** គឺ ក្នុងកន្លះខែ កំទេចធូលី និងលម្អងធូលី លើផែនដីដែលស្ងួត ព្រោះខ្យល់ និងកំដៅថ្ងៃ បែកក្រហែង ព្រោះជើងគោ និងក្របីជាដើមជាន់ ក៏ហុយទៅខាងលើតាំងឡើងព្រមក្នុងអាកាស ។

ពាក្យថា **ភ្លៀងធំមិនមែនកាល (មហាអកាលមេឃោ)** (ភ្លៀងធំបង្អុរចុះមិនត្រូវកាល) បានដល់ ភ្លៀងដែលតាំងឡើង គ្របដណ្តប់ទូទៅទាំងផ្ទៃអាកាស ហើយក៏ធ្លាក់ចុះមកអស់កន្លះខែក្នុងខាងខ្នើតខែអាសាឍ្ហ: ។ ក៏ភ្លៀងនោះ លោកបំណងយកក្នុងទីនេះថា ភ្លៀងមិនមែនកាលកើតឡើង ព្រោះកាលមិនទាន់ដល់វេលាភ្លៀង ។

ពាក្យថា **ឲ្យអន្តរធានស្ងប់ទៅដោយឆាប់រហ័ស (ឋានសោ អន្តរធាបេតិ វូបសមេ)** គឺ នាំទៅកាន់ការមិនឃើញ បានដល់ ឲ្យជ្រៀតលិចទៅក្នុងផែនដីដោយពេលភ្លាមៗ នោះឯង ។ ពាក្យថា **ដូច្នោះដូចគ្នា (ឯវមេវ ខោ)** នេះជាពាក្យសម្តែងប្រការប្រៀបធៀប ។ ពាក្យតពីនោះទៅ ក៏មានន័យដូចពោលហើយនោះឯង ។

ចប់អដ្ឋកថា វេសាលីសូត្រទី ៩

# អ ដ្ឋ ក ថា

## កិមិលសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង កិមិលសូត្រទី ១០ ។*

[៥៦] *ពាក្យថា* ***ជិតក្រុងកិមិលា*** *(កិមិលាយំ) គឺ ក្នុងនគរមានឈ្មោះយ៉ាងនោះ ។ ពាក្យថា* ***បានក្រាបទូល*** *(ឯតទវោច) សេចក្តីថា បានឮថា ព្រះថេរៈគិតថា ទេសនានេះ មិនបានធ្វើតាមអនុសន្ធិ យើងនឹងឲ្យតាមអនុសន្ធិ (យថានុសន្ធិ) កាលនឹងបន្តអនុសន្ធិនៃទេសនា ទើបបានពោលពាក្យនេះ ។*

[៥៩] *ពាក្យថា* ***កាយណាមួយក្នុងបណ្តាកាយទាំងឡាយ*** *(កាយញ្ញតរំ) គឺ យើងពោលកាយណាមួយក្នុងកាយទាំងឡាយ មានកាយ គឺ ដីជាដើម មានន័យថា យើងពោលដល់កាយ គឺ ខ្យល់ ។ ម្យ៉ាងទៀត ចំណែកនៃរូប ២៥ ប្រភេទ គឺ ចក្ខាយតនៈ (អាយតនៈគឺភ្នែក) ។ល។ កវឡីង្កាភាហារ ឈ្មោះថា* ***រូបកាយ*** *។ ក្នុងចំណែកនៃរូបទាំងនោះ ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល រមែងជាកាយម្យ៉ាង ព្រោះរួមចូលក្នុងផោដ្ឋព្វាយតនៈ (អាយតនៈ គឺ ផោដ្ឋព្វៈ) ។ សូម្បីព្រោះហេតុនោះ ព្រះថេរៈទើបបាន*

ពោលយ៉ាងនោះ ។

ពាក្យថា ព្រោះហេតុនោះឯង (តស្មា តិហ) សេចក្ដីថា ព្រោះរមែងពិចារណាឃើញកាយ គឺ ខ្យល់ ដែលជាកាយម្យ៉ាងក្នុងកាយទាំង ៤ ឬរមែងពិចារណាឃើញខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល ដែលជាកាយម្យ៉ាងក្នុងរូបកាយ ក្នុងចំណែកនៃរូប ២៥ ដូច្នោះ ទើបឈ្មោះថា ជាអ្នកពិចារណាឃើញកាយក្នុងកាយ ។ គប្បីជ្រាបសេចក្ដីទាំងពួងយ៉ាងនេះ ។

[៦០] ពាក្យថា **វេទនាណាមួយក្នុងបណ្ដាវេទនាទាំងឡាយ (វេទនាញ្ញតរំ)** គឺ វេទនាណាមួយក្នុងវេទនាទាំង ៣ យ៉ាង ពាក្យនេះលោកពោលសំដៅយកសុខវេទនា ។

ពាក្យថា **ការធ្វើទុកក្នុងចិត្តឲ្យល្អ (សាធុកំ មនសិការំ)** គឺ ការយកចិត្តដាក់យ៉ាងល្អ ដែលកើតឡើងហើយដោយអំណាចបីតិជាដើម ។ សួរថា ក៏ការមនសិការជាសុខវេទនាឬ ។

ឆ្លើយថា មិនដូច្នោះទេ នេះជាមាតិកាទេសនា ដូចជា **សញ្ញា** លោកហៅដោយឈ្មោះថា **សញ្ញា** ក្នុងពាក្យនេះថា ជាអ្នកតាមប្រកបការអប់រំ **អនិច្ចសញ្ញា** (ការសម្គាល់ថាមិនទៀង) យ៉ាងណា សូម្បីក្នុងទីនេះ ក៏ដូច្នោះ គប្បីជ្រាបថា លោកហៅវេទនាក្នុងឈាន ដោយឈ្មោះថា ការធ្វើទុកក្នុង

ចិត្ត (មនសិការ) ។ ពិតណាស់ ក្នុងពួក ៤ នេះ លោកហៅវេទនា ដោយមាតិកានៃបីតិក្នុងបទដំបូង ។ ក្នុងបទទី ២ ហៅដោយសរុបថា **សុខ** ប៉ុណ្ណោះ ។ ក្នុងចិត្តសង្ខារ ២ បទ ព្រោះព្រះបាលីថា ធម៌ទាំងនេះ គឺ សញ្ញា និងវេទនានេះ ជាចេតសិក ជាប់ទាក់ទងជាមួយចិត្ត ជាគ្រឿងតាក់តែងចិត្ត លោកទើបពោលវេទនា ដោយឈ្មោះថា ចិត្តសង្ខារ (គ្រឿងតាក់តែងចិត្ត) ព្រោះព្រះបាលីថា វៀរលែងតែវិតក្កៈ និងវិចារៈហើយ ធម៌ដែលប្រកបជាមួយចិត្តសូម្បីទាំងអស់ រួមចូលក្នុងចិត្តសង្ខារ ។ ព្រះថេរៈរួមធម៌ទាំងអស់នោះដោយឈ្មោះថា **មនសិការ** (គឺការធ្វើទុកក្នុងចិត្ត) ហើយពោលថា ការធ្វើទុកក្នុងចិត្តឲ្យល្អ ក្នុងទីនេះ ។

ក៏កាលដូច្នោះ មានអ្នកជំទាស់ថា ព្រោះហេតុដែលវេទនានេះជាអារម្មណ៍មិនបាន ដូច្នោះ ការពិចារណាឃើញវេទនាក៏មិនគួរ ព្រោះសូម្បីក្នុងមហាសតិប្បដ្ឋានសូត្រជាដើម បុគ្គលធ្វើវត្ថុមានសុខជាដើមនោះៗ ឲ្យជាអារម្មណ៍ហើយ រមែងសោយវេទនា តែវត្ថុមានសុខជាដើមនោះ ព្រោះអាស្រ័យការប្រព្រឹត្តទៅនៃវេទនា ទើបមានត្រឹមតែវោហារថា **យើងសោយ** លោកសំដៅយកវត្ថុមានសុខជាដើមនោះ ទើបពោលថា កាលសោយសុខ-វេទនា (ក៏ដឹងច្បាស់ថា) យើងសោយសុខវេទនា ដូច្នេះជាដើម ។ មួយ៉ាង

ទៀត លោកបានពោលពាក្យឆ្លើយរបស់បញ្ហានេះ ទុកក្នុងការពណ៌នាសេចក្តីរបស់ពាក្យថា **ជាអ្នកកំណត់ដឹងបីតិ (បីតិប្បដិសំវេទី)** ជាដើម ទុកដូចគ្នា ។ សមពិតដូចពាក្យដែលលោកពោលទុកក្នុងវិសុទ្ធិមគ្គថា ៖

**បីតិ** រមែងដឹងច្បាស់ដោយអាការ ២ យ៉ាង គឺ ដោយអារម្មណ៍ ១ ដោយសេចក្តីមិនវង្វេង ១ ។

**បីតិ** រមែងដឹងច្បាស់ដោយអារម្មណ៍ តើដូចម្តេច? ភិក្ខុ រមែងចូលឈានដែលមានបីតិ ២ ឈាន ក្នុងខណៈចូលឈាននោះ **បីតិ** របស់អ្នកបានឈាន រមែងជាការដឹងច្បាស់ហើយដោយអារម្មណ៍ ព្រោះសេចក្តីនៃអារម្មណ៍ដែលខ្លួនបានដឹងច្បាស់ហើយ ។

**បីតិ** រមែងជាការដឹងច្បាស់ហើយ ដោយសេចក្តីមិនវង្វេង តើដូចម្តេច? ភិក្ខុចូលឈានដែលមានបីតិ ២ ឈាន ចេញចាកឈានហើយ រមែងពិចារណាបីតិដែលប្រកបជាមួយឈាន ដោយការអស់ទៅ ដោយការសូន្យទៅ ក្នុងខណៈការឃើញជាក់ច្បាស់របស់ភិក្ខុនោះ **បីតិ** រមែងជាការដឹងច្បាស់ហើយ ព្រោះសេចក្តីមិនវង្វេង ដោយការចាក់ធ្លុះលក្ខណៈ ។ សមដូចដែលព្រះសារីបុត្របានពោលទុកក្នុងបដិសម្ភិទាមគ្គថា កាលភិក្ខុដឹងច្បាស់ថា ចិត្តមានអារម្មណ៍តែមួយ គឺ សេចក្តីមិនរាយមាយនៃចិត្ត ដោយអំណាច

ការដកដង្ហើមចេញវែង **សតិ** រមែងចូលទៅតាំងទុកហើយ បីតិនោះ រមែងជាការដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ បណ្ឌិតគប្បីជ្រាបសេចក្តី សូម្បីបទដ៏សេសដោយទំនងនេះឯង ។

ធម៌ជាគ្រឿងតាក់តែងចិត្ត គឺ **បីតិ និងសុខ** ដោយអារម្មណ៍ របស់អ្នកបានសម្រេចឈានបានដឹងច្បាស់ហើយ ដូចដែលពោលមកនេះប្រការណាមុំះឯង **វេទនា** ដោយអារម្មណ៍ ក៏រមែងបានដឹងច្បាស់ហើយ ដោយការបានចំពោះនូវមនសិការ ពោលគឺ វេទនាដែលប្រកបជាមួយឈានសូម្បីនេះដូច្នោះ ។ ព្រោះហេតុនោះ ពាក្យថា **ភិក្ខុ** គឺ ជាអ្នកតាមឃើញវេទនាក្នុងវេទនាទាំងឡាយ នៅក្នុងសម័យនោះ ទើបជាពាក្យដែលពោលទុកល្អហើយនោះឯង ។

[៦១] ក្នុងពាក្យថា **អានន្ទ ព្រោះតថាគមិនពោល...ចំពោះអ្នកមិនមានសតិ មិនមានសម្បជញ្ញៈ (នាហំ អានន្ទ មុដ្ឋស្សតិស្ស អសម្បជានស្ស)** នេះ មានអធិប្បាយដូចតទៅនេះ ។ ព្រោះហេតុដែលភិក្ខុប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា **យើងនឹងកំណត់ដឹងចិត្ត** ដកដង្ហើមចូល រមែងយក (និមិត្តនៃ) ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញ មកជាអារម្មណ៍ សូម្បីដោយពិត ដល់យ៉ាងនោះ កាល (ភិក្ខុ) ចូលទៅតាំងសតិ និង

សម្បជញ្ញៈក្នុងអារម្មណ៍របស់ចិត្តនោះហើយ រមែងឈ្មោះថា ភិក្ខុនេះជាអ្នកពិចារណាឃើញចិត្តក្នុងចិត្ត ព្រោះការប្រព្រឹត្តទៅដោយពិត ។

អានាបានស្សតិភាវនា (ការចម្រើនសតិក្នុងការដកដង្ហើមចូល និងដកដង្ហើមចេញ) របស់អ្នកប្រាសចាកសតិ អ្នកប្រាសចាកបញ្ញា រមែងមានមិនបានឡើយ ដូច្នោះ ដោយអារម្មណ៍ហើយ ក្នុងសម័យនោះ ភិក្ខុជាអ្នកពិចារណាឃើញចិត្តក្នុងចិត្ត ដោយអំណាចដឹងច្បាស់ចិត្ត ដូច្នេះ ។

[៦២] **អភិជ្ឈា** ទ្រង់សម្តែងទុកក្នុងបទថា **ភិក្ខុឃើញការលះអភិជ្ឈា និងទោមនស្សដោយបញ្ញា ទើបព្រងើយបានយ៉ាងល្អ (សោ យន្តំ ហោតិ អភិជ្ឈាទោមនស្សានំ បហានំ តម្បញ្ញាយ ទិស្វា សាធុកំ អជ្ឈុបេក្ខិតា ហោតិ)** នេះ បានដល់ កាមច្ឆន្ទៈនោះឯង ។ ទ្រង់សម្តែងព្យាបាទនិវរណៈដោយអំណាចទោមនស្ស ។ ក៏ពួក ៤ នេះ ត្រាស់ដោយអំណាចវិបស្សនាប៉ុណ្ណោះ ។ ចំណែកធម្មានុបស្សនាមាន ៥ យ៉ាង ដោយអំណាចនីវរណ-បព្វៈជាដើម , នីវរណបព្វៈ ជាប្រការដើមរបស់ធម្មានុបស្សនានោះ សូម្បីរបស់នីវរណបព្វៈនោះ មានពួក ២ នៃនីវរណៈនេះជាខាងដើម ។ ដើម្បីនឹងទ្រង់សម្តែងដល់ពាក្យខាងដើមនៃធម្មានុបស្សនា ដូចដែលពោលមកនេះ ទើបត្រាស់ថា **អភិជ្ឈា និងទោមនស្ស**ដូច្នេះ ។

ពាក្យថា **ការលះ (បហានំ)** សំដៅយក ញាណដែលលះបង់ យ៉ាងនេះថា ភិក្ខុរមែងលះបង់សេចក្តីសម្គាល់ថាទៀង ដោយការតាមពិចារណាឃើញសេចក្តីមិនទៀង ។

ពាក្យថា **ឃើញការលះនោះ ដោយបញ្ញា (តំ បញ្ញាយ ទិស្វា)** គឺ ញាណជាគ្រឿងលះបង់ បានដល់ អនិច្ចញ្ញាណ វិរាគញ្ញាណ និរោធញ្ញាណ និងបដិនិស្សគ្គញ្ញាណនោះ រមែងមានដោយវិបស្សនាបញ្ញា ។ មយ៉ាងទៀត ទ្រង់សម្តែងដល់សេចក្តីបន្តជាប់ៗ គ្នានៃវិបស្សនានោះ យ៉ាងនេះថា យ៉ាងដទៃទៀត ។

ពាក្យថា **ទើបព្រងើយបាន (អជ្ឈុបេក្ខិតា ហោតិ)** គឺ ឈ្មោះថារមែងព្រងើយដ៏ក្រៃលែងពីរយ៉ាង គឺ រមែងព្រងើយដ៏ក្រៃលែងចំពោះអ្នកប្រព្រឹត្តទៅក្នុងសេចក្តីស្ងប់ ១ , រមែងព្រងើយដ៏ក្រៃលែងចំពោះការទំនុកបម្រុងព្រមគ្នា ១ ។ ក្នុងករណីនោះ ការព្រងើយដ៏ក្រៃលែង រមែងមានសូម្បីចំពោះធម៌ដែលកើតរួមគ្នាខ្លះ ការព្រងើយដ៏ក្រៃលែង រមែងមានដល់អារម្មណ៍ខ្លះ ។ ក្នុងទីនេះបំណងយកការព្រងើយដ៏ក្រៃលែង ដល់អារម្មណ៍ ។

ពាក្យថា **ព្រោះហេតុនោះឯង អានន្ទ (តស្មា តិហានន្ទ)** គឺ ព្រោះហេតុដែលអានាបានស្សតិសមាធិប្រព្រឹត្តទៅហើយ ដោយទំនងជាដើមថា ឃើញនឹងតាមពិចារណាឃើញការមិនទៀង ដកដង្ហើមចូល ដូច្នេះ មិនមែនប្រព្រឹត្តទៅតែក្នុងធម៌ មាននីវរណៈជាដើមប៉ុណ្ណោះ តែភិក្ខុបានឃើញញាណ

ដែលជាគ្រឿងលះបង់ធម៌ ដែលបានពោលទុកហើយក្នុងប្រការ គឺ អភិជ្ឈា និងទោមនស្ស ដោយបញ្ញាហើយ រមែងជាអ្នកព្រងើយដ៏ក្រៃលែង ដូច្នោះ គប្បីជ្រាបថា ភិក្ខុជាអ្នកតាមពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះឯង ។

[៦៣] ក្នុងពាក្យថា ដូច្នោះដូចគ្នា (ឯវមេវ ខោ) នេះ គប្បីឃើញអាយតនៈទាំង ៦ យ៉ាង ដូចផ្លូវធំបែកជា ៤ ។ កិលេសក្នុងអាយតនៈទាំង ៦ យ៉ាង ដូចគំនរធូលី ។ សតិប្បដ្ឋាន ៤ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៤ ដូចរទេះ និងរថ ដែលកំពុងមកពីទិសទាំង ៤ ។ គប្បីជ្រាប ការចូលទៅសម្លាប់ធម៌ដែលជាបាបអកុសល ដោយកាយានុបស្សនាជាដើម ដូចការកម្ចាត់គំនរធូលី ដោយរទេះ ឬរថនោះ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា កិមិលសូត្រទី ១០

## ចប់ឯកធម្មវគ្គទី ១

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

| | |
|---|---|
| ១ អដ្ឋកថា ឯកធម្មសូត្រ | ២ អដ្ឋកថា អរិដ្ឋសូត្រ |
| ៣ អដ្ឋកថា កប្បិនសូត្រ | ៤ អដ្ឋកថា ទីបសូត្រ |
| ៥ អដ្ឋកថា វេសាលីសូត្រ | ៦ អដ្ឋកថា កិមិលសូត្រ |

# ទុតិយវគ្គទី ២

## អ ដ្ឋ ក ថា

### ឥច្ឆានង្គលសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥច្ឆានង្គលសូត្រទី ១ ។*

*[៦៥] សួរថា ហេតុដូចម្តេច ព្រះដ៏មានព្រះភាគ ទើបត្រាស់ប្រាប់វិហារសមាបត្តិ (ការចូលដល់ធម៌ជាគ្រឿងនៅ) របស់ព្រះអង្គថា ពួកអ្នកគប្បីប្រាប់យ៉ាងនេះ (ឯវំ ព្យាករេយ្យាថ) ។*

*ឆ្លើយថា ដើម្បីចៀសពីការតិះដៀល ។ ពិតណាស់ ប្រសិនបើពួកភិក្ខុទាំងនោះគប្បីពោលថា "ពួកយើងមិនជ្រាប" ពេលនោះ ពួកអន្យតិរ្ថិយក៏នឹងគប្បីលើកការតិះដៀលឡើងដល់ភិក្ខុទាំងនោះថា "ពួកលោករមែងមិនជ្រាបថា សាស្តារបស់ពួកយើងនៅហើយរហូតអស់បីខែ ដោយសមាបត្តិឈ្មោះឯណោះ ក៏ហេតុដូចម្តេច ពួកលោកទើបព្រមនៅបម្រើលោកទៀតហ្ន៎" ព្រោះហេតុនោះ ទើបទ្រង់ត្រាស់យ៉ាងនោះ ដើម្បីចៀសអំពីការចោទប្រកាន់ ។*

សួរថា បើដូច្នោះ ហេតុដូចម្ដេចក្នុងទីនេះ ទើបមិនត្រាស់ ដូចដែលត្រាស់ថា វា អក្សរ ក្នុងទីដទៃថា មានសតិ រមែងដកដង្ហើមចូល ឬកាលកំពុងដកដង្ហើមចូលវែងផង ។

ឆ្លើយថា ព្រោះភាវៈជាធម៌ស្ងប់យ៉ាងក្រៃលែង ។

ពិតហើយ ខ្យល់ដកដង្ហើមចូល ឬខ្យល់ដកដង្ហើមចេញជាវត្ថុដែលប្រាកដដល់មនុស្សពួកដទៃ វត្ថុទាំងពីរយ៉ាងនេះ ជាវត្ថុដែលប្រាកដដល់ព្រះដ៏មានព្រះភាគ ។ ព្រោះទ្រង់មានព្រះសតិ ដែលទ្រង់ចូលទៅតាំងទុកជានិច្ច ហេតុនេះ ទើបមិនត្រាស់ទុក ព្រោះជាធម៌ស្ងប់យ៉ាងក្រៃលែង ។ បើដូច្នោះ ហេតុដូចម្ដេចទើបមិនត្រាស់ថា **យើងរមែងសិក្សា (សិក្ខាមិ)** តែត្រាស់ថា **យើងដកដង្ហើមចូល (អស្សសាមិ)** ប៉ុណ្ណោះ? ។ ព្រោះមិនមានវត្ថុដែលនឹងត្រូវសិក្សា ។ ពិតហើយ ព្រះសេក្ខៈ ៧ ពួក ឈ្មោះថា **សេក្ខៈ** ព្រោះនៅមានវត្ថុដែលនឹងត្រូវសិក្សា , ព្រះខីណាស្រព ឈ្មោះថា **អសេក្ខៈ** ព្រោះមិនមានវត្ថុដែលនឹងត្រូវសិក្សា ។ ព្រះតថាគតទាំងឡាយជាបុគ្គលមិនត្រូវសិក្សា ទើបឈ្មោះថា **អសេក្ខៈ** ។ កិច្ចដែលនឹងត្រូវសិក្សារបស់ព្រះអសេក្ខៈទាំងនោះមិនមាន ហេតុនេះ ទើបមិនត្រាស់ទុកថា តថាគតរមែងសិក្សា ព្រោះមិនមានកិច្ចដែលនឹងត្រូវសិក្សា ។

ចប់អដ្ឋកថា ឥច្ឆានង្គលសូត្រទី ១

# អ ដ្ឋ ក ថា

## បឋមអានន្ទសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអានន្ទសូត្រទី ៣ ។

[៩០] ពាក្យថា រមែងស្រាវជ្រាវ (បវិចិនតិ) គឺ រមែងស្រាវជ្រាវដោយអំណាចនៃការមិនទៀងជាដើម ។ ពីរបទក្រៅពីនេះ ជាពាក្យប្រើជំនួសនឹងពាក្យថា រមែងពិចារណា នេះឯង ។

[៩១] ពាក្យថា មិនអាស្រ័យអាមិស (និរាមិសា) គឺ មិនមានកិលេស បានដល់ ទាំងកាយទាំងចិត្ត រមែងស្ងប់រម្ងាប់ ដោយសេចក្ដីស្ងប់រម្ងាប់សេចក្ដីខ្វល់ខ្វាយផ្លូវកាយ និងផ្លូវចិត្ត ។

[៩២] ពាក្យថា រមែងតាំងមាំ (សមាធិយតិ) បានដល់ រមែងតាំងទុកដោយប្រពៃ គឺ ដូចជាអប្បនាចិត្ត ។

[៩៣] ពាក្យថា រមែងសម្លឹងមើល (អជ្ឈុបេក្ខិតា ហោតិ) គឺ រមែងជាអ្នកព្រងើយដ៏ក្រៃលែង ដោយសេចក្ដីព្រងើយដ៏ក្រៃលែង ចំពោះធម៌ដែលកើតរួមជាមួយ ។

សតិក្នុងកាយនោះ របស់ភិក្ខុដែលកំណត់កាយដោយវិធី ១៤ យ៉ាង

ដូចដែលពោលមកនេះ ឈ្មោះថា **សតិសម្ពោជ្ឈង្គ** ញាណដែលប្រកបនឹងសតិនោះ ឈ្មោះថា **ធម្មវិចយសម្ពោជ្ឈង្គ** សេចក្ដីព្យាយាមដែលប្រព្រឹត្តទៅក្នុងផ្លូវកាយ និងផ្លូវចិត្ត ដែលប្រកបជាមួយធម្មវិចយសម្ពោជ្ឈង្គនុ៎ះឯង **ជាវីរិយសម្ពោជ្ឈង្គ** បីតិ បស្សទ្ធិ និងចិត្តេកគ្គតា **ជាបីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ និងសមាធិសម្ពោជ្ឈង្គ** អាការដែលជាកណ្ដាលៗ គឺ មិនធូរពេក មិនតឹងពេករបស់ពោជ្ឈង្គទាំង ៦ នេះ **ជាឧបេក្ខាសម្ពោជ្ឈង្គ** ។

ដូចជា កាលពួកសេះរត់ទៅស្មើ ការចាក់ជន្ទ្រញថា មួយនេះខ្ជិល ឬយឺត ថា មួយនេះរត់លឿនពេក រមែងមិនមានដល់សារថី មានត្រឹមតែអាការតាំងនៅរបស់សេះដែលរត់ហើយយ៉ាងនោះតែម្យ៉ាង យ៉ាងណា អាការដែលជាកណ្ដាលៗ គឺ មិនធូរពេលមិនតឹងពេក របស់ពោជ្ឈង្គទាំង ៦ នេះ ក៏ឈ្មោះថា **ជាឧបេក្ខាសម្ពោជ្ឈង្គ** ដូច្នោះឯង ។ ដោយពាក្យប៉ុណ្ណេះ ព្រះដ៏មានព្រះភាគបានត្រាស់អ្វីទុក? បានត្រាស់ឈ្មោះថា **វិបស្សនាពោជ្ឈង្គព្រមទាំងលក្ខណៈ** ដែលប្រកបដោយខណៈចិត្តតែមួយទុកហើយ ។

ពាក្យជាដើមថា **អាស្រ័យវិវេក (វិវេកនិស្សិតំ)** មានអត្ថដូចពោលទុកស្រេចហើយ ។

សួរថា ក៏ក្នុងសូត្រនេះ ទ្រង់សម្ដែងសតិកំណត់ខ្យល់ដកដង្ហើមចូល

និងដកដង្ហើមចេញ ១៦ ជង ជាមិស្សកៈយ៉ាងណា? ។

ឆ្លើយថា ការតាំងសតិ (សតិប្បដ្ឋាន) ដែលមានខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញជាមូល ជាបុព្វភាគ សតិដែលរលឹកដល់ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញ ដែលជាមូល ជាបុព្វភាគនៃការតាំងសតិនោះ ។ សតិដែលញុំាងពោជ្ឈង្គឲ្យបរិបូណ៌ ក៏ជាបុព្វភាគ សូម្បីពោជ្ឈង្គទាំងនោះ ក៏ជាបុព្វភាគ តែពោជ្ឈង្គដែលញុំាងវិជ្ជា និងវិមុត្តិឲ្យបរិបូណ៌ ជាលោកុត្តរៈ ដែលឲ្យកើតឡើងហើយ វិជ្ជា និងវិមុត្តិ ជាវត្ថុដែលប្រកបជាមួយអរិយផល ។ ឬវិជ្ជា ជាវត្ថុដែលប្រកបជាមួយមគ្គ ៤ វិមុត្តិ ជាវត្ថុដែលប្រកបនឹងផល ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា បឋមអានន្ទសូត្រទី ៣

# អ ដ្ឋ ក ថា

## សូត្រទី ៤ ៥ ៦

*សូត្រទី ៤ ៥ ៦ មានសេចក្ដីកំណត់ស្មើនឹងសូត្រទី ៣ នេះឯង ។ ពាក្យដ៏សេសគ្រប់កន្លែង មានសេចក្ដីងាយទាំងអស់នោះឯង ។*

**ចប់ទុតិយវគ្គទី ២**

**រួមអដ្ឋកថាក្នុងវគ្គនេះ គឺ**

១អដ្ឋកថា ឥច្ឆានង្គលសូត្រ ២អដ្ឋកថា បឋមអានន្ទសូត្រ

## ចប់អានាបានស្សតិសំយុត្ត ២

# សោតាបត្តិសំយុត្តទី ៣

## វេឡុទ្វារវគ្គទី ១

## អ ដ្ឋ ក ថា

### រាជសុត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង រាជសូត្រទី ១ ។*

*[១១២] ពាក្យថា **កិញ្ចាបិ** ជានិបាតចុះក្នុងអត្ថថា អនុគ្រោះ និង តិះដៀល ។*

*ពិតហើយ ព្រះសាស្តាកាលនឹងទ្រង់អនុគ្រោះ (កាលកាន់យក) រាជ-សម្បត្តិ គឺ ភាពជាឥស្សរាធិបតីនៃមហាទ្វីបទាំង ៤ និងកាលទ្រង់តិះដៀល គឺ ការលះបង់អបាយទាំង ៤ មិនទាន់បាន ទើបទ្រង់ត្រាស់ពាក្យជាដើមថា "ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ...សូម្បីក៏ពិត" (**កិញ្ចាបិ ភិក្ខវេ រាជា បក្កវត្តិ**) ។*

*បណ្តាបទទាំងនោះ បទថា **នៃទ្វីបទាំង ៤ (ចតុន្នំ ទីបានំ)** បានដល់*

ទ្វីបធំទាំង ៤ មានទ្វីប ១.០០០ ជាបរិវារ ។

បទថា *ភាពជាឥស្សរាធិបតី (ឥស្សរិយាធិបច្ចំ)* សេចក្តីថា ភាពជាឥស្សរៈ ភាពជាអធិបតី ឈ្មោះថា *ភាពជាធំ* ។ ភាពជាឥស្សរៈ ភាពជាធំ ឈ្មោះថា *ភាពជាឥស្សរាបតី* ព្រោះអត្ថថា មិនមានសេចក្តីផ្សេងគ្នាក្នុងរាជសម្បត្តិ ។ បទថា *សោយ (ការេត្វា)* បានដល់ ធ្វើរាជសម្បត្តិបែបនេះឲ្យប្រព្រឹត្តទៅ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យជាដើមថា "ភិក្ខុទាំងឡាយ អរិយសាវក...ក៏ពិត" *(កិញ្ចាបិ ភិក្ខវេ អរិយសាវកោ)* ។

[១១៣] សំពត់គ្មានជាយ ឈ្មោះថា *សំពត់សៅហង (នន្តកានិ)* ក្នុងបទនោះ ។ ក៏សំពត់សាដកសូម្បី ១៣ ហត្ថ តាំងពីកាត់ជាយសំពត់ចេញ ដល់ការរាប់ថា សំពត់មិនមានជាយដូចគ្នា ។

បទថា *ដោយសេចក្តីជ្រះថ្លាដែលមិនញាប់ញ័រ (អវេច្ចប្បសាទេន)* បានដល់ សេចក្តីជ្រះថ្លាដែលមិនកម្រើក ។

ពាក្យថា ក៏សេចក្តីជ្រះថ្លានោះ គឺ សេចក្តីជ្រះថ្លាមួយ មានច្រើនយ៉ាងនោះឯង ក៏សេចក្តីជ្រះថ្លាដែលមកដល់ហើយដោយមគ្គនោះ រមែងកើតឡើងមិនមុនមិនក្រោយក្នុងវត្ថុណា ដោយអំណាចវត្ថុនោះ សេចក្តីជ្រះថ្លានោះ លោកទើបពោលទុក ៣ យ៉ាង ដោយន័យជាដើមថា ដោយ

សេចក្តីជ្រះថ្លាដែលមិនញាប់ញ័រក្នុងព្រះពុទ្ធ ។ ព្រោះសេចក្តីជ្រះថ្លាតែម្យ៉ាងដូច្នោះ សេចក្តីជ្រះថ្លានោះ រមែងជាហេតុឲ្យបង្អោនទៅផ្សេងៗ គ្នា ។ ពិតហើយ អរិយសាវក រមែងមានសេចក្តីជ្រះថ្លា សេចក្តីស្រឡាញ់ និងសេចក្តីគោរពក្នុងព្រះពុទ្ធប៉ុណ្ណោះច្រើន ក្នុងព្រះធម៌ ឬក្នុងព្រះសង្ឃមិនច្រើន ឬរមែងមានសេចក្តីជ្រះថ្លាក្នុងព្រះធម៌ប៉ុណ្ណោះច្រើន ក្នុងព្រះពុទ្ធ ឬក្នុងព្រះ-សង្ឃមិនច្រើន ឬរមែងមានសេចក្តីជ្រះថ្លាក្នុងព្រះសង្ឃប៉ុណ្ណោះច្រើន ក្នុងព្រះពុទ្ធ ឬព្រះធម៌មិនច្រើន ព្រោះហេតុនោះ អរិយសាវកមានសេចក្តីជ្រះថ្លា សេចក្តីស្រឡាញ់ និងសេចក្តីគោរព (ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ) ត្រឹមតែម្យ៉ាងក៏ទេ ។

ពាក្យជាដើមថា ***សូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគព្រះអង្គនោះ (ឥតិបិ សោ ភគវា)*** ដូច្នេះ លោកឲ្យពិស្តារហើយ ក្នុងបករណ៍វិសេសឈ្មោះថា វិសុទ្ធិមគ្គនុ៎ះឯង ។

បទថា ***ដែលព្រះអរិយៈប្រាថ្នាហើយ (អរិយកន្តេហិ)*** សេចក្តីថា ដែលព្រះអរិយៈទាំងឡាយប្រាថ្នាហើយ គឺ ជាទីពេញចិត្តនោះឯង ។ ព្រោះថា ព្រះអរិយបុគ្គលទាំងឡាយ ទៅហើយរវាងចកត ក៏មិនធ្វើឲ្យសីល ៥ ឲ្យកម្រើក លោកពោលហើយយ៉ាងនេះ សំដៅយកសីល ៥ ដែលជាទី

ស្រឡាញ់ទាំងនោះ សូម្បីរបស់ព្រះអរិយបុគ្គលទាំងនោះ ។

ពាក្យថា **មិនដាច់ (អខណ្ឌេហិ)** ព្រះដ៏មានព្រះភាគត្រាស់ហើយដូចគ្នានោះឯង ។ ចំណែកមួយដែលដាច់ត្រង់ជាយ លោកហៅថា **ដាច់តាមលំដាប់** ។

បទថា **ធ្លុះត្រង់កណ្តាល** បានដល់ ចំណែកទាំងនោះ មានសាច់សំពត់ខូចខាតក្នុងផ្ទៃតែមួយ ។

បទថា **ពព្រុះ** បានដល់ ពព្រុះដោយចំណុចផ្សេងៗ ។ បទថា **ពពាល** សេចក្តីថា សីលដែលដាច់ក្នុងប្រការខាងដើម ឬទីបំផុត ទៅតាមលំដាប់យ៉ាងនេះ ឈ្មោះថា **ដាច់** , ដែលដាច់ក្នុងកណ្តាល ឈ្មោះថា **ធ្លុះ** , ឈ្មោះថា **ពព្រុះ** ព្រោះដាច់ទៅតាមលំដាប់ ២-៣ សិក្ខាបទ ក្នុងទីណាមួយ , ដែលដាច់ចន្លោះសិក្ខាបទមួយ ឈ្មោះថា **ពពាល** ។ គប្បីជ្រាបដល់សីលមិនដាច់ជាដើម ព្រោះមិនមានទោសទាំងនោះ ។ បទថា **ជាឥស្សរ (ភុជិស្សេហិ)** បានដល់ ដោយធ្វើភាពជាធំ ។ បទថា **វិញ្ញូជនសរសើរ (វិញ្ញូបសត្ថេហិ)** សេចក្តីថា ដែលវិញ្ញូជនទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ។

បទថា **ដែលតណ្ហា និងទិដ្ឋិមិនស្ទាបអង្អែល (អបរាមដ្ឋេហិ)** សេចក្តី

ថា ដែលតណ្ហា និងទិដ្ឋិមិនស្ទាបអង្អែលយ៉ាងនេះថា សេចក្តីត្រិះរិះឈ្មោះនេះ ដែលលោកធ្វើហើយ ។ បទថា **ប្រព្រឹត្តិទៅដើម្បីសមាធិ (សមាធិសំវត្តនិកេហិ)** សេចក្តីថា ដើម្បីឲ្យអប្បនាសមាធិ ឬឧបចារសមាធិប្រព្រឹត្តទៅ ។

ចប់អដ្ឋកថា រាជសូត្រទី ១

# អ ដ្ឋ ក ថា

## ឱគធសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង ក្នុងឱគធសូត្រទី ២ ។

[១១៦] ព្រះដ៏មានព្រះភាគ ទ្រង់កាន់យកសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធ ដោយបទថា **សទ្ធា...មានដល់បុគ្គលណា** (យេសំ សទ្ធា) ។ ទ្រង់កាន់យកសីលដែលព្រះអរិយៈប្រាថ្នាហើយ ដោយបទថា **សីល** (សីលំ) ។ ទ្រង់កាន់យកសេចក្ដីជ្រះថ្លាក្នុងព្រះសង្ឃ ដោយបទថា **សេចក្ដីជ្រះថ្លា** (បសាទោ) ។ ទ្រង់កាន់យកសេចក្ដីជ្រះថ្លាក្នុងធម៌ ដោយបទថា **ការឃើញធម៌** (ធម្មទស្សនំ) ព្រោះថា ទ្រង់ត្រាស់អង្គនៃការសម្រេចសោតា ៤ ដោយប្រការដូច្នេះ ។ បទថា **រមែងសម្រេចតាមកាល** (កាលេ បច្ចេន្តិ) បានដល់ សម្រេច (ផល) តាមកាល ។ បទថា **សេចក្ដីសុខដែលឈានចុះក្នុងព្រហ្មចរិយៈ** (ព្រហ្មចរិយោគធំ សុខំ) បានដល់ សុខដែលសម្បយុត្តដោយមគ្គ ៣ ខាងលើ ដែលរួមយកព្រហ្មចរិយៈហើយតាំងនៅ ។ ក៏សេចក្ដីជ្រះថ្លាដែលមកហើយក្នុងគាថា ចាត់ថា ជាសេចក្ដីជ្រះថ្លាដែលជាលោកុត្តរៈ **ព្រះតិបិដកចូឡាភយត្ថេរ** ពោលថា "សេចក្ដីជ្រះថ្លា" មុន ។ **ព្រះតិបិដកចូឡនាគត្ថេរ** ពោល

*ថា “សេចក្តីជ្រះថ្លា គឺ ការពិចារណាមគ្គដែលមកហើយ” ។ ព្រះថេរៈសូម្បីទាំងពីរ ជាបណ្ឌិត ជាពហុស្សុត សុភាសិតរបស់ព្រះថេរៈទាំងពីរថា នេះជាសេចក្តីជ្រះថ្លាដែលលាយគ្នា (មិស្សកៈ) ។*

ចប់អដ្ឋកថា ឱកធសូត្រទី ២

# អ ដ្ឋ ក ថា

## ទីឃាវុសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង ទីឃាវុសូត្រទី ៣ ។

[១២១] បទថា ព្រោះហេតុនោះ (តស្មា) សេចក្តីថា ព្រោះលោកប្រាកដក្នុងអង្គនៃធម៌ជាគ្រឿងសម្រេចសោតា ៤ ។

បទថា ដែលប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា (វិជ្ជាភាគិយេ) សេចក្តីថា ក្នុងចំណែកនៃការដឹងច្បាស់ ។

[១២២] បទថា ក្នុងសង្ខារទាំងពួង (សព្វសង្ខារេសុ) សេចក្តីថា ក្នុងសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ។

ព្រះដ៏មានព្រះភាគបានត្រាស់វិបស្សនានៃមគ្គទាំង ៣ ខាងលើដល់ទីឃាវុឧបាសកយ៉ាងនេះ ។

[១២៣] បទថា ទុក្ខ (វិឃាតំ) បានដល់ សេចក្តីលំបាក ។

ចប់អដ្ឋកថា ទីឃាវុសូត្រទី ៣

# អ ដ្ឋ ក ថា

## ទុតិយសារិបុត្តសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសារីបុត្តសូត្រទី ៥ ។*

[១២៨] *បទថា **សោតាបត្តិយង្គៈ (សោតាបត្តិយង្គំ)** សេចក្តីថា អង្គគុណ នៃការបានចំពោះដែលជាចំណែកខាងដើមនៃធម៌ជាគ្រឿងសម្រេចសោតា ។ ក៏គុណដែលបានចំពោះ មានសេចក្តីជ្រះថ្លាដែលមិនញាប់ញ័រក្នុងព្រះពុទ្ធ ឈ្មោះថា អង្គនៃសោតាបន្ន ក៏អង្គសូម្បីទាំងនោះមកហើយថា អង្គនៃធម៌ជាគ្រឿងសម្រេចសោតា ។ ក្នុងអង្គទាំងនោះ អង្គសូម្បីទាំង ២ ក៏មានអធិប្បាយពាក្យនេះថា បុគ្គល សេពសប្បុរស សេពគប់ អង្គុយជិតស្តាប់ធម៌ ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ បដិបត្តិវត្តបដិបត្តិដែលជាចំណែកខាងដើម ដែលជាធម៌សមគួរដល់ធម៌ រមែងបានចំពោះធម៌ជាគ្រឿងសម្រេចសោតា ។*

*ធម៌មានការសេពគប់សប្បុរសជាដើម ឈ្មោះថា អង្គនៃធម៌ជាគ្រឿងសម្រេចសោតា ព្រោះអត្ថថា ជាអង្គដើម្បីប្រយោជន៍នៃធម៌ជាគ្រឿងសម្រេចសោតា ។ ធម៌ក្រៅអំពីនេះ ឈ្មោះថា **សោតាបត្តិយង្គៈ** (អង្គនៃធម៌ជា*

*គ្រឿងសម្រេចសោតា) ព្រោះអត្ថថា ជាអង្គនៃធម៌ជាគ្រឿងសម្រេចសោតា ពោលគឺ* ***បឋមមគ្គ*** *។ សោតាបត្តិមគ្គ ជាអង្គនៃសោតាបត្តិមគ្គដែលចាក់ធ្លុះហើយ ព្រោះហេតុនោះ ទើបឈ្មោះថា អង្គនៃធម៌ជាគ្រឿងសម្រេចសោតា ។*

ចប់អដ្ឋកថា ទុតិយសារីបុត្តសូត្រទី ៥

# អ ដ្ឋ ក ថា

## ថបតិសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងថបតិសូត្រទី ៦ ។

[១៣៦] បទថា *អាស្រ័យនៅក្នុងស្រុកសួយឈ្មោះសាធុកៈ (សាធុកេ បដិវសន្តិ)* សេចក្តីថា នៅក្នុងស្រុកសួយរបស់ខ្លួន ដែលមានឈ្មោះ សាធុកៈ ។

បណ្តាជាងឈើទាំងនោះ ជាងឈើឈ្មោះថា **ឥសិទត្តៈ** ជាព្រះ-សកទាគាមី ជាងឈើឈ្មោះ បុរាណ ជាព្រះសោតាបន្ន ជាអ្នកសន្តោស ក្នុងកិរិយារបស់ខ្លួន ។

បទថា *បានឲ្យបុរសឈរចាំផ្លូវ (មគ្គេ បុរិសំ ឋបេសុំ)* សេចក្តីថា បានដឹងថា ផ្លូវជាទីទៅរបស់ព្រះដ៏មានព្រះភាគ ត្រង់ទ្វារស្រុករបស់ពួក ជាងឈើទាំងនោះ ព្រោះហេតុនោះ ពួកជាងឈើនោះ ទើបដាក់បុរស ទុកកណ្តាលផ្លូវ ដោយគិតថា ព្រះដ៏មានព្រះភាគ កាលពួកយើងដេកលក់ ហើយ ឬប្រមាទហើយក្នុងវេលា ឬក្រៅវេលា ស្តេចគប្បីទៅ បើដូច្នោះ ពួកយើងគប្បីបានចូលគាល់ ។

[១៣៧] បទថា *ដើរតាម (អនុពន្ធីសុ)* សេចក្តីថា តាមជាប់ទៅអំពី

ខាងក្រោយ តែមិនឆ្ងាយ ។

ព្រះដ៏មានព្រះភាគ ស្តេចយាងតាមផ្លូវដោយព្រះបាទត្រង់កណ្តាលផ្លូវទេះ ។ ពួកជាងឈើក្រៅពីនេះ បានជាប់តាមទៅទាំងពីរខាង ។

បទថា **ទ្រង់ចៀសចេញអំពីផ្លូវ (មគ្គា ឱក្កម្ម)** សេចក្តីថា ការធ្វើបដិសណ្ឋារៈចំពោះព្រះពុទ្ធទាំងឡាយ ដែលស្តេចយាងទៅជាមួយនរណាៗ (មនុស្សទូទៅ) ក៏គួរ ។ ការធ្វើបដិសណ្ឋារៈចំពោះព្រះពុទ្ធទាំងឡាយ ដែលស្តេចប្រថាប់ឈរជាមួយនឹងនរណាៗ (មនុស្សទូទៅ) ស្តេចប្រថាប់គង់រហូតអស់មួយថ្ងៃជាមួយនឹងនរណាៗ ក៏គួរ ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រិះរិះហើយថា ការធ្វើបដិសណ្ឋារៈរបស់ព្រះពុទ្ធដែលស្តេចយាងទៅជាមួយបុគ្គលពួកនេះក៏មិនគួរ ការធ្វើបដិសណ្ឋារៈរបស់ព្រះពុទ្ធ ដែលស្តេចយាងទៅជាមួយបុគ្គលដែលឈរក៏មិនគួរ ព្រោះថា ជនទាំងនេះ ជាម្ចាស់នៃសាសនារបស់តថាគត មានផលដែលដល់ហើយ (ជាព្រះសកទាគាមី) តថា-គត នឹងគង់ធ្វើបដិសណ្ឋារៈរហូតអស់មួយថ្ងៃជាមួយនឹងបុគ្គលពួកនេះ ដូច្នេះហើយ ទើបទ្រង់ចៀសចេញអំពីផ្លូវ ស្តេចចូលទៅរកគល់ឈើ ។

បទថា **ប្រថាប់គង់លើអាសនៈដែលគេក្រាលថ្វាយ (បញ្ញត្តេ អាសនេ និសីទិ)** សេចក្តីថា សួរថា ពួកជាងឈើបានឲ្យកាន់យកឆត្រ ស្បែកជើង

ឈើប្រត់ ប្រេងលាបជើង ទឹកបាន: ៨ យ៉ាង និងបល្ល័ង្កមានជើង ដូចជើងសត្វទៅហើយឬ? ។

ឆ្លើយថា ឲ្យក្រាលបល្ល័ង្កដែលគេនាំមកថ្វាយហើយ ។ ព្រះសាស្តាប្រថាប់គង់លើបល្ល័ង្កនោះ ។

បទថា **អគ្គុយក្នុងទីដែលសមគួរម្ខាង (ឯកមន្តំ និសីទឹសុ)** សេចក្តីថា ពួកជាងឈើពោលហើយថា ពួកលោកចូរថ្វាយរបស់ដ៏សេស មានឆត្រនិងស្បែកជើងជាដើម ដល់ភិក្ខុសង្ឃ ។ សូម្បីខ្លួនឯងក៏បានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអគ្គុយក្នុងទីដ៏សមគួរម្ខាង ។

ពាក្យទាំងអស់មានជាដើមថា **ព្រះមានព្រះភាគស្តេចនឹងចារិកចាកក្រុងសាវត្ថី ទៅកាន់កោសលជនបទ (សាវត្ថិយា កោសលេសុ ចារិកំ បក្កមិស្សតីតិ)** សេចក្តីថា ពួកជាងឈើ មានឥសិទត្តៈជាដើម ក្រាបទូលហើយដោយអំណាចមជ្ឈិមប្រទេសនុ៎ះឯង ។ ព្រោះហេតុអ្វី ទើបកំណត់? ព្រោះថា ការត្រាច់ចារិកទៅក្តី ការញ៉ាំងអរុណឲ្យតាំងឡើងក្តី របស់ព្រះដ៏មាន-ព្រះភាគ ពួកជាងឈើពោលហើយដោយអំណាចមជ្ឈិមប្រទេស ព្រោះពាក្យនោះកំណត់យ៉ាងពិតប្រាកដថា ព្រះដ៏មានព្រះភាគ ស្តេចរមែងចារិកទៅក្នុងមជ្ឈិមប្រទេសនោះឯង ព្រះអង្គរមែងឲ្យអរុណតាំងឡើងក្នុងមជ្ឈិមប្រទេស ។

[១៨៣] ក្នុងបទថា *ព្រះដ៏មានព្រះភាគរបស់យើងទាំងឡាយ នឹងទៅក្នុងទីជិត (អាសន្នេ នោ ភគវា ភវិស្សតីតិ)* សេចក្តីថា ពួកជាងឈើនោះមានសេចក្តីត្រេកអរ ព្រោះព្រះដ៏មានព្រះភាគនៅក្នុងទីជិត តែម្យ៉ាងក៏មិនមែន ដែលពិត ពួកគេមានសេចក្តីសប្បាយចិត្តថា ឥឡូវនេះ យើងនឹងបានថ្វាយទាន ធ្វើការបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម (និង) សួរបញ្ហា ។

[១៨៤] បទថា *ម្នាលនាយជាងឈើទាំងឡាយ ព្រោះហេតុនោះ ការនៅគ្រប់គ្រងផ្ទះ ជាទីចង្អៀត (តស្មាតិហ ថបតយោ សម្ពាធោ ឃរាវាសោ)* សេចក្តីថា គហបតីទាំងឡាយ កាលតថាគតនៅឆ្ងាយ ពួកអ្នក រមែងមានសេចក្តីខ្វល់ចិត្តមិនមែនតិច កាលតថាគតនៅជិត ក៏រមែងមានសេចក្តីសប្បាយចិត្តមិនមែនតិច ព្រោះហេតុណា ហេតុនោះ គប្បីជ្រាបពាក្យនេះថា ការនៅគ្រប់គ្រងផ្ទះជាទីចង្អៀត ។ ក៏ព្រោះទោសនៃការនៅគ្រប់គ្រងផ្ទះ ពួកអ្នកទើបមានសេចក្តីគិតយ៉ាងនេះថា បើយើងលះបង់ឃរាវាស ហើយបួស ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងសេចក្តីនេះដល់ជាងឈើឈ្មោះថា **ឥសិទត្តៈ** នោះ ទើបត្រាស់យ៉ាងនេះថា កាលពួកអ្នកទៅនិងមកជាមួយនឹងតថាគតយ៉ាងនេះ ហេតុនោះទើបមិនមាន ។ គប្បីជ្រាប

សេចក្តីត្រង់ការនៅគ្រប់គ្រងផ្ទះចង្អៀត ព្រោះអត្ថថា មានកិលេសជាគ្រឿងឲ្យកង្វល់ និងមានសេចក្តីហួងហែង ក្នុងពាក្យនោះ ។ ក៏ការនៅគ្រប់គ្រងផ្ទះរបស់អ្នកដែលនៅក្នុងទីនៅដ៏ធំ ឈ្មោះថា ចង្អៀត ព្រោះអត្ថថា មានកិលេសជាតិជាគ្រឿងឲ្យកង្វល់ និងមានសេចក្តីហួងហែង ។

បទថា **ជាផ្លូវហូរមកនៃធូលី រជោបថោ** សេចក្តីថា ជាផ្លូវមកនៃធូលី គឺ រាគៈ ទោសៈ និងមោហៈ អធិប្បាយថា ដើម្បីប្រយោជន៍ដល់ការមក ។

បទថា **បព្វជ្ជាទើបមានឱកាសទូលាយ អព្ភោកាសោ បព្វជ្ជា** សេចក្តីថា បព្វជ្ជា ឈ្មោះថា មានឱកាសទូលាយ ព្រោះអត្ថថា មិនមានកិលេសជាតិជាគ្រឿងកង្វល់ និងមិនមានសេចក្តីហួងហែង ក៏បព្វជ្ជារបស់ភិក្ខុពីររូបដែលអង្គុយស្មឹងស្មាធ៏ក្នុងបន្ទប់សូម្បី ៤ ហត្ថ ឈ្មោះថា មានឱកាសទូលាយ ព្រោះអត្ថថា មិនមានកិលេសជាតិជាគ្រឿងកង្វល់ និងមិនមានសេចក្តីហួងហែង ។

បទថា **ម្នាលជាងឈើទាំងឡាយ គួរអ្នកទាំងឡាយកុំប្រមាទ (អលំ ច បន វោ ថបតយោ អប្បមាទាយា)** សេចក្តីថា ការដែលពួកអ្នកនៅជាយរាវាសជាទីចង្អៀតហើយយ៉ាងនេះ គួរធ្វើសេចក្តីមិនប្រមាទនោះឯង ។

[១៥០] បទថា *ពួកខ្ញុំព្រះអង្គ នឹងឲ្យ...ប្រថាប់គង់ខាងមុខព្រះអង្គ ខាងក្រោយព្រះអង្គ (ឯកំ បុរតោ ឯកំ បច្ឆតោ និសីទាបេម)* សេចក្តីថា បានឮថា ជនសូម្បីទាំងពីរប៉ុណ្ណោះ ឲ្យស្ត្រីទាំងនោះ ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ប្រថាប់អង្គុយលើដំរី ២ ក្បាល ទាំងនោះយ៉ាងនេះ ចាត់ចែងដំរីព្រះទីនាំងរបស់ព្រះរាជាទុកត្រង់កណ្តាល ហើយទៅក្នុងចន្លោះទាំងពីរខាង ព្រោះដូច្នោះ ពួកជាងឈើនោះទើបពោលហើយយ៉ាងនេះ ។

បទថា *សូម្បីដំរី ខ្ញុំព្រះអង្គទាំងឡាយក៏ត្រូវរក្សា (នាគោបិ រក្ខិតព្វោ)* សេចក្តីថា រមែងរក្សាដំរីទុក ដោយប្រការដែលដំរីនោះនឹងមិនធ្វើអ្វីៗឲ្យជាការបដិបត្តិខុស ដូច្នោះ ។

បទថា *ព្រះជយាសូម្បីទាំងនោះ (តាបិ ភគនិយោ)* សេចក្តីថា ព្រះជាយាទាំងនោះ រមែងមិនមានសេចក្តីប្រមាទដោយប្រការណា គប្បីរក្សាដោយប្រការនោះ ។

បទថា *ត្រូវរក្សាខ្លួនផង (អត្តាបិ)* សេចក្តីថា ដែលបុគ្គលទាំងឡាយមិនធ្វើកិរិយា មានការញញឹម ការរីករាយ ការពោល និងការសម្លឹងមើលជាដើម ឈ្មោះថា *គប្បីរក្សាខ្លួន* ។ បុគ្គលទាំងឡាយធ្វើ (ការញញឹមជាដើម)

ហើយយ៉ាងនោះ គប្បីត្រូវតិះដៀលថា អ្នកនេះ ប្រទូសរ៉ាយ ។ គហបតីទាំងឡាយ ព្រោះហេតុនោះឯង ព្រះរាជាវរមែងប្រគល់ឲ្យពួកអ្នកទទួលរាជ-កណ្ឌៈជានិច្ច ព្រោះហេតុណា ព្រោះហេតុនោះ យកវាសចង្អៀត ឈ្មោះថា **ជាផ្លូវមកនៃធូលី** ។ ក៏ភិក្ខុសមាទានសំពត់បង្សុកូល កាលឲ្យទទួលយ៉ាងនេះ រមែងមិនមាន ព្រោះហេតុណា ព្រោះហេតុនោះ បព្វជ្ជា ទើបឈ្មោះថា **មានឱកាសទូលាយ** ។

ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា សូម្បីបព្វជ្ជា យ៉ាងនេះ គហបតីទាំងឡាយ ក៏អ្នកទាំងឡាយកុំប្រមាទ គឺ ធ្វើសេចក្តីមិនប្រមាទនុ៎ះឯង ។

[១៥៣] បទថា **មានចាគៈដែលលះបង់ហើយ (មុត្តចាគោ)** សេចក្តីថា មានចាគៈដែលបានលះបង់ហើយ ។

បទថា **មានបាតដៃលាងស្អាត (បយតបាណី)** សេចក្តីថា មានដៃលាងហើយ ដើម្បីប្រយោជន៍ដល់ការឲ្យដល់អ្នកទាំងឡាយដែលមកហើយ ។

បទថា **ត្រេកអរក្នុងការលះបង់ (វោស្សគ្គរតោ)** សេចក្តីថា ជាអ្នកត្រេកអរហើយក្នុងការលះបង់ ពោលគឺ ការឲ្យ ។

បទថា **គួរដល់ការសូម (យាចយោគោ)** គឺ ជាអ្នកគួរដល់បុគ្គលគប្បីសូម ។

បទថា ត្រេកអរក្នុងការចែកនូវទាន (ទានសំវិភាគរតោ) សេចក្តីថា ជាអ្នកត្រេកអរហើយក្នុងការចែកវត្ថុណាៗ សូម្បីមានប្រមាណតិច ក្នុងទាននោះឯង ដែលបានហើយនោះ ។

[១៥៤] បទថា មិនបានចែករំលែកឡើយ (អប្បដិវិភត្តំ) សេចក្តីថា របស់ទាំងពួងមិនបានធ្វើការបែងចែកយ៉ាងនេះថា របស់នេះសម្រាប់អាត្មាអញ របស់នេះសម្រាប់ភិក្ខុទាំងឡាយទេ ជារបស់ដែលពួកអ្នកគប្បីឲ្យទាំងអស់ តាំងនៅហើយ ។

ចប់អដ្ឋកថា ៨បតិសូត្រទី ៦

# អ ដ្ឋ ក ថា

## វេឡុទ្វារសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង **វេឡុទ្វារសូត្រទី ៧** ។*

[១៥៥] *បទថា **វេឡុទ្វារៈ (វេឡុទ្វារំ)** សេចក្តីថា ដែលបានឈ្មោះយ៉ាងនេះ ព្រោះមានគុម្ពឫស្សីដែលដុះមកតាំងអំពីដើម ត្រង់ទ្វារស្រុក ។*

[១៥៩] *បទថា **បង្អោនចូលមកក្នុងខ្លួន (អត្តូបនាយិកំ)** សេចក្តីថា គប្បីបង្អោននាំចូលមកក្នុងខ្លួន ។*

[១៦៦] *បទថា **ចាកការពោលរោយរាយឥត ប្រយោជន៍ (សម្ផប្បលាបកាសេន)** សេចក្តីថា ចាកការនិយាយរោយរាយ អធិប្បាយថា ចាកការពោលដោយសេចក្តីមិនដឹង ដែលមិនមានប្រយោជន៍ ។*

ចប់អដ្ឋកថា វេឡុទ្វារសូត្រទី ៧

# អ ដ្ឋ ក ថា

## បឋមគិញ្ជកាវសថសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមគិញ្ជកាវសថសូត្រទី ៨ ។*

[១៧០] *បទថា* ***ស្រុកញាតិកៈ (ញាតិកេ)*** *សេចក្តីថា ស្រុក ២ របស់បុត្រនៃចូឡបិតិ និងមហាបិតិទាំងពីរមាន ព្រោះអាស្រ័យបឹងមួយ ។ បទថា* ***ញាតិកេ*** *បានដល់ ក្នុងស្រុកមួយ ។ បទថា* ***ផ្ទះស្នាក់ដែលធ្វើដោយឥដ្ឋ (គិញ្ជកាវសថេ)*** *សេចក្តីថា ទីនៅដែលធ្វើដោយឥដ្ឋ ។*

[១៧១] *បទថា* ***ចំណែកខាងក្រោម (ឱរម្ភាគិយានំ)*** *បានដល់ ចំណែកខាងក្រោម ដែលឲ្យបដិសន្ធិក្នុងកាមភពទាំងឯង ។ម្យ៉ាងទៀត ឈ្មោះថា* ***ឱរម្ភាគិយៈ*** *ព្រោះអត្ថថា គប្បីលះបានដោយមគ្គ ៣ ដែលបាន ឈ្មោះថា* ***ឱរៈ*** *ដូច្នេះ ។ បណ្តាសញ្ញោជនៈទាំងនោះ សញ្ញោជនៈពីរទាំងនេះ គឺ កាមច្ឆន្ទៈ ព្យាបាទៈ ដែលបុគ្គលមិនគ្របសង្កត់ដោយសមាបត្តិ ឬមិនបាន ដកឡើងដោយមគ្គ រមែងមិនឲ្យដល់រូបភព ឬអរូបភពដែលជាចំណែកខាង លើ ដោយអំណាចនៃការកើត ។ សញ្ញោជនៈ ៣ មានសក្កាយទិដ្ឋិជាដើម នាំសត្វដែលកើតហើយក្នុងរូបភពនោះ ឲ្យមកកើតសូម្បីក្នុងកាមភពនេះទៀត*

ព្រោះហេតុនោះ សញ្ញោជនៈសូម្បីទាំងអស់ ទើបឈ្មោះថា **ឱរម្ភាគិយៈ** នោះឯង ។

បទថា **មានសភាពមិនធ្លាក់ចុះជាធម្មតា (អនាវត្តិធម្មោ)** សេចក្ដីថា មានការមិនមកជាសភាវៈ ដោយអំណាចបដិសន្ធិ ។

បទថា **ព្រោះរាគៈ ទោសៈ និងមោហៈស្រាលស្ដើង (រាគទោស-មោហានំ តនុត្តា)** សេចក្ដីថា គប្បីជ្រាបរាគៈ ទោសៈ និងមោហៈស្រាលស្ដើង ២ យ៉ាងគឺ ដោយការកើតឡើងក្នុងលោកនេះមួយដង ១ ដោយការដែលបរិយុដ្ឋានកិលេសស្រាលស្ដើង ១ ។ ក៏រាគៈជាដើម រមែងមិនកើតឡើងរឿយៗ ដល់ព្រះសកទាគាមី ដូចកើតដល់ពួកបុថុជ្ជន គ្រាខ្លះពេលខ្លះក៏កើតឡើង ។ កាលនឹងកើតឡើង ក៏មិនកើតឡើងច្រើន ដូចពួកបុថុជ្ជនកើតឡើងស្រាលស្ដើង ដូចស្លាបរុយ ។ ក៏ព្រះទីឃភាណកតេបិដកមហា-សិវត្ថេរ ពោលហើយថា ព្រះសកទាគាមី រមែងមានបុត្រ និងធីតា (និង) ពួកស្នំ ព្រោះហេតុនោះ កិលេសទាំងឡាយទើបមានច្រើន ប៉ុន្តែថា ពាក្យនេះ លោកពោលហើយដោយអំណាចភព ។ ក៏ពាក្យនោះ ត្រូវជំទាស់ហើយព្រោះលោកពោលទុកក្នុងអដ្ឋកថាថា វៀរ ៧ ភព ភពទី ៨ ព្រះសោតាបន្នរមែងមិនមានសញ្ញោជនៈដែលស្រាលស្ដើងក្នុងភព វៀរ ២ ភព ក្នុង ៥ ភព

ព្រះសកទាគាមី រមែងមិនមានសញ្ញោជនៈដែលស្រាលស្តើងក្នុងភព វៀរ រូបភព អរូបភព ក្នុងកាមភព ព្រះអនាគាមី រមែងមិនមានសញ្ញោជនៈដែល ស្រាលស្តើងក្នុងភព ក្នុងភពណាៗ ព្រះខីណាស្រព រមែងមិនមានសញ្ញោជនៈ ដែលស្រាលស្តើងក្នុងភព ។

ពាក្យថា **លោកនេះ (ឥមំ លោកំ)** សេចក្តីថា លោកពោលសំដៅ យកកាមាវចរលោកនេះ ។

ក៏ក្នុងពាក្យនេះ មានអធិប្បាយដូចតទៅនេះថា ប្រសិនបើថា ភិក្ខុ ឈ្មោះថា **សាឡ្ហៈ** សម្រេចសកទាគាមិផលក្នុងមនុស្សលោក ហើយកើត ក្នុងទេវលោក ធ្វើឲ្យជាក់ច្បាស់ព្រះអរហត្ត នោះជាការប្រពៃ ។ ប៉ុន្តែថា (កាលមិនអាចសម្រេចដូចពោលហើយ) មកកាន់មនុស្សលោក ហើយក៏ នឹងធ្វើឲ្យជាក់ច្បាស់ព្រះអរហត្តដោយពិត ។ សូម្បីសម្រេចព្រះសកទា- គាមិផលក្នុងទេវលោកហើយ បើមកកើតក្នុងមនុស្សលោក ក៏នឹងធ្វើព្រះ- អរហត្តឲ្យជាក់ច្បាស់ នោះជាការប្រពៃ ។ ប៉ុន្តែថា កាលមិនអាច គ្រាទៅ ទេវលោកហើយ ក៏នឹងធ្វើឲ្យជាក់ច្បាស់ដោយពិត ។ ការធ្លាក់ចុះ ឈ្មោះថា **វិនិបាត** សេចក្តីធ្លាក់ចុះ ជាធម៌របស់ព្រះសោតាបន្នក៏មិនមែន ហេតុនោះ ឈ្មោះថា **មានការមិនធ្លាក់ចុះជាធម្មតា** ។ អធិប្បាយថា មានសេចក្តីមិន

ធ្លាក់ចុះជាសភាវៈ ក្នុងអបាយទាំង ៤ ។ បទថា **ទៀង (និយតោ)** បានដល់ជាបុគ្គលទៀង ដោយទំនងនៃធម៌ ។

បទថា **មានកិរិយាត្រាស់ដឹងក្នុងខាងមុខ (សម្ពោធិបរាយនោ)** សេចក្តីថា ការត្រាស់ដឹង ពោលគឺ មគ្គ ៣ ខាងលើ ជាទីទៅក្នុងខាងមុខ ជាគតិជាទីពឹង ដែលគេគប្បីសម្រេចដោយពិត ហេតុនោះ ឈ្មោះថា អ្នកមានការត្រាស់ដឹងព្រមប្រព្រឹត្តទៅក្នុងខាងមុខ ។

[១៧២] បទថា **ប្រការនេះជាសេចក្តីលំបាក (វិហេសាវេសា)** សេចក្តីថា អានន្ទ សេចក្តីលំបាកកាយនោះឯង រមែងប្រាកដសូម្បីដល់តថាគតដែលពិចារណាមើល គតិ ឧប្បត្តិ និងញាណជាគ្រឿងត្រាស់ដឹងក្នុងខាងមុខរបស់បុគ្គលទាំងនោះ ដោយព្រះញាណ ។ ប៉ុន្តែថា ព្រះពុទ្ធទាំងឡាយមិនមានសេចក្តីលំបាកផ្លូវចិត្ត ។ បទថា **ធម្មាទាស (ធម្មាទាសំ)** បានដល់កញ្ចក់ឆ្លុះ ពោលគឺ ធម៌ ។ បទថា **យេន** សេចក្តីថា ប្រកបហើយដោយកញ្ចក់ឆ្លុះ ពោលគឺ ដោយធម៌ណា ។

ពាក្យថា **មានអបាយ ទុគ្គតិ និងវិនិបាតអស់ហើយ (ខីណាបាយ-ទុគ្គតិវិនិបាតោ)** នេះ ព្រះដ៏មានព្រះភាគ ត្រាស់ហើយដោយពាក្យដែលជាវេវចនៈរបស់នរកជាដើមនុ៎ះឯង ។ ក៏នរកជាដើម ឈ្មោះថា **អបាយ** ព្រោះ

*ទៅប្រាសអំពីសេចក្ដីចម្រើន ។ **គតិ** គឺ ទីស្ទុះទៅនៃទុក្ខ ហេតុនោះ ឈ្មោះថា **ទុគ្គតិ** ។ បុគ្គលដែលមានប្រក្រតីធ្វើអាក្រក់ គ្មានអំណាច រមែងធ្លាក់ទៅក្នុងនរកជាដើមនោះ ហេតុនោះ ទើបឈ្មោះថា **វិនិបាត** ។*

ចប់អដ្ឋកថា គិញ្ជកាវសថសូត្រទី ៨

# អ ដ្ឋ ក ថា

## តតិយគិញ្ជកាវសថសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងតតិយគិញ្ជកាវសថសូត្រទី ១០ ។*

*[១៧៩] បទថា **ច្រើនជាង ៥០ នាក់** (បរោបញ្ញាស) បានដល់ ច្រើនជាង ៥០ នាក់ ។ បទថា **ច្រើនជាង ៩០ នាក់** (សាធិកនវុតិ) បានដល់ ច្រើនជាង ៩០ នាក់ ។ បទថា **ច្រើនជាង ៦ នាក់** (ឆាតិរេកានិ) បានដល់ ច្រើន (៥០០) ជាង ៦ នាក់ ។ បានឮមកថា ស្រុកនោះ មិនជាធំពេកទេ សូម្បីយ៉ាងនោះ ក្នុងស្រុកនោះក៏មានអរិយសាវកច្រើន ។ ក្នុងស្រុកនោះ មនុស្សស្លាប់ក្នុង គ្រាតែមួយ ប្រមាណ ២.៤០០.០០០ ដោយអហិវាតករោគ ។ ក្នុងបុគ្គលទាំងនោះ អរិយសាវកមានប្រមាណប៉ុណ្ណេះ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា តតិយគិញ្ជកាវសថសូត្រទី ១០

### ចប់ទេវវគ្គទី ១

### រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១អដ្ឋកថា រាជសូត្រ ២អដ្ឋកថា ឱគធសូត្រ

៣ អដ្ឋកថា ទីឃាវុសូត្រ ៤ អដ្ឋកថា ទុតិយសារីបុត្តសូត្រ
៥ អដ្ឋកថា ថបតិសូត្រ ៦ អដ្ឋកថា វេឡុទ្វារសូត្រ
៧ អដ្ឋកថា បឋមគិញ្ជ...សូត្រ ៦ អដ្ឋកថា តតិយគិញ្ជ...សូត្រ

# រាជការាមវគ្គទី ២

## អ ដ្ឋ ក ថា

## សហស្សសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សហស្សសូត្រទី ១ ។*

[១៨២] *ពាក្យថា រាជការាម បានដល់ អារាមដែលបានឈ្មោះយ៉ាងនេះ ព្រោះព្រះរាជាទ្រង់ឲ្យសាង ។ សួរថា ព្រះរាជាអង្គណា ។ ឆ្លើយថា ព្រះបាទបសេនទិកោសល ។*

*បានឮមកថា ក្នុងបឋមពោធិកាល ពួកតិរ្ថិយឃើញព្រះសាស្តាដែលទ្រង់ដល់នូវភាពដ៏ប្រសើរដោយយស និងលាភ នាំគ្នាគិតហើយថា ព្រះសមណគោតមដល់នូវភាពដ៏ប្រសើរដោយលាភ និងយស ក៏សីល ឬសមាធិយ៉ាងដទៃណាៗ របស់ព្រះសមណគោតមនោះមិនមាន ព្រះសមណគោតមនោះ ដល់នូវសេចក្តីចម្រើនដោយលាភ និងយសយ៉ាងនេះ ដូចជាកាន់យកផ្ទៃផែនដីដ៏ធំ បើសូម្បីពួកយើងអាចឲ្យសាងវត្តជិតព្រះជេតពនបាន ក៏នឹងគប្បីជាអ្នកដល់នូវសេចក្តីចម្រើនដោយលាភ និងយស ។ តិរត្ថិយ៍ទាំង*

នោះ ទើបបបួលឧបដ្ឋាករបស់ខ្លួនបានប្រមាណ ១០០.០០០ នាក់ បាន កហាបណៈហើយ ក៏នាំឧបដ្ឋាកទាំងនោះទៅរាជសម្នាក់ ។ ព្រះរាជាត្រាស់ សួរថា អ្នកទាំងឡាយមានការអ្វី ។ ទូលថា ពួកខ្ញុំព្រះអង្គនឹងសាងវត្តរបស់ តិរ្ថិយជិតជេតពន ប្រសិនបើព្រះសមណគោតម ឬពួកសាវករបស់ព្រះ- សមណគោតមនឹងមកហាម សូមព្រះអង្គកុំបណ្ដោយឲ្យហាមឡើយ ហើយ បានថ្វាយសំណូក ។ ព្រះរាជាទទួលសំណូកហើយ ត្រាស់ថា ពួកអ្នកចូរ ទៅសាងចុះ ។

ពួកតិរ្ថិយនោះ ទើបឲ្យពួកឧបដ្ឋាករបស់ខ្លួនជញ្ជូនទព្វសម្ភារៈមក ហើយធ្វើការលើកសសរជាដើម បន្លឺសំឡេងគឹកកងលាន់ឡើង ធ្វើកោ- លាហលតែម្យ៉ាង ។ ព្រះសាស្ដា ស្ដេចចេញពីព្រះគន្ធកុដិ ប្រថាប់ត្រង់ យ៉មុខ ត្រាស់សួរហើយថា អានន្ទ ក៏ពួកនរណានោះ ប្រាកដដូចជាពួក ព្រានប្រមង់ មានសំឡេងគឹកកងលាន់ឮ ដណ្ដើមត្រីគ្នា ។

អា. ពួកតិរ្ថិយ សាងវត្តរបស់តិរ្ថិយជិតព្រះជេតពន ព្រះអង្គ ។

ព្រះ. អានន្ទ ពួកនេះជាសត្រូវដល់សាសនា នឹងធ្វើឲ្យនៅមិនជាសុខ ដល់ពួកភិក្ខុ អ្នកចូរទូលព្រះរាជា ហើយឲ្យរុះរើចេញទៅ ។

ព្រះថេរៈព្រមដោយពួកភិក្ខុ បានទៅឈរត្រង់ព្រះទ្វារហ្លួង ។ រាជ-

បុរសទាំងឡាយក្រាបទូលដល់ព្រះរាជាថា បពិត្រសម្មតិទេព ពួកព្រះថេរៈមកគាល់ ។ ព្រះរាជាស្តេចទ្រង់មិនបានចេញមក ព្រោះបានទទួលសំណូកហើយ ។ ព្រះថេរៈទាំងឡាយ ទើបទៅក្រាបទូលព្រះសាស្តា ។ ព្រះ-សាស្តាទ្រង់បញ្ជូនព្រះសារីបុត្រ និងព្រះមោគ្គល្លានទៅ ។ ព្រះរាជាមិនបានព្រះរាជទានសូម្បីការគាល់របស់ព្រះថេរៈទាំងពីរនោះ ។ ព្រះថេរៈទាំងនោះ ទើបមកក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជាស្តេចមិនបានចេញមកឡើយ ។ ព្រះសាស្តាទ្រង់ព្យាករណ៍ក្នុងខណៈនោះឯងថា ព្រះរាជាតាំងនៅក្នុងរាជសម្បត្តិរបស់ខ្លួន តែមិនបានដើម្បីធ្វើកាលៈឡើយ ។

ថ្ងៃទីពីរ ព្រះអង្គនោះឯង មានពួកភិក្ខុជាបរិវារ ស្តេចយាងទៅប្រថាប់ឈរត្រង់ទ្វារហ្លួង ។ ព្រះរាជាទ្រង់ជ្រាបថា ព្រះសាស្តាស្តេចមកហើយ ទើបស្តេចចេញទៅក្រាបទូលឲ្យព្រះមានព្រះភាគចូលនិវេសន៍ ឲ្យប្រថាប់គង់លើរាជបល្ល័ង្ក ទ្រង់បានថ្វាយបបរ និងរបស់ទំពារ ។ ព្រះសាស្តាសោយបបរ និងរបស់ទំពារហើយ មិនត្រាស់ថា "មហាបពិត្រ ព្រះអង្គធ្វើហេតុនេះហើយ" ចំពោះព្រះរាជាអ្នកស្តេចមកប្រថាប់អង្គុយ ដោយព្រះរាជ-តម្រិះថា យើងនឹងអង្គុយក្នុងសម្នាក់របស់ព្រះសាស្តា ជរាបទ្រង់ព្រះក្រយាហារ

សម្រេច ដូច្នេះ ទើបទ្រង់ត្រិះរិះថា តថាគតនឹងឲ្យព្រះរាជានោះយល់ព្រម ព្រោះហេតុនោះ ទើបទ្រង់នាំហេតុក្នុងអតីតមកថា "មហាបពិត្រ ដែលឈ្មោះថា ការឲ្យពួកបព្វជិតរុក្កូនគ្នានិងគ្នាមិនសមគួរ ព្រះរាជាទ្រង់ឲ្យពួកឥសីទាំងនោះរុក្កូនគ្នានិងគ្នាហើយ បានលិចក្នុងមហាសមុទ្រទៅព្រមជាមួយនឹងដែនដី" ។ ព្រះរាជាត្រាស់សួរថា "កាលណា បពិត្រព្រះអង្គ" ។

ព្រះសាស្តាត្រាស់ថា "មហាបពិត្រ ក្នុងអតីត ព្រះរាជាព្រះនាមថា កុរុ ក្នុងដែនកុរុ គ្រងរាជសម្បត្តិនៅ ។ គណៈឥសី ២ គណៈ មួយគណៈ ៥០០ ទៅអំពីជើងភ្នំកុរុ កាន់កុរុនគរ ដើម្បីនឹងសេពរសប្រៃ និងជូរ ដែលមិនឆ្ងាយព្រះនគរ មានដើមឈើពីរដើម ។ គណៈឥសីដែលមកមុន អង្គុយនៅត្រង់គល់ឈើមួយដើម ។ សូម្បីគណៈឥសីដែលមកខាងក្រោយ ក៏បានអង្គុយត្រង់គល់ដើមឈើមួយដើមទៀត ។ ពួកឥសីបាននៅតាមសេចក្តីពេញចិត្តហើយ ក៏ទៅកាន់ជើងភ្នំវិញ ។ ពួកឥសីនោះ សូម្បីមកទៀត ក៏បានអង្គុយក្នុងទីមួយនៃគល់ឈើរបស់ខ្លួន ។ ពួកឥសីដែលមកខាងក្រោយ ក៏បានអង្គុយត្រង់គល់ដើមឈើរបស់ខ្លួនដូចគ្នា ។ កាលវេលាកន្លងទៅយូរ ដើមឈើមួយដើមក៏ងាប់ ។ ពួកតាបសមកត្រង់ដើមឈើងាប់នោះ គិតថា ដើមឈើមួយដើមនេះ (ដើមដែលមិនទាន់ងាប់) ធំ នឹងល្មមសូម្បីដល់ពួក

យើង តាបសទាំងនោះ ទើបអង្គុយក្នុងទីមួយកន្លែងនៃដើមឈើរបស់ពួកតាបសក្រៅពីនេះ ។ តាបសទាំងនោះមកហើយខាងក្រោយ មិនចូលទៅទីគល់នោះ ឈរនៅខាងក្រៅ ហើយពោលថា “លោកទាំងឡាយអង្គុយក្នុងទីនេះ ព្រោះហេតុអ្វី? តាបសទាំងនោះពោលថា លោកអាចារ្យ ដើមឈើរបស់ពួកខ្ញុំងាប់ហើយ ដើមឈើនេះជាដើមឈើធំ សូម្បីពួកលោកចូរចូលមកចុះ ក៏នឹងល្មមសូម្បីដល់ពួកលោកផង ដល់ពួកខ្ញុំផង ។

ពួកតាបសពោលថា “ពួកយើងនឹងចូលទៅ តែពួកលោកចូរចេញហើយពោលពាក្យថែមទៀតថា ពួកលោកមិនពេញចិត្តចេញទៅទេឬ ទើបចាប់ត្រង់ដៃជាដើមទាញចេញទៅ ។

តាបសទាំងនោះទើបគិតថា ណ្ហើយចុះ យើងនឹងឲ្យពួកឥសីនោះគិត ហើយនិម្មិតកង់ ២ សម្រេចដោយមាស និងភ្លៅសម្រេចដោយប្រាក់ដោយឫទ្ធិ បានឲ្យវិលទៅព្រះទ្វារហ្លួង ។ ពួករាជបុរស ក្រាបទូលរឿងនេះឲ្យព្រះរាជាទ្រង់ជ្រាបថា ព្រះអង្គ ពួកតាបសកាន់គ្រឿងបណ្ណាការ ឈរហើយ ។ ព្រះរាជាទ្រង់ត្រេកអរ ហើយត្រាស់ថា ពួកអ្នកចូរហៅមក ឲ្យហៅមក ហើយត្រាស់ថា ពួកលោកធ្វើកម្មធំហើយ រឿងអ្វីៗ ដែលខ្ញុំនឹងគប្បីធ្វើដល់ពួកលោកមានដែរឬ ។

តាបស. សូមថ្វាយព្រះពរមហាបពិត្រ មានដើមឈើមួយដើម ដែលជាទីអន្ទុយរបស់ពួកខ្ញុំព្រះអង្គ គល់ឈើនោះ ត្រូវពួកឥសីជទៃដណ្ដើមយកហើយ សូមព្រះអង្គឲ្យពួកឥសីនោះ ប្រគល់គល់ឈើនោះដល់ពួកខ្ញុំព្រះអង្គ ។

ព្រះរាជា ទើបបញ្ជូនពួករាជបុរសទៅឲ្យដេញពួកតាបសចេញទៅ ។ ពួកឥសីដែលឈរខាងក្រៅ គិតថា ពួកតាបសនេះឲ្យអ្វីហ្ន៎ទើបបានហើយ ឃើញថា វត្ថុនេះ ទើបគិតថា សូម្បីពួកយើងឲ្យសំណូកហើយ ក៏នឹងកាន់យកបាន ទើបនិម្មិតបន្ទួចរថដោយមាស ដោយឫទ្ធិ កាន់ទៅហើយ ។ ព្រះរាជាទ្រង់ឃើញហើយ ត្រេកអរ ត្រាស់ថា លោកម្ចាស់ ខ្ញុំគប្បីធ្វើយ៉ាងណា ។

ពួកតាបសទូលថា មហាបពិត្រ គណៈឥសីជទៃអន្ទុយត្រង់គល់ឈើរបស់ពួកខ្ញុំព្រះអង្គ សូមព្រះអង្គប្រទានគល់ឈើនោះ ។

ព្រះរាជាទ្រង់បញ្ជូនពួករាជបុរសទៅ ឲ្យបណ្ដេញតាបសទាំងនោះចេញ ។ ពួកតាបសធ្វើការឈ្លោះគ្នានិងគ្នាហើយ ជាអ្នកក្ដៅក្រហាយថា ពួកយើងធ្វើកម្មមិនសមគួរឡើយ ទើបបានទៅកាន់ជើងភ្នំវិញ ។ លំដាប់នោះ ទេវតាក៏ក្រោធខឹង ហើយពោលថា ព្រះរាជានេះទទួលសំណូកពីដៃរបស់គណៈតាបសសូម្បីទាំងពីរ ធ្វើឲ្យមានការឈ្លោះគ្នានិងគ្នា ទើបបង្អុរទឹក

មហាសមុទ្រ ធ្វើទីផ្លូវប្រមាណ ១.០០០ យោជន៍ នៃដែនដីរបស់ព្រះរាជានោះ ឲ្យក្លាយជាសមុទ្រតែម្តង ។

ខ្ញុំបានស្តាប់មកថា កុរុរាជា ធ្វើឲ្យតាបសទាំងឡាយ
ឲ្យបែកគ្នា ព្រះរាជានោះ ព្រមទាំងដែនដី ទើបត្រូវ
ទម្លាយហើយ ដល់សេចក្តីវិនាសហើយ ដូច្នេះ ។

លុះព្រះដ៏មានព្រះភាគទ្រង់សម្តែងអតីតនេះ យ៉ាងនេះហើយ ព្រោះដែលឈ្មោះថា ពាក្យរបស់ព្រះពុទ្ធទាំងឡាយ បុគ្គលគួរជឿ ហេតុនោះព្រះរាជាទ្រង់កំណត់ ពិចារណាកិរិយារបស់ព្រះអង្គហើយ ទ្រង់ត្រិះរិះថា កម្មដែលមិនគួរធ្វើ យើងបានធ្វើហើយ ទើបត្រាស់ថា "នាយ ពួកអ្នកចូរទៅដេញពួកតិរ្ថិយចេញទៅ លុះទ្រង់ឲ្យដេញចេញទៅហើយ ទើបត្រិះរិះថា វិហារដែលយើងឲ្យសាងនៅមិនទាន់មាន យើងនឹងឲ្យសាងវិហារក្នុងទីនោះឯង ដូច្នេះ ហើយមិនព្រះរាជទានទព្វសម្ភារៈដល់តិរ្ថិយទាំងនោះ ទ្រង់ឲ្យសាងវិហារហើយ ។ ពាក្យនោះ (រាជការាម) ព្រះសង្គីតិកាចារ្យពោលហើយ សំដៅយកវិហារនោះឯង ។

ចប់អដ្ឋកថា សហស្សសូត្រទី ១

# អ ដ្ឋ ក ថា

## ព្រាហ្មណសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រាហ្មណសូត្រទី ២ ។*

[១៨៣] *ពាក្យថា* **បដិបទា** *ឈ្មោះថា* **ឧទយគាមិនី** *(ឧទយគាមិនឹ) សេចក្តីថា បដិបទាជាគ្រឿងឲ្យដល់សេចក្តីចម្រើនក្នុងលទ្ធិរបស់ខ្លួន ។*

*បទថា* **គប្បីរង់ចាំសេចក្តីស្លាប់** *(មរណំ អាគមេយ្យាសិ)* បានដល់ *គប្បីប្រាថ្នាសេចក្តីស្លាប់ ។*

ចប់អដ្ឋកថា ព្រាហ្មណសូត្រទី ២

# អ ដ្ឋ ក ថា

## បឋមទុគ្គតិសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុគ្គតិសូត្រទី ៤ ។*

[១៩២] *បទថា រមែងចួងផុតភ័យ គឺ ទុគតិទាំងអស់បាន (សព្វ-ទុគ្គតិភយំ សមតិក្កន្តោ) សេចក្តីថា ទ្រង់ហាមបុគ្គលជាអ្នកមានចំណែកពីរ របស់មនុស្ស ។*

ចប់អដ្ឋកថា បឋមទុគ្គតិសូត្រទី ៤

# អ ដ្ឋ ក ថា

## ទុតិយទុគ្គតិសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយទុគ្គតិសូត្រទី ៥ ។*

[១៩៣] *បទថា រមែងកន្លងភ័យ គឺ ទុគ្គតិ និងវិនិបាតទាំងអស់បាន (សព្វទុគ្គតិវិនិបាតភយំ សមតិក្កន្តោ) សេចក្តីថា ទ្រង់ហាមអបាយ ៤ នឹងកាពជាអ្នកមានចំណែកពីរបស់មនុស្ស ។*

ចប់អដ្ឋកថា ទុតិយទុគ្គតិសូត្រទី ៥

# អ ដ្ឋ ក ថា

## បឋមមិត្តាមច្ចសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមមិត្តាមច្ចសូត្រទី ៦** ។*

[១៩៤] *ពាក្យថា **មិត្ត** (មិត្តា) បានដល់ មិត្តតាមវោហារ ដោយអំណាចការបរិភោគអាមិសក្នុងផ្ទះនៃគ្នានិងគ្នា ។ ពាក្យថា **អាមាត្យ** (អមច្ចា) បានដល់ អ្នកឲ្យការងារដែលគួរធ្វើប្រព្រឹត្តទៅរួមគ្នា ក្នុងការជួយប្រឹក្សានិងឥរិយាបថជាដើម ។ ពាក្យថា **ញាតិ** (ញាតី) បានដល់ ជាចំណែកតាយាយ ។ ពាក្យថា **សាលោហិត** (សាលោហិតា) បានដល់ បងប្អូនប្រុស បងប្អូនស្រី និងអ៊ំជាដើម ដែលមានលោហិតស្មើគ្នា ។*

ចប់អដ្ឋកថា បឋមមិត្តាមច្ចសូត្រទី៦

# អ ដ្ឋ ក ថា

## ទុតិយមិត្តាមច្ចសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយមិត្តាមច្ចសូត្រទី ៧ ។

[១៩៦] ឈ្មោះថា សេចក្តីប្រែប្រួលយ៉ាងដទៃ មានច្រើនយ៉ាង គឺ សេចក្តីប្រែប្រួលជាយ៉ាងដទៃដោយសេចក្តីជ្រះថ្លា សេចក្តីប្រែប្រួលជាយ៉ាងដទៃដោយភាវៈ សេចក្តីប្រែប្រួលជាយ៉ាងដទៃដោយគតិ សេចក្តីប្រែប្រួលជាយ៉ាងដទៃដោយលក្ខណៈ សេចក្តីប្រែប្រួលជាយ៉ាងដទៃដោយការផ្លាស់ប្តូរ ។

ក្នុងសេចក្តីប្រែប្រួលជាយ៉ាងដទៃនោះ សេចក្តីប្រែប្រួលជាយ៉ាងដទៃដោយភាវៈ ព្រះដ៏មានព្រះភាគទ្រង់បំណងយកក្នុងមហាភូតទាំងឡាយ ។ ក៏កាលបឋវីធាតុដែលជាប់ដោយសភាពក្រាស់ណែន ដោយភាវៈជាមាសជាដើម បែកធ្លាយហើយ ដល់ភាពជាទឹកហើយ ភាវៈក្នុងគ្រាមុនក៏វិនាសទៅ ការប្រែប្រួលជាយ៉ាងដទៃដោយភាវៈក៏នឹងប្រាកដ ។ ចំណែកលក្ខណៈមិនបាត់ទៅ គឺ បឋវីធាតុមានសភាពរឹងជាលក្ខណៈនោះឯង ។

កាលអាបោធាតុ ដែលបន្តទៅដោយអាការដែលប្រែប្រួលទៅ ដោយ

កាលជារសអំពៅជាដើមអស់ទៅ ដល់សភាពជាផែនក្រាស់រឹង ភាវៈក្នុងគ្រាមុនក៏នឹងបាត់ទៅ ការប្រែប្រួលជាយ៉ាងដទៃដោយភាវៈក៏នឹងប្រាកដឡើង ។ តែលក្ខណៈនឹងមិនបាត់ទៅ គឺ អាបោធាតុនោះមានការកកផ្តុំឲ្យជាប់គ្នា ជាលក្ខណៈ ។ ក៏សេចក្តីប្រែប្រួលជាយ៉ាងដទៃដោយគតិនេះ ក្នុងសេចក្តីប្រែប្រួលជាយ៉ាងដទៃនោះ ព្រះដ៏មានព្រះភាគទ្រង់បំណងយកក្នុងបទនេះថា *សេចក្តីប្រែប្រួលជាយ៉ាងដទៃ* ។ ក៏សេចក្តីប្រែប្រួលជាយ៉ាងដទៃនោះរមែងមិនមានដល់អរិយសាវក ។ សូម្បីសេចក្តីប្រែប្រួលជាយ៉ាងដទៃ ដោយសេចក្តីជ្រះថ្លា ក៏មិនមានទុំះឯង ។ ដើម្បីប្រកាសផលរបស់សេចក្តីជ្រះថ្លាព្រះដ៏មានព្រះភាគ ទើបទ្រង់សម្តែងសេចក្តីប្រែប្រួលជាយ៉ាងដទៃ ដោយគតិ ទុកក្នុងបទនេះទុំះឯង ។ ពាក្យដ៏សេសក្នុងគ្រប់ៗ បទ ងាយយល់ទាំងអស់នោះឯង ។

ចប់អដ្ឋកថា ទុតិយមិត្តាមច្ចសូត្រទី ៧

## ចប់រាជការាមវគ្គទី ២

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ


១ អដ្ឋកថា សហស្សសូត្រ ២ អដ្ឋកថា អានន្ទសូត្រ
៣ អដ្ឋកថា បឋមទុគ្គតិសូត្រ ៤ អដ្ឋកថា ទុតិយទុគ្គតិសូត្រ
៥ អដ្ឋកថា បឋមមិត្តាមច្ចសូត្រ ៦ អដ្ឋកថា ទុតិយមិត្តាមច្ចសូត្រ

# សរកានិវគ្គទី ៣

## អ ដ្ឋ ក ថា

### បឋមមហានាមសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមហានាមសូត្រទី ១ ។*

*[២០៨] បទថា **ស្តុកស្តម្ភ** (ឥទ្ធំ) គឺ ស្តុកស្តម្ភបរិបូរដោយប្រេង ទឹកឃ្មុំ និង ទឹកអំពៅជាដើម ។*

*បទថា **ចម្រើនរុងរឿង** (ផីតំ) គឺ សម្បូរទៅដោយគ្រឿងប្រដាប់ មានគ្រឿងពាក់ដៃ និងពាក់សីសៈជាដើម ។ ពាក្យថា **កុះករទៅដោយមនុស្ស** (អាកិណ្ណមនុស្សំ) គឺ មានមនុស្សរកចន្លោះមិនបាន ។ ថ្នល់ដែលដើរមិនបានរហូត លោកហៅថា **ព្យូហៈ** ក្នុងបទថា **មានថ្នល់ចង្អៀត** (សម្ពាធព្យូហំ) មនុស្សទាំងឡាយចូលទៅដោយផ្លូវ ដែលចូលទៅក្នុងថ្នល់ណា ថ្នល់ទាំងនោះចង្អៀតមានច្រើនក្នុងនគរនេះ ហេតុនោះ ព្រះនគរនេះឈ្មោះថា មានថ្នល់ចង្អៀត ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងការរស់នៅយ៉ាងច្រើនកុះកររបស់អ្នកនគរ សូម្បីដោយពាក្យនេះ ។*

*បទថា ដែលពពាក់ពពូន (វិត្ថានេ្ថន) បានដល់ វិលទៅជុំវិញៗ ម្តងខាងនេះម្តងខាងនោះ ព្រោះការពពាក់ពពូន ។*

ចប់អដ្ឋកថា បឋមមហានាមសូត្រទី ១

# អ ដ្ឋ ក ថា

## គោធាសូត្រទី ៣

[២១៤] គប្បីជ្រាបវិនិច្ឆ័យក្នុង *គោធាសូត្រទី ៣* ។

[២១៧] ស្តេចសក្យៈនោះ ត្រាស់ពាក្យនេះថា ព្រះដ៏មានព្រះភាគប៉ុណ្ណោះ ទ្រង់គប្បីជ្រាបរឿងនេះថា បុគ្គលដែលប្រកបដោយធម៌ទាំងនេះ ឬដែលមិនប្រកបដោយធម៌ទាំងនេះ (ភគវា វ ឯតំ ជានេយ្យ ឯតេហិ ធម្មេហិ សមន្នាគតំ វា អសមន្នាគតំ វា) ដោយបំណងថា ព្រះដ៏មានព្រះភាគប៉ុណ្ណោះ ទ្រង់ជ្រាបដល់បុគ្គលប្រកបដោយធម៌ ៣ ប្រការ ជាព្រះសោ-តាបន្ន ឬបុគ្គលដែលប្រកបដោយធម៌ ៤ ប្រការ ជាព្រះសោតាបន្ន ។

[២២២] បទថា ការកើតនៃហេតុចំពោះប្រការខ្លះ គប្បីកើតឡើង (កោចិទេវ ធម្មសមុប្បាទោ ឧប្បជ្ជេយ្យ) សេចក្តីថា ហេតុណានីមួយ គប្បីកើតឡើង ។ បទថា ចំណែកមួយជាព្រះដ៏មានព្រះភាគ ចំណែកមួយជាភិក្ខុសង្ឃ (ឯកតោ អស្ស ភគវា ឯកតោ ភិក្ខុសង្ឃោ) សេចក្តីថា កាលបើហេតុណាកើតឡើងហើយ ព្រះដ៏មានព្រះភាគទ្រង់មានលទ្ធិ (ការឃើញ) ផ្សេងពីភិក្ខុសង្ឃ ត្រាស់វាទៈមួយយ៉ាង ឈ្មោះថា ជាចំណែកមួយ សូម្បី

ភិក្ខុសង្ឃ ក៏មានការគិតផ្សេងអំពីព្រះដ៏មានព្រះភាគ ពោលវាទៈមួយយ៉ាង ឈ្មោះថា ជាចំណែកមួយទៀត ។ បទថា **ខ្ញុំព្រះអង្គគប្បីមានចំណែកនោះ (តេនេវាហំ អស្សំ)** សេចក្ដីថា ព្រះអង្គត្រាស់ព្រះវាចាណា ខ្ញុំព្រះអង្គគប្បីកាន់យក (ជឿស្ដាប់) ព្រះវាចានោះ ។ ក៏សេចក្ដីប្រែប្រួលជាយ៉ាងដទៃ ដោយសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យ រមែងមិនមានដល់ព្រះអរិយសាវក មិនមែនឬ? ព្រោះហេតុអ្វី ស្ដេចសក្យៈនោះ ទើបត្រាស់យ៉ាងនេះ? ព្រោះព្រះដ៏មាន-ព្រះភាគ ទ្រង់ជាព្រះសព្វញ្ញូ ។ ក៏ស្ដេចសក្យៈនោះ រមែងមានសេចក្ដីគិតយ៉ាងនេះថា ភិក្ខុសង្ឃសូម្បីមិនដឹង គប្បីពោល ព្រោះខ្លួនមិនមែនសព្វញ្ញូ ចំណែកព្រះសាស្ដា ដែលឈ្មោះថា ទ្រង់មិនជ្រាបមិនមាន ដូច្នេះ ព្រោះហេតុនោះ ទើបពោលទុកយ៉ាងនេះឯង ។

[២២៧] បទថា **ក្រៅពីកល្យាណធម៌ និងកុសលធម៌ (អញ្ញត្រ កល្យាណា អញ្ញត្រ កុសលា)** សេចក្ដីថា ខ្ញុំព្រះអង្គរមែងពោលកល្យាណធម៌ និងកុសលប៉ុណ្ណោះ រមែងមិនពោលពាក្យដែលផុតអំពីកល្យាណធម៌ និងកុសលធម៌ ។ ព្រោះហេតុនោះ សក្យរាជព្រះនាមថា **គោធា** ទើបមានធម៌ដែលរកទោសមិនបាន ។

ចប់អដ្ឋកថា គោធាសូត្រទី ៣

# អ ដ្ឋ ក ថា

## បឋមសរកានិសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសរកានិសូត្រទី ៤ ។

[២៣១] ពាក្យថា មហាបពិត្រ បុគ្គលខ្លះក្នុងលោកនេះ (ឥធ មហានាម ឯកច្ចោ បុគ្គលោ) សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ប្រារព្ធ ដើម្បីទ្រង់នឹងសម្តែងថា សក្យរាជឈ្មោះថា សរកានិ ទុះឯង ផុតពីអបាយតែម្យ៉ាងក៏មិនមែន សូម្បីបុគ្គលទាំងនេះក៏រួចផុតហើយ ។

[២៣៤] បទថា រមែងអត់ទ្រាំដល់ការសម្លឹង...ដោយប្រមាណ (មត្តសោ និជ្ឈានំ ខមន្តិ) សេចក្តីថា រមែងអត់ទ្រាំដល់ការពិចារណាដោយប្រមាណ ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងបុគ្គលដែលតាំងនៅក្នុងមគ្គ ឈ្មោះថា ធម្មានុសារី ដោយបទនេះ ។ បទថា មិនទៅកាន់នរក (អគន្តា និរយំ) សេចក្តីថា ក៏ការពោលថា "បុគ្គលដែលតាំងនៅក្នុងមគ្គ ជាអ្នករួចផុតហើយ ឬថា នឹងផុតពីអបាយ" ដូច្នេះ ក៏គួរ ។ ក៏បុគ្គលរមែងរួចផុតដោយជុំវិញ ព្រោះហេតុណា ព្រោះហេតុនោះ ដែលឈ្មោះថា បុគ្គលទៅហើយ រមែងមិនមាន ព្រោះហេតុនោះ លោកទើបពោលថា "មិនទៅ" អធិប្បាយ រមែងមិនទៅ ។

[២៣៦] *ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងបុគ្គល ដែលតាំងនៅក្នុងមគ្គឈ្មោះថា សទ្ធានុសារី ដោយបទនេះថា* ***អ្នកមានសទ្ធាល្មមប្រមាណ (សទ្ធា-មត្តំ) អ្នកមានសេចក្ដីស្រឡាញ់ល្មមប្រមាណ (បេមមត្តំ)*** *ដោយបទនេះ ។*

[២៣៧] *ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងដើមឈើធំមានខ្លឹម ៤ ដើម ដែលតាំងនៅជិតគ្នា ទើបត្រាស់ក្នុងបទថា* ***មហាសាលា*** *ដូច្នេះ ។ ក្នុងបទថា* ***សរកានិសក្យរាជ សមាទានសិក្ខាក្នុងវេលាជិតនឹងអស់ព្រះជន្ម (មរណកាលេ សិក្ខំ សមាទិយីតិ)*** *នេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងថា "ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសិក្ខា ៣ ក្នុងវេលាជិតអស់ព្រះជន្ម ។*

ចប់អដ្ឋកថា បឋមសរកានិសូត្រទី ៤

# អ ដ្ឋ ក ថា

## ទុតិយសរកានិសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសរកានិសូត្រទី ៥ ។*

*[២៤៧] បទថា **ស្រែអាក្រក់ (ទុក្ខេត្តំ)** បានដល់ ស្រែដែលមិនស្មើគ្នា ។ បទថា **មានផ្ទៃដីមិនល្អ (ទុព្ភូមី)** បានដល់ មានដីរឹង ហើយប្រៃ ។ បទថា **បែកក្រហែង (ខណ្ឌានិ)** បានដល់ បែកទូទៅ ។ បទថា **ស្អុយ (បូតិនិ)** បានដល់ សើមដោយទឹកហើយក៏ស្អុយរលួយ ។ បទថា **ត្រូវខ្យល់និងកំដៅ ថ្ងៃប៉ះខ្ទប់ហើយ (វាតាតបហតានិ)** សេចក្ដីថា ដល់សេចក្ដីវិនាសព្រោះខ្យល់ និងកំដៅថ្ងៃទម្លាយហើយ ។ បទថា **មិនកាន់យកខ្លឹមសារ (អសារាទានិ)** បានដល់ មិនកាន់យកខ្លឹម គឺ មិនមានសារៈល្មមនឹងកាន់យកបាន ។ បទថា **រក្សាទុកមិនល្អ (អសុខសយិតានិ)** សេចក្ដីថា រក្សាដាក់ទុកក្នុងជង្រុកជាដើមមិនល្អ ។*

*[២៤៨] បទថា **រក្សាទុកល្អហើយ (សុខសយិតានិ)** សេចក្ដីថា មិនដុះរហូតអស់ ៤ ខែ អំពីទីដែលរក្សាទុក ។*

ចប់អដ្ឋកថា ទុតិយសរកានិសូត្រទី ៥

# អ ដ្ឋ ក ថា

## បឋមទុសីលយសូត្រទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមទុសីលយសូត្រទី ៦ ។

[២៥១] បទថា វេទនាទឹងគប្បីស្ងប់រម្ងាប់ដោយឆាប់រហ័ស (ឋាន-សោ វេទនា បដិប្បស្សម្ភេយ្យុំ) បានដល់ វេទនាគប្បីរម្ងាប់ក្នុងខណៈ ។

[២៦៣] បទថា ដោយមិច្ឆាញាណៈ (មិច្ឆាញាណេ) បានដល់ ដោយការពិចារណាខុស ។

[២៦៤] បទថា ដោយមិច្ឆាវិមុត្តិ (មិច្ឆាវិមុត្តិយា) បានដល់ ដោយការរួចផុត ដែលមិននាំចេញចាកទុក្ខ ។

[២៦៦] បទថា ព្រោះដូច្នោះ...ដែលសទ្ធា និងសីល (តស្មា សទ្ធញ្ច សីលញ្ច) លោកបានពោលទុកក្នុងគាថាហើយ ។ បទថា យត្រ ហិ នាម ស្មើនឹង យោ នាម ។

ចប់អដ្ឋកថា បឋមទុសីលយសូត្រទី ៦

# អ ដ្ឋ ក ថា

## ទុតិយទុសីលយសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយទុសីលយសូត្រទី ៧ ។*

*[២៧២] បទថា ភ័យខ្លាចសេចក្ដីស្លាប់ដែលនឹងមកដល់ខាងមុខ (សម្បរាយិកំ មរណភយំ) បានដល់ ខ្លាចសេចក្ដីស្លាប់ដែលនឹងមកដល់ក្នុងខាងមុខជាហេតុ ។*

*[២៧៤] បទថា សមគួរដល់គ្រហស្ថ (គហិសាមីចិកានិ) បានដល់ សមគួរដល់គ្រហស្ថ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានសេចក្ដីងាយយល់ទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ទុតិយទុសីលយសូត្រទី ៧

## ចប់សរកានិវគ្គទី ៣

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១អដ្ឋកថា បឋមមហានាមសូត្រ ២អដ្ឋកថា គោធាសូត្រ
៣អដ្ឋកថា បឋមសរកានិសូត្រ ៤អដ្ឋកថា ទុតិយសរកានិសូត្រ
៥ អដ្ឋកថា បឋមទុសីលយសូត្រ ៦អដ្ឋកថា ទុតិយទុសីលយសូត្រ

# បុញ្ញាភិសន្ទវគ្គទី ៤

## អ ដ្ឋ ក ថា

### បឋមអភិសន្ទសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអភិសន្ទសូត្រទី ១ ។*

*[២៨៥] បទថា អន្លង់បុណ្យ អន្លង់កុសល (បុញ្ញាភិសន្ទា កុសលាភិសន្ទា) បានដល់ ស្ទឹង គឺ បុណ្យ ស្ទឹង គឺ កុសល ។*

*បទថា នាំមកនូវសេចក្តីសុខ (សុខស្សាហារា) បានដល់ ជាបច្ច័យនៃសេចក្តីសុខ ។*

ចបអដ្ឋកថា បឋមអភិសន្ទសូត្រទី ១

# អ ដ្ឋ ក ថា

## បឋមទេវបទសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមទេវបទសូត្រទី ៤ ។*

*[២៨៨] បទថា **ទេវបទ** (ទេវបទានិ) បានដល់ វត្តបដិបត្តិដែលធ្វើដោយគោរព ដោយប្រាជ្ញារបស់ទេវតាទាំងឡាយ គឺ ដោយញាណរបស់ទេវ ។ បទថា **ដើម្បីសេចក្តីបរិសុទ្ធិ** (វិសុទ្ធិយា) គឺ ដើម្បីសេចក្តីបរិសុទ្ធិ ។ បទថា **ដើម្បីសេចក្តីផូរផង់** (បរិយោទបនាយ) គឺ ដើម្បីប្រយោជន៍ដល់សេចក្តីផូរផង់ គឺ ដើម្បីប្រយោជន៍ដ៏រុងរឿង ។ បុគ្គលដែលតាំងនៅក្នុងផលសម្បទាំង ៤ ឈ្មោះថា **ទេវ** ព្រោះអត្ថថា បរិសុទ្ធិ ក្នុងសូត្រនេះ ។*

ចប់អដ្ឋកថា បឋមទេវបទសូត្រទី ៤

# អ ដ្ឋ ក ថា

## ឧស្សុសូត្រទី ៨

[២៩១] គប្បីជ្រាបវិនិច្ឆ័យក្នុង *ឧស្សុសូត្រទី ៨* ។

[២៩៦] បទថា *ដល់ត្រើយ (បារំ គន្ត្វា)* គឺ និព្វាន លោកហៅថា ត្រើយ អធិប្បាយថាដល់ត្រើយនោះ ។

ក៏ក្នុងបទថា *ប្រព្រឹត្តទៅដើម្បីការអស់អាសវៈ (អាសវានំ ខយាយ សំវត្តន្តិ)* លោកធ្វើទេសនាទុកយ៉ាងនេះថា ដល់ព្រះនិព្វានមុនហើយ អាសវៈទើបអស់ជាខាងក្រោយមិនមែន កាលនឹងអស់ ក៏ប្រព្រឹត្តទៅព្រមគ្នា ។

ចប់អដ្ឋកថា ឧស្សុសូត្រទី ៨

# អ ដ្ឋ ក ថា

## នន្ទិយសូត្រទី ១០

[៣០០] គប្បីជ្រាបវិនិច្ឆ័យក្នុង នន្ទិយសូត្រទី ១០ ។

[៣០២] បទថា ដើម្បីសេចក្តីស្ងប់ស្ងាត់ក្នុងពេលថ្ងៃ ដើម្បីពួនសម្ងំក្នុងពេលយប់ (ទិវា បវិវេកាយ រត្តិយា បដិសល្លានាយ) សេចក្តីថា ស្ងាត់ពេលថ្ងៃ ពេលយប់ពួនសម្ងំ ។ បទថា ធម៌ទាំងឡាយរមែងមិនប្រាកដ (ធម្មា ន បាតុភវន្តិ) បានដល់ ធម៌ គឺ សមថៈ និងវិបស្សនា រមែងមិនកើតឡើង ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្តីងាយយល់ទាំងអស់ ។

ចប់អដ្ឋកថា នន្ទិយសូត្រទី ១០

## ចប់បុញ្ញាភិសន្ទវគ្គទី ៤

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១អដ្ឋកថា បឋមអភិសន្ទសូត្រ ២អដ្ឋកថា បឋមទេវបទសូត្រ
៣អដ្ឋកថា វស្សសូត្រ ៤អដ្ឋកថា នន្ទិយសូត្រ

# សគាថកបុញ្ញាភិសន្ទវគ្គទី ៥

## អ ដ្ឋ ក ថា

### អភិសន្ទសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអភិសន្ទសូត្រទី ១ ។*

*[៣០៥] បទថា **នឹងរាប់មិនបាន (អសង្ខេយ្យោ)** គឺ មិនអស់ ដោយការរាប់តាមស្លាក ។ ក៏ការរាប់គំនរបុណ្យនេះ រមែងមិនមានដោយអំណាចការប្រែកប ។*

*[៣០៧] ពាក្យថា **មានវត្ថុដែលគួរភ័យខ្លាចច្រើន (ពហុភេរវំ)** គឺ មានវត្ថុដែលគួរខ្លាចច្រើន ដោយអំណាចអារម្មណ៍ដែលគួរខ្លាច ទាំងដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ ។ ពាក្យថា **បុថូ** គឺ ច្រើន ។ ពាក្យថា **ហូរ (សវន្តី)** គឺ បង្ហូរហើយ ។ ពាក្យថា **ចូលទៅ (ឧបយន្តិ)** បានដល់ ចូល ទៅហើយ ។*

ចប់អដ្ឋកថា បឋមអភិសន្ទសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយអភិសន្ទសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអភិសន្ទសូត្រទី ២ ។*

[៣១០] *បទថា មហានទី រមែងហូរទៀយៗ ទៅ ត្រង់មាត់ទឹកណា (យត្ថិមា មហានទិយោ សំសន្ទន្តិ សមេន្តិ) សេចក្តីថា ទីប្រជុំរួមនៃទន្លេធំទាំងនេះរួមគ្នាតែមួយ មិនមានចន្លោះ ។*

ចប់អដ្ឋកថា ទុតិយអភិសន្ទសូត្រទី ២

# អ ដ្ឋ ក ថា

## តតិយអភិសន្ទសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយអភិសន្ទសូត្រទី ៣ ។

[៣១៤] បទថា អ្នកត្រូវការបុណ្យ (បុញ្ញកាមោ) គឺ អ្នកត្រូវការបុណ្យ ។ បទថា តាំងស៊ប់ក្នុងកុសល (កុសលេ បតិដ្ឋិតោ) គឺ អ្នកតាំងនៅក្នុងមគ្គដែលជាកុសល ។ បទថា ចម្រើនមគ្គដើម្បីសម្រេចអមតធម៌ (ភាវេតិ មគ្គំ អមតស្ស បត្តិយា) គឺ ចម្រើនអរហត្តមគ្គ ដើម្បីសម្រេចនិព្វាន ។ ក្នុងបទថា អ្នកសម្រេចធម៌ដែលជាសារៈ (ធម្មសារាធិគមោ) មានវិគ្រោះថា ធម៌ដែលជាសារៈ គឺ អរិយផល លោកហៅថា ធម៌ដែលមានសារៈ ការសម្រេចធម៌ដែលជាសារៈរបស់បុគ្គលនោះ មានហើយ ហេតុនោះ បុគ្គលនោះ ឈ្មោះថា អ្នកសម្រេចធម៌ដែលជាសារៈ អធិប្បាយថា អ្នកសម្រេចផល ។ បទថា ត្រេកអរក្នុងធម៌ជាទីអស់ទៅ (ខយេ រតោ) គឺ ត្រេកអរក្នុងការអស់កិលេស ។

ចប់អដ្ឋកថា តតិយសន្ទសូត្រទី ៣

# អ ដ្ឋ ក ថា

## បឋមមហទ្ធនសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមហទ្ធនសូត្រទី ៤ ។*

*[៣១៥] បទថា ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន (អឌ្ឍោ មហទ្ធនោ) គឺ អ្នកស្តុកស្តម្ភ និងមានទ្រព្យច្រើន ដោយអរិយទ្រព្យ ៧ យ៉ាង ។ អ្នកមានភោគៈច្រើនដោយភោគៈនោះឯង ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់នោះឯង ។*

ចប់អដ្ឋកថា បឋមមហទ្ធនសូត្រទី ៤

## ចប់សគាថកបុញ្ញាភិសន្ទវគ្គទី ៥

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា បឋមអភិសន្ទសូត្រ ២ អដ្ឋកថា ទុតិយអភិសន្ទសូត្រ
៣ អដ្ឋកថា តតិយអភិសន្ទសូត្រ ៤ អដ្ឋកថា បឋមមហទ្ធនសូត្រ

# សប្បញ្ញវគ្គទី ៦

## អ ដ្ឋ ក ថា

### វស្សវុត្ថសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង វស្សវុត្ថសូត្រទី ២ ។

[៣២២] បទថា ភិក្ខុដែលជាព្រះសោតាបន្ន មិនដល់នូវការដាក់ចុះដោយហេតុប៉ុណ្ណោះ ប្រជុំអង្គនៃការត្រាស់ដឹង គឺ ឥន្ទ្រិយ និងពលៈ ចម្រើនវិបស្សនា ក៏នឹងសម្រេចព្រះសកទាគាមិមគ្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដៅយកសេចក្ដីនេះថា សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ ហើយត្រាស់វង្សនៃប្រពៃណីក្នុងព្រះសាសនា ក្នុងព្រះសូត្រនេះ ។

ចប់អដ្ឋកថា វស្សវុត្ថសូត្រទី ២

# អ ដ្ឋ ក ថា

## ធម្មទិន្នសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ធម្មទិន្នសូត្រទី ៣ ។*

*[៣២៦] បទថា **ធម្មទិន្នៈ (ធម្មទិន្នោ)** សេចក្តីថា ជាឧបាសកម្នាក់ ក្នុងបណ្តាឧបាសក ៧ នាក់ ។ សេចក្តីពិស្តារថា ក្នុងសម័យពុទ្ធកាល បុគ្គល ៧ នាក់នេះ គឺ ធម្មទិន្នឧបាសក ១ វិសាខឧបាសក ១ ឧគ្គគហបតី ១ ចិត្តគហបតី ១ ហត្ថកអាឡវកៈ ១ ចូឡអនាថបិណ្ឌិកៈ ១ មហាអនាថបិណ្ឌិកៈ ១ ជាអ្នកមានឧបាសក ៥០០ ជាបរិវារ ។ ធម្មទិន្នឧបាសក ជាបុគ្គលម្នាក់ក្នុងបណ្តាបុគ្គលទាំង ៧ នាក់នោះ ។ បទថា **ជ្រាលជ្រៅ (គម្ភីរា)** បានដល់ មានធម៌ដ៏ជ្រាលជ្រៅ មានសល្លសូត្រជាដើម ។ បទថា **មានអត្ថដ៏ជ្រៅ (គម្ភីរត្ថា)** បានដល់ មានអត្ថដ៏ជ្រៅ មានចេតនាសូត្រជាដើម ។ បទថា **ជាលោកុត្តរៈ (លោកុត្តរា)** សេចក្តីថា ដែលសម្តែងអត្ថ ដែលជាលោកុត្តរៈ មានអសង្ខតសំយុត្តជាដើម ។ បទថា **ប្រកបដោយសុញ្ញតៈ (សុញ្ញតប្បដិសំយុត្តា)** សេចក្តីថា ដែលសម្តែងសភាពសូន្យនៃសត្វ មានខជ្ជនិកសូត្រជាដើម ។ បទថា **នឹងចូលដល់ហើយ (ឧបស-***

សម្បជ្ជ វិហរិស្សាម) សេចក្តីថា នឹងបានចំពោះហើយ ។ បទថា ម្នាល ធម្មទិន្នៈ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះ (ឯវំ ហិ វោ ធម្មទិន្ន សិក្ខិ-តព្វំ) សេចក្តីថា អ្នកទាំងឡាយគប្បីបំពេញចន្ទោបមបដិបទា រថវិនីតបដិបទា មោនេយ្យបដិបទា មហាអរិយវង្សបដិបទា សិក្សាហើយ យ៉ាងនេះ ។

ព្រះសាស្តាទ្រង់ប្រាប់ការៈដែលមិនអាចទ្រាំបាន ដល់ឧបាសកទាំងនេះ ដោយប្រការដូច្នេះ ។ ព្រោះហេតុអ្វី? បានឮថា ឧបាសកទាំងនោះតាំងនៅក្នុងភូមិរបស់ខ្លួនហើយ ទូលសូមឱវាទ ។ ក៏ឧបាសកទាំងនោះ ដូចជាលើកការៈទាំងពួងឡើង ដោយមិនផ្សេងគ្នា អង្វរថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ឱវាទដល់ពួកខ្ញុំព្រះអង្គចុះ" ដូច្នេះ ។ ព្រោះហេតុនោះ ព្រះសាស្តាកាលនឹងត្រាស់ប្រាប់ការៈដែលអត់ទ្រាំមិនបាន ដល់ពួកឧបាសកទាំងនោះ ទើបត្រាស់ហើយយ៉ាងនេះ ។

[៣២៧] បទថា **ន ខោ បនេតំ** បានដល់ **ន ខោ ឯតំ** ប្រែថា នុ៎ះឯងក៏មិនមែន ។ ក៏ **ន** អក្សរ ក្នុងបទថា **ន ខោនេតំ** នោះ គប្បីជ្រាបថា មានត្រឹមតែព្យញ្ជនៈ សន្ធិប៉ុណ្ណោះ ។ បទថា **ព្រោះហេតុនោះ (តស្មា)** សេចក្តីថា ព្រោះហេតុនោះ ឥឡូវនេះ អ្នកទាំងឡាយគប្បីសូមឱវាទក្នុងភូមិរបស់ខ្លួនចុះ ។

ចប់អដ្ឋកថា ធម្មទិន្នសូត្រទី ៣

# អ ដ្ឋ ក ថា

## គិលាយនសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង គិលាយនសូត្រទី ៤ ។

[៣២៨] បទថា *រឿងនេះខ្ញុំព្រះអង្គនៅមិនទាន់ (ន ខោ បនេតំ)* សេចក្ដីថា ខ្ញុំព្រះអង្គនៅមិនទាន់បាន (ស្ដាប់) រឿងនេះឡើយ ។ ព្រះសោតាបន្ន ព្រះដ៏មានព្រះភាគទ្រង់បំណាងថា *ឧបាសកអ្នកមានបញ្ញា (សប្បញ្ញោ ឧបាសកោ)* ។

[៣២៩] បទថា *ដោយធម៌ ជាទីតាំងនៃសេចក្ដីស្រាលចិត្ត (អស្សាសនីយេហិ ធម្មេហិ)* សេចក្ដីថា ដោយធម៌ទាំងឡាយដែលធ្វើនូវសេចក្ដីធូរស្រាលចិត្ត ។ បទថា *អ្នកចូរដកដង្ហើមឲ្យស្រួលចុះ (អស្សាសតាយស្មា)* បានដល់ អ្នកចូរធូរស្បើយក្នុងចិត្ត ។

[៣៣០] បទថា *លោកដូចគ្នានឹងយើង (មារិសោ)* បានដល់ អ្នកជាប់ជំពាក់ដោយសេចក្ដីស្លាប់ ។ បទថា *មានសេចក្ដីស្លាប់ជាធម្មតា (មរណធម្មោ)* បានដល់ ទៀងតែនឹងស្លាប់ ។

[៣៣២] បទថា *សូមចូរបង្អោន (អធិមោចេហិ)* បានដល់ សូមចូរ

កំណត់ ។ បទថា **បង្អោនទៅ (អធិមោចិតំ)** បានដល់ កំណត់ហើយ ។

[៣៣៤] បទថា **អ្នកមានចិត្តរួចផុតហើយយ៉ាងនេះ (ឯវំ វិមុត្តចិត្តស្ស)** សេចក្ដីថា អ្នកដែលមានចិត្តរួចផុតហើយ ដោយការរួចផុត គឺ អរហត្តផល យ៉ាងនេះ ។ បទថា **រួចផុតដោយវិមុត្តិដូចគ្នា (យទិទំ វិមុត្តិយា វិមុត្តំ)** សេចក្ដីថា យើងមិនគប្បីពោលដល់ការធ្វើផ្សេងៗ គ្នានោះ នៃវិមុត្តិ ប្រារព្ធចិត្តដែលរួចផុតហើយនេះ ។ ដែលឈ្មោះថា ប្រមាណក្នុងគុណជាទីមក គឺ ក្នុងវត្តត្រង់លានព្រះចេតិយ និងលានពោធិព្រឹក្ស និងក្នុងវត្ត ៨០ ខន្ធកៈ របស់ភិក្ខុសង្ឃ រមែងមិនមាន ។ ក៏កាលចាក់ធ្លុះមគ្គ ឬផល ឧបាសក និងភិក្ខុទាំងឡាយ រមែងមិនមានហេតុធ្វើឲ្យផ្សេងគ្នាឡើយ ។

ចប់អដ្ឋកថា គិលាយនសូត្រទី ៤

# អ ដ្ឋ ក ថា

## បដិលាភសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង បដិលាភសូត្រទី ៩ ។

[៣៣៩] ក្នុងបទថា *រមែងប្រព្រឹត្តទៅដើម្បីបានចំពោះនូវបញ្ញា (សប្បញ្ញាបដិលាភាយ សំវត្តន្តិ)* នេះ ព្រះសេក្ខបុគ្គល ៧ ពួក គប្បីជ្រាបថា ឈ្មោះថា អ្នកបានចំពោះនូវបញ្ញា , ព្រះខីណាស្រព ឈ្មោះថា អ្នកបាននូវបញ្ញាហើយ ។ សូម្បីក្នុងពាក្យជាដើមថា ដើម្បីសេចក្តីចម្រើននៃបញ្ញាខាងមុខ ក៏ន័យនេះឯង ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានន័យងាយទាំងនោះឯង ។

ចប់អដ្ឋកថា បដិលាភសូត្រទី៩

### ចប់សប្បញ្ញវគ្គទី ៦

### រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១អដ្ឋកថា វស្សវុត្ថសូត្រ ២អដ្ឋកថា ធម្មទិន្នសូត្រ
៣អដ្ឋកថា គិលាយនសូត្រ ៤អដ្ឋកថា បដិលាភសូត្រ

# មហាបញ្ញវគ្គទី ៧

## អ ដ្ឋ ក ថា

### មហាបញ្ញវគ្គទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង មហាបញ្ញវគ្គទី ៧ ។

គប្បីជ្រាបខ្លឹមសារគ្រប់បទ តាមន័យដែលពោលក្នុងបដិ-សម្ភិទា ដោយន័យជាដើមថា ឈ្មោះថា អ្នកមានបញ្ញាច្រើន ព្រោះអត្ថថា កំណត់យកក្នុងអត្ថច្រើន ។ ក្នុងបទជាដើមថា រមែងប្រព្រឹត្តទៅដើម្បីភាពជាអ្នកមានបញ្ញាច្រើន ដូច្នេះនោះឯង ។ ពាក្យដ៏សេសគ្រប់ៗ បទ ងាយយល់ទាំងនោះឯង ។

ចប់អដ្ឋកថា មហាបញ្ញវគ្គទី ៧

## ចប់សោតាបត្តិសំយុត្តទី ២

# សច្ចសំយុត្តទី ៤

## អ ដ្ឋ ក ថា

### សមាធិសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមាធិសូត្រទី ១ នៃអដ្ឋកថាសច្ចសំយុត្ត ។*

*[៣៥៥] បទថា ភិក្ខុទាំងឡាយ... សមាធិ (សមាធឹ ភិក្ខវេ) សេចក្ដីថា បានព្ធថា ភិក្ខុទាំងនោះ រមែងវិនាសចាកឯកគ្គតាចិត្ត (សមាធិ) ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ប្រារព្ធទេសនានេះ ដល់ភិក្ខុទាំងនោះថា ភិក្ខុទាំងនោះបានចិត្តដែលមានអារម្មណ៍ដ៏ប្រសើរតែមួយយ៉ាងនេះ ចម្រើនកម្មដ្ឋានហើយក៏នឹងសម្រេចគុណវិសេសបាន ។ គប្បីជ្រាបការកាត់ហេតុ ដោយអំណាចហេតុតាមពិតជាដើម ក្នុងបទនេះថា ម្នាលភិក្ខុទាំងឡាយ ព្រោះដូច្នោះឯងអ្នកទាំងឡាយ គប្បីធ្វើសេចក្ដីព្យាយាមថា នេះទុក្ខ (តស្មាតិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ) ។*

*ក៏មានពាក្យអធិប្បាយ ដែលព្រះដ៏មានព្រះភាគ ត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតាំងមាំ រមែងដឹងទូទៅដល់សច្ចៈ ៤*

តាមសេចក្តីពិត ព្រោះហេតុណា ព្រោះហេតុនោះ អ្នកទាំងឡាយមានចិត្តតាំងមាំ គប្បីធ្វើសេចក្តីព្យាយាមថា នេះទុក្ខ ដូច្នេះ ដើម្បីត្រូវការដឹងសច្ចៈ ៤ តាមសេចក្តីពិត ។ សច្ចៈ ៤ រមែងជាធម្មជាតិប្រាកដច្បាស់ដល់តថាគតនោះឯង ព្រះតថាគតទ្រង់ចែកទុកល្អហើយ ។ ក្នុងសច្ចៈទាំង ៤ នោះ ការពោលសរសើរមិនមានប្រមាណ បទ និងព្យញ្ជនៈ មិនមានប្រមាណ និងវដ្តៈរមែងចម្រើន ព្រោះសច្ចៈទាំង ៤ នោះ ដែលអ្នកទាំងឡាយមិនបានចាក់ធ្លុះ ផ្តើមពីកាលចាក់ធ្លុះសច្ចៈទាំង ៤ នោះ វដ្តៈក៏មិនចម្រើន ព្រោះហេតុណា ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាមថា នេះទុក្ខ ដូច្នេះ ដោយសន្និមថា វដ្តៈនឹងមិនចម្រើនយ៉ាងនេះ ។

ចប់អដ្ឋកថា សមាធិសូត្រទី ១

# អ ដ្ឋ ក ថា

## បដិសល្លានសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង បដិសល្លានសូត្រទី ២ ។*

*[៣៥៦] បទថា បដិសល្លានសូត្រទី ២ លោកពោលទុកហើយដើម្បីប្រយោជន៍ដល់ការបានចំពោះនូវសេចក្តីស្ងប់កាយ នៃភិក្ខុដែលមានសភាពមិនប្រក្រតីផ្លូវកាយវិវេក ។*

ចប់អដ្ឋកថា បដិសល្លានសូត្រទី ២

# អ ដ្ឋ ក ថា

## កុលបុត្រសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុលបុត្រសូត្រទី ៣ ។*

[៣៥៧] *បទថា* ***ដើម្បីដឹងដ៏ក្រៃលែង*** *(អភិសមយាយ) គឺ ដើម្បីប្រយោជន៍ដល់ការដឹងក្រៃលែង ។ ក៏ព្រះដ៏មានព្រះភាគទ្រង់បំណាងយកអ្នកប្រព្រឹត្តក្នុងព្រះសាសនា ក្នុងបទនេះថា* ***សមណៈ ឬព្រាហ្មណ៍*** *។*

ចប់អដ្ឋកថា បឋមកុលបុត្តសូត្រទី ៣

# អ ដ្ឋ ក ថា

## បឋមសមណព្រាហ្មណសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសមណព្រាហ្មណសូត្រទី ៥ ។*

*[៣៥៩] បទថា ក៏ព្រះដ៏មានព្រះភាគត្រាស់សច្ចៈទាំង ៤ នោះ តាមអធ្យាស្រ័យរបស់អ្នកត្រាស់ដឹង ក្នុងព្រះសូត្រទី ៤-៥ ដោយការត្រាស់នោះៗ ។*

ចប់អដ្ឋកថា បឋមសមណព្រាហ្មណសូត្រទី ៥

# អ ដ្ឋ ក ថា

## ទុតិយសមណព្រាហ្មណសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសមណព្រាហ្មណសូត្រទី ៦ ។*

*[៣៦០] បទថា ប្រកាសហើយដល់វត្ថុដែលខ្លួនដឹងហើយ (អភិសម្ពុទ្ធំ បកាសេសុំ) សេចក្តីថា ប្រកាសវត្ថុដែលខ្លួនដឹងចំពោះហើយ យ៉ាងនេះថា យើងជាអ្នកដឹងព្រមចំពោះហើយ ។ ក៏ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់កាន់យកព្រះសព្វញ្ញុតញ្ញាណទាំងឡាយ ដោយសមណៈសព្ទ ។*

ចប់អដ្ឋកថា ទុតិយសមណព្រាហ្មណសូត្រទី ៦

# អ ដ្ឋ ក ថា

## តិរច្ឆានកថាសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង តិរច្ឆានកថាសូត្រទី ១០ ។

[៣៦៤] បទថា ច្រើនយ៉ាង (អនេកវិហិតំ) បានដល់ មានច្រើនយ៉ាង ។ បទថា តិរច្ឆានកថា (តិរច្ឆានកថំ) គឺ ពាក្យដែលជាតិរច្ឆាន ក្រៅផ្លូវសួគ៌ និងនិព្វាន ព្រោះមិនជាការនាំ (សត្វ) ចេញចាកទុក្ខ ។ ក្នុងបទថា រឿងព្រះរាជា ដូច្នេះ ជាដើម ពាក្យដែលប្រារព្ធព្រះរាជាហើយ ប្រព្រឹត្តទៅដោយន័យជាដើមថា ព្រះបាទមហាសម្មត ព្រះបាទមន្ធាតុ ព្រះបាទធម្មាសោក មានអានុភាពច្រើនយ៉ាងនេះ ឈ្មោះថា រឿងព្រះរាជា ។ សូម្បីក្នុងរឿងចោរ ជាដើម ក៏ន័យនេះ ។ ក៏រឿងជាប់ជំពាក់អាស្រ័យផ្ទះ ដោយន័យជាដើមថា បណ្ដាព្រះរាជាទាំងនោះ ព្រះរាជាព្រះអង្គឯណោះ មានរូបល្អគួរមើល ឈ្មោះថា តិរច្ឆានកថា ។ ក៏ពាក្យដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា សូម្បីអ្នកមានឈ្មោះឯណោះ មានអានុភាពច្រើនយ៉ាងនេះ បានដល់ការអស់ទៅ វិនាសទៅហើយ ដូច្នេះ តាំងនៅក្នុងភាពជាកម្មដ្ឋាន ។ សូម្បីក្នុងពួកចោរ ការពោលពាក្យសម្ដែងសេចក្ដីពេញចិត្តអាស្រ័យផ្ទះថា ពាក្យ

ទាំងនោះ បានមានហើយ ព្រោះអាស្រ័យកម្មរបស់ពួកចោរនោះថា មូល-ទេព ជាអ្នកមានអានុភាពច្រើនយ៉ាងនេះ ឈ្មោះថា តិរច្ឆានកថា ។ ក្នុងការច្បាំង ពាក្យ (ដែលប្រព្រឹត្តទៅ) ដោយអំណាចសេចក្តីពេញចិត្ត និងសេចក្តីត្រេកអរថា បុគ្គលឯណោះ ត្រូវបុគ្គលឯណោះ សម្លាប់ហើយយ៉ាងនេះ ចាក់ហើយយ៉ាងនេះ ក្នុងការច្បាំងជាដើមនោះឯង ដូច្នេះ ឈ្មោះថា តិរច្ឆានកថា ។

ក៏ពាក្យដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា ដែលឈ្មោះថា សូម្បីបុគ្គលពួកនោះ ក៏ដល់ការអស់ទៅ ដូច្នេះ ចាត់ជាកម្មដ្ឋានក្នុងទីគ្រប់កន្លែងនោះឯង ។ មួយវិញទៀត សូម្បីក្នុង **រឿងបាយ** ជាដើម ការពោលដោយអំណាចសេចក្តីពេញចិត្ត និងសេចក្តីត្រេកអរថា ពួកយើងបានទំពារ បរិភោគអាហារ មានបាយជាដើម ដែលមានពណ៌ មានក្លិន ដល់ព្រមដោយរស និងផស្សៈ រមែងមិនគួរ ។ ចំណែកការពោលរឿងដែលមានប្រយោជន៍មុនថា ពួកយើងបានថ្វាយបាយ ទឹកផឹក សំពត់ យាន ទីដេក ផ្កាឈើ គ្រឿងក្រអូប គ្រឿងលាប ដែលដល់ព្រមដោយពណ៌ជាដើម ដល់អ្នកមានសីលទាំងឡាយ ពួកយើងបានធ្វើការបូជាទីចេតិយ ដូច្នេះ ក៏គួរ ។

សូម្បីក្នុង **រឿងញាតិ** ជាដើម ការពោលដោយអំណាចសេចក្តីត្រេកអរ

ថា "ញាតិទាំងឡាយរបស់ពួកយើង ជាអ្នកក្លាហាន" ឬថា "ពួកយើងទៅដោយយានដែលល្អយ៉ាងនេះ ក្នុងកាលមុន" ដូច្នេះ រមែងមិនគួរ ។

តែក៏គួរពោលពាក្យថា "ញាតិទាំងឡាយរបស់ពួកយើងទាំងនោះ ធ្វើវត្ថុមានប្រយោជន៍ហើយដល់នូវការអស់ទៅ" ឬថា "គ្រាមុន ពួកយើងបានថ្វាយយានមានសភាពបែបនេះដល់ព្រះសង្ឃ" ។ សូម្បីក្នុង **រឿងស្រុក** ជាដើម ការពោលដោយអំណាចស្រុក ដែលរស់នៅហើយល្អ រស់នៅមិនល្អ និងរកអាហារបានងាយ រកបានលំបាកជាដើម ឬដោយសេចក្តីត្រេកអរយ៉ាងនេះថា "អ្នកដែលរស់នៅស្រុកឯណោះក្លាហាន" ដូច្នេះ មិនគួរ ។ ចំណែកការពោលដល់រឿងស្រុកនោះថា "មនុស្សទាំងឡាយ ធ្វើវត្ថុឲ្យជាប្រយោជន៍ មានសទ្ធា ជ្រះថ្លាហើយ" ឬថា "មនុស្សទាំងនោះដល់ការអស់ទៅ វិនាសទៅ" ដូច្នេះ រមែងគួរ ។ សូម្បីក្នុងការពោល **រឿងនិគម រឿងនគរ** និង **រឿងជនបទ** ក៏ន័យនេះ ។

សូម្បីការពោល **រឿងស្ត្រី** អាស្រ័យពណ៌សម្បុរ និងទ្រង់ទ្រាយជាដើម មិនគួរពោលដោយអំណាចសេចក្តីពេញចិត្តជាដើម ។ ការពោលយ៉ាងនេះថា "មនុស្សទាំងនេះ មានសទ្ធាជ្រះថ្លា ហើយដល់ការអស់ទៅ" ដូច្នេះឯង ក៏គួរ ។ សូម្បីការពោល **រឿងអ្នកក្លាហាន** មិនគួរពោលដោយ

អំណាចសេចក្ដីពេញចិត្តថា "អ្នកចម្បាំង ឈ្មោះថា នន្ទមិតជាអ្នកក្លាហាន" ។ ការពោលយ៉ាងនេះថា "បុគ្គលនេះមានសទ្ធា ជ្រះថ្លាហើយ ដល់ការអស់ទៅ" ដូច្នេះឯង ក៏គួរ ។ បាឋៈថា **សូរកថា** ដូច្នេះខ្វះ ការពោលដល់អ្នកក្លាហានសូម្បីនោះ រមែងមិនគួរ ដោយអំណាចសេចក្ដីពេញចិត្តថា "ដែលឈ្មោះថា ស្ត្រីបែបនេះ ជាអ្នកមានបិតាឈ្មោះថា សូរៈ មានមាតាឈ្មោះថា បូតី" ដូច្នេះនោះឯង ។ ចំណែកការពោលដោយអំណាចទោសន៊ុះឯងរមែងគួរ ដោយន័យជាដើមថា អ្នកប្រព្រឹត្តវត្តរបស់មនុស្សក្លួត ។

សូម្បីការពោល **រឿងប្រកផ្លូវ** រមែងមិនគួរ ព្រោះការពោលដោយអំណាចសេចក្ដីពេញចិត្តថា "ប្រកផ្លូវឯណោះ ធ្វើទុកល្អហើយ" ឬថា ពួកអ្នកដែលនៅប្រកផ្លូវឯណោះក្លៀវក្លា មានសេចក្ដីអង់អាច" ដូច្នេះ ។ ការពោលយ៉ាងនេះថា "ពួកគេជាអ្នកសទ្ធាជ្រះថ្លា ហើយដល់នូវការអស់ទៅ" ដូច្នេះ ក៏គួរ ។ ក្នុងពាក្យថា **រឿងកំពង់ទឹក** ពាក្យពោលដោយរឿងដែលតាំងផ្ទាំង លោកហៅថា "ពាក្យពោលក្នុងរឿងកំពង់ទឹក" ឬពោលពាក្យថា "រឿងនាងទាសីដងទឹកដោយខ្ពម" ។ ការពោលដោយអំណាចសេចក្ដីពេញចិត្តថា "សូម្បីនាងជាអ្នកគួរស្រឡាញ់ ឆ្លាតក្នុងរបាំរាំច្រៀង" ដូច្នេះមិនគួរ ។ ការពោលដោយន័យជាដើមថា "មានសទ្ធា ជ្រះថ្លាហើយ" ដូច្នេះ ក៏គួរ ។

ពាក្យថា **រឿងអ្នកដែលស្លាប់ទៅហើយ (បុព្វេបេតកថា)** បានដល់ រឿងញាតិដែលស្លាប់ទៅហើយ ។ ការវិនិច្ឆ័យក្នុងរឿងញាតិដែលស្លាប់ទៅហើយនោះ ក៏ដូចគ្នានឹងរឿងញាតិដែលនៅមានជីវិតនៅទុំះឯង ។

ពាក្យថា **រឿងរាយរាយ (នានត្តកថា)** បានដល់ រឿងដែលរកប្រយោជន៍មិនបាន ផុតអំពីរឿងកើតមុន និងក្រោយ ជារឿងមានសភាពផ្សេងៗ ។

ពាក្យថា **រឿងលោក (លោកក្ខាយិកា)** គឺ ការពោលលេងៗ ពោលអំពីរឿងលោកជាដើម យ៉ាងនេះថា "លោកនេះនរណាសាង បុគ្គលឈ្មោះឯណោះសាង ក្អែកស ព្រោះមានឆ្អឹងស សត្វក្រៀលក្រហម ព្រោះមានឈាមក្រហម" ។ ការពោល រឿងសមុទ្រ ដែលមិនមានប្រយោជន៍ជាដើម យ៉ាងនេះថា ព្រោះហេតុអ្វី សមុទ្រទើបឈ្មោះថា សាគរ សមុទ្រឈ្មោះថា សាគរ ព្រោះដឹងបានដោយចុងម្រាមដៃថា សមុទ្រនេះយើងជីកហើយ ឈ្មោះថា **រឿងសមុទ្រ** ។ ការពោលក្នុងរឿងដែលមិនមានប្រយោជន៍ជាទូទៅថា "ចម្រើន វិនាស" ហើយពោលរឿងដែលប្រព្រឹត្តទៅ ឈ្មោះថា **ពោលរឿងចម្រើន និងវិនាស** ។ ក៏ក្នុងរឿងពោលអំពីសេចក្តីចម្រើន និងសេចក្តីវិនាសនេះ សភាពដែលទៀង ឈ្មោះថា សេចក្តីចម្រើន , សភាព

ដាច់សូន្យ ឈ្មោះថា សេចក្តីវិនាស ។ ការវិវឌ្ឍន៍ ឈ្មោះថា សេចក្តីចម្រើន ហាយនៈភាព ឈ្មោះថា សេចក្តីវិនាស ។ កាមសុខ ឈ្មោះថា សេចក្តីចម្រើន ការធ្វើខ្លួនឲ្យលំបាក ឈ្មោះថា សេចក្តីវិនាស ។ រួមមក សេចក្តីចម្រើន និងសេចក្តីវិនាស ដោយប្រការនោះៗ ៦ យ៉ាងនេះ ទើបជា **ការពោលរឿងតិរច្ឆាន ៣២** ដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងនោះឯង ។

ចប់អដ្ឋកថា តិរច្ឆានកថាសូត្រទី ១០

## ចប់សមាធិវគ្គទី ១

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ


១អដ្ឋកថា សមាធិសូត្រ ២អដ្ឋកថា បដិសល្លានសូត្រ
៣អដ្ឋកថា បឋមកុលបុត្តសូត្រ ៤អដ្ឋកថា បឋមសមណ...សូត្រ
៥អដ្ឋកថា ទុតិយសមណ...សូត្រ ៦អដ្ឋកថា តិរច្ឆានកថាសូត្រ

# ធម្មចក្កប្បវត្តនវគ្គទី ២

## អ ដ្ឋ ក ថា

### បឋមតថាគតសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមតថាគតសូត្រទី ១** ។*

[៣៦៥] *បទថា **ជិតក្រុងពារាណសី (ពារាណសិយំ)** បានដល់ ជិតព្រះនគរដែលមានឈ្មោះយ៉ាងនេះ ។ ពាក្យថា **ឥសិបតនមិគទាយវ័ន (ឥសិ-បតនេ មិគទាយេ)** បានដល់ ក្នុងព្រៃដែលបានឈ្មោះយ៉ាងនេះ ដោយអំណាចជាទីធ្លាក់ចុះ និងឡើង (ភ្នំ) នៃពួកឥសី ។ ក្នុងអាភាម ពោលគឺ ព្រៃដែលឈ្មោះថា មិគទាយៈ ព្រោះឲ្យអភ័យដល់ម្រឹគទាំងឡាយ ដោយអំណាចការឲ្យអភ័យ ។ អធិប្បាយថា ក៏ឥសីទាំងឡាយដែលជាសព្វញ្ញូ កើតឡើងហើយៗ រមែងទៅអង្គុយក្នុងព្រៃនោះ ដើម្បីឲ្យធម្មចក្កប្រព្រឹត្តទៅ ។ សូម្បីឥសីដែលជាព្រះបច្ចេកពុទ្ធទាំងឡាយ កន្លងទៅ ៧ ថ្ងៃ ចេញចាកនិរោធ-សមាបត្តិ ធ្វើកិច្ចមានការលុបព្រះភក្ត្រជាដើម ត្រង់អនោតត្តស្រះ មកតាមអាកាសពីញកភ្នំឈ្មោះថា នន្ទមូលកៈ ហើយធ្លាក់ចុះទៅដោយអំណាចការ*

ចុះត្រង់ព្រៃនោះ រមែងប្រជុំគ្នាធ្វើឧបោសថ និងអនុឧបោសថ បំណាច់ទៅ ក្នុងគន្ធមាទន៍ខ្លះ និងហោះមកពីក្នុងគន្ធមាទន៍នោះខ្លះ ដោយពាក្យតាមដែលពោលមកហើយនេះឯង ព្រៃនោះលោកទើបហៅថា "ឥសិបតនៈ" ព្រោះជាទីហោះចុះ និងហោះឡើងនៃឥសីទាំងឡាយ ។

បទថា ត្រាស់ហៅ (អាមន្តេសិ) សេចក្តីថា បំពេញបារមីតាំងពីធ្វើអភិនិហារជិតព្រះបាទរបស់ព្រះពុទ្ធទីបង្ករ និងស្តេចចេញសាងព្រះផ្នួសក្នុងព្រះជាតិចុងក្រោយដោយលំដាប់ ប្រថាប់អង្គុយលើអបរាជិតបល្ល័ង្កត្រង់ព្រៃនោះ ទ្រង់កម្ចាត់មារ និងសេនាមារ ។ បឋមយាម ទ្រង់រឭកដល់បុព្វេនិវាសានុស្សតិញ្ញាណ មជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុឲ្យបរិសុទ្ធិ បច្ឆិម-យាមចុងក្រោយ ទ្រង់ញុំាងម៉ឺនលោកធាតុឲ្យគឹកកងញាប់ញ័រហើយ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ហើយទ្រង់ញុំាងកាលវេលាឲ្យកន្លងទៅ ៧ សប្តាហ៍ ត្រង់បរិវេណគល់ឈើពោធិព្រឹក្ស មានការសម្តែងធម៌ដែលស្តេចមហាព្រហ្មអារាធនាហើយ ទ្រង់ពិចារណាមើលលោកដោយពុទ្ធចក្ខុ ហើយស្តេចទៅក្រុងពារាណសី ដើម្បីសង្គ្រោះសត្វលោក ទ្រង់ឲ្យព្រះបញ្ចវគ្គិយត្រេកអរហើយ ទ្រង់ប្រាថ្នានឹងប្រកាសធម្មចក្រ ទើបត្រាស់ហៅមក ។

បទថា ម្នាលភិក្ខុទាំងឡាយ ចំណែកបំផុត ២ យ៉ាងនេះ (ទ្វេមេ

**ភិក្ខវេ អន្តា)** សេចក្តីថា ភិក្ខុទាំងឡាយ ចំណែកលាមក ២ ទាំងនេះ ។ ក៏ព្រមនឹងការត្រាស់ដល់បទនេះ សម្លេងគឹកកងនៃការត្រាស់ ខាងក្រោមតាំងពីអវិចី ខាងលើទល់ដល់ភវគ្គព្រហ្ម ផ្សាយទៅទូទាំងម៉ឺនលោកធាតុតាំងនៅ ។ សម័យនោះឯង ព្រហ្មរាប់បាន ១៨ កោដិ មកប្រជុំគ្នាហើយ ។ ព្រះអាទិត្យលិចទៅកាន់ទិសខាងលិច ព្រះចន្ទពេញវង់ ប្រកបដោយពួកផ្កាយនក្សត្រនៃខែអាសាឡ្ហៈ អណ្តែតឡើងឯទិសខាងកើត ។ សម័យនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ផ្តើមធម្មចក្កប្បវត្តនសូត្រនេះ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ ចំណែកបំផុត ២ យ៉ាងនេះ ។

បណ្តាបទទាំងនោះ បទថា **ដែលបព្វជិត (បព្វជិតេន)** សេចក្តីថា អ្នកកាត់សញ្ញោជនៈនៃគ្រហស្ថហើយ ចូលដល់ការបួស ។

បទថា **មិនគួរសេព (ន សេវិតព្វា)** គឺ មិនគប្បីប្រព្រឹត្ត ។ បទថា **ការប្រកបខ្លួនឲ្យជាប់ជំពាក់ដោយកាមសុខ ក្នុងកាមទាំងឡាយ (យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគ)** សេចក្តីថា ការតាមប្រកបកាមសុខក្នុងវត្ថុកាម កិលេសកាម ។ បទថា **ជារបស់ថោកទាប (ហីនោ)** បានដល់លាមក ។ បទថា **ជារបស់អ្នកស្រុក (គម្មោ)** គឺ ជារបស់មាននៅនៃអ្នកស្រុកទាំងឡាយ ។ បទថា **ជារបស់បុថុជ្ជន (បោថុជ្ជនិកោ)** បានដល់ ដែល

បុគ្គលអន្ធពាលប្រព្រឹត្តរឿយៗ ហើយ ។ បទថា **មិនប្រសើរ (អនរិយោ)** បានដល់ មិនបរិសុទ្ធិ គឺ មិនមែនរបស់ប្រសើរបំផុត ម្យ៉ាងទៀត មិនមែនរបស់ព្រះអរិយទាំងឡាយ ។ បទថា **មិនប្រកបដោយប្រយោជន៍ (អនត្ថសញ្ហិតោ)** គឺ រកប្រយោជន៍មិនបាន អធិប្បាយថា មិនអាស្រ័យហេតុដែលនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យ ។

បទថា **ការប្រកបសេចក្តីលំបាកដល់ខ្លួន (អត្តកិលមថានុយោគោ)** គឺ ការតាមប្រកបសេចក្តីលំបាកឲ្យខ្លួន អធិប្បាយថា ធ្វើទុក្ខដល់ខ្លួន ។ បទថា **ជាទុក្ខ (ទុក្ខោ)** បានដល់ នាំទុក្ខមកឲ្យដោយការសម្លាប់ខ្លួន មានការដេកផ្ការលើបន្លាជាដើម ។ ព្រះអង្គទ្រង់ធ្វើចក្ខុ គឺ បញ្ញា ព្រោះដូច្នោះទើបឈ្មោះថា **ធ្វើចក្ខុ (ចក្ខុករណី)** ។ បទទី ២ ជាវេវចនៈរបស់បទនោះឯង ។ បទថា **ដើម្បីសេចក្តីស្ងប់ (ឧបសមាយ)** គឺ ដើម្បីប្រយោជន៍ដល់ការស្ងប់កិលេស ។ បទថា **ដើម្បីសេចក្តីដឹងក្រៃលែង (អភិញ្ញាយ)** គឺ ដើម្បីប្រយោជន៍ដល់ការដឹងក្រៃលែងចំពោះសច្ចៈទាំង ៤ ។ បទថា **ដើម្បីសេចក្តីត្រាស់ដឹង (សម្ពោធាយ)** បានដល់ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងសច្ចៈទាំង ៤ នោះឯង ។ បទថា **ដើម្បីនិព្វាន (និព្វានាយ)** បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ក្នុងបទនេះ ពាក្យ

ណាដែលសល់ ជារបស់គប្បីពោលទុក ពាក្យនោះ លោកពោលទុកក្នុងបទនោះៗ ក្នុងខាងក្រោយ ។ សួម្បីសច្ចកថា លោកក៏ឲ្យពិស្តារហើយក្នុងបករណ៍វិសេសវិសុទ្ធិមគ្គ ដោយប្រការទាំងពួងនុ៎ះឯង ។

[៣៧១] បទថា **វិលជុំវិញ ៣ (តិបរិវដ្ដំ)** គឺ វិលជុំវិញ ៣ ជុំ ដោយអំណាចវិលជុំវិញ ៣ ជុំ ពោលគឺ សច្ចញាណ កិច្ចញាណ និងកតញាណ ។ ក៏ក្នុងវិលជុំវិញ ៣ នេះ ញាណតាមសេចក្ដីពិតក្នុងសច្ចៈ ៤ យ៉ាងនេះ គឺ នេះទុក្ខអរិយសច្ចៈ នេះទុក្ខសមុទ័យ ឈ្មោះថា **សច្ចញាណ** ។ ញាណ ដែលជាគ្រឿងដឹងកិច្ចដែលគួរធ្វើ យ៉ាងនេះថា គួរកំណត់ដឹង គួរលះក្នុងសច្ចៈទាំងនោះឯង ឈ្មោះថា **កិច្ចញាណ** ។ ញាណជាគ្រឿងដឹងការៈនៃកិច្ចនោះ ដែលធ្វើហើយយ៉ាងនេះថា កំណត់ដឹងហើយ លះបានហើយដូច្នេះ ឈ្មោះថា **កតញាណ** ។ បទថា **មានអាការ ១២ (ទ្វាទសាការំ)** សេចក្ដីថា មានអាការ ១២ គឺ មានអាការសច្ចៈមួយៗ ៣ ។ បទថា **ញាណទស្សនៈ (ញាណទស្សនំ)** គឺ ការឃើញ ពោលគឺ ញាណដែលកើតឡើងហើយ ដោយអំណាចវិលជុំវិញ ៣ យ៉ាង អាការ ១២ យ៉ាងទាំងនេះ ។

[៣៧២] បទថា **ភ្នែកឃើញធម៌ (ធម្មចក្ខុំ)** បានដល់ មគ្គ ៣ និងផល ៣ ។ ក្នុងទីដទៃ ឈ្មោះថា ជាធម្មចក្ខុ ។ ក្នុងបទនេះ បានដល់ បឋមមគ្គ

តែម្យ៉ាង ។

បទថា **ធម្មចក្រ (ធម្មចក្កំ)** បានដល់ ញាណជាគ្រឿងចាក់ធ្លុះ និង ញាណជាគ្រឿងសម្តែង ។ ក៏កាលព្រះដ៏មានព្រះភាគប្រថាប់គង់លើពោធិ-បល្ល័ង្ក បដិវេធញ្ញាណ មានអាការ ១២ កើតឡើងហើយក្នុងសច្ចៈ ៤ ក្តី ប្រថាប់គង់សួម្បីក្នុងព្រៃឥសិបតនៈ ទេសនាញាណដែលប្រព្រឹត្តទៅហើយ ដើម្បីសម្តែងសច្ចៈ មានអាការ ១២ ក្តី ឈ្មោះថា **ធម្មចក្ក** ។ ក៏ញាណសូម្បីទាំងពីរនោះ ឈ្មោះថា ញាណដែលប្រព្រឹត្តទៅហើយក្នុងព្រះឱរៈនៃព្រះទសពលនោះឯង ។ ធម្មចក្រនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រកាសដោយទេសនានេះ ឈ្មោះថា ទ្រង់ឲ្យប្រព្រឹត្តទៅហើយ ។ ក៏ធម្មចក្រនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រព្រឹត្តទៅ ដរាបដល់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ និងព្រហ្ម ១៨ កោដិ តាំងនៅក្នុងសោតាបត្តិផល និងកាលឲ្យធម្មចក្រប្រព្រឹត្តទៅហើយ ទើបឈ្មោះថា ឲ្យប្រព្រឹត្តទៅហើយ ។ ក៏កាលព្រះដ៏មានព្រះ-ភាគ ទ្រង់ឲ្យធម្មចក្រប្រព្រឹត្តទៅហើយ លោកសំដៅយកពាក្យនោះ ទើបពោលពាក្យជាដើមថា ភុម្មទេវតាទាំងឡាយ ប្រកាសឲ្យបានឮសំឡេង ។

បណ្តាបទទាំងនោះ បទថា **ភុម្មទេវតា (ភុម្មា)** បានដល់ ទេវតាដែលតាំងនៅលើផែនដី ។ បទថា **ប្រកាសឲ្យបានឮសំឡេង (សទ្ទមនុ-**

*សហ្មវេសុំ)* សេចក្តីថា ទេវតាទាំងឡាយឲ្យសាធុការព្រមៗ គ្នា ពោលពាក្យជាដើមថា នោះធម្មចក្រដ៏កំពូល ដែលព្រះដ៏មានព្រះភាគ... ដូច្នេះ ប្រកាសឲ្យបានឮហើយ ។

[៣៧៣] បទថា *ពន្ទឺ (ឧភាសោ)* បានដល់ ពន្ទឺ គឺ ព្រះសព្វញ្ញុតញ្ញាណ ។ ពិតណាស់ ពន្ទឺ គឺ ព្រះសព្វញ្ញុតញ្ញាណនោះ រុងរោចន៍កន្លងទេវានុភាពរបស់ពួកទេវតា ។

[៣៧៤] បទថា *កោណ្ឌញ្ញៈបានដឹងហើយហ្ន៎ (អញ្ញាសិ វត ភោ កោណ្ឌញ្ញោ)* សេចក្តីថា សំឡេងគឹកកងយ៉ាងឧឡារ នៃព្រះឧទាននេះ ផ្សាយទៅរហូតមុឺនលោកធាតុហើយតាំងនៅ ។

ចប់អដ្ឋកថា បឋមតថាគតសូត្រទី ១

# អ ដ្ឋ ក ថា

## សង្កាសនសូត្រទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុង សង្កាសនសូត្រទី ៩ ។

[៣៩៧] បទថា *អក្ខរៈរកប្រមាណមិនបាន (អបរិមាណា វណ្ណា)* បាន ដល់ អក្ខរៈមិនមានប្រមាណ ។ បទថា *ព្យញ្ជនៈ (ព្យញ្ជនា)* ដូច្នេះ ជាវេវចនៈរបស់ពាក្យថា អក្ខរៈរកប្រមាណមិនបានទាំងនោះ ។

ម្យ៉ាងទៀត ឯកទេសមួយនៃអក្ខរៈ ក៏គឺ ឈ្មោះថា ព្យញ្ជនៈ ។ បទថា *ការថៃក (សង្កាសនា)* គឺ ការថៃក ។ ពិតហើយ កាលសច្ចៈមួយៗ លោកសម្តែងឲ្យពិស្តារហើយ ដោយអាការទាំងពួង អក្ខរៈជាដើមក៏ឈ្មោះថា មិនមានទីបំផុត ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគទើបត្រាស់ហើយយ៉ាងនេះ ។

ចប់អដ្ឋកថា សង្កាសនសូត្រទី៩

# អ ដ្ឋ ក ថា

## តថសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង តថសូត្រទី ១០ ។

[៣៩៨] បទថា តំទុក្ខ ឈ្មោះថា ជារបស់ពិត ព្រោះអត្ថថា មានហើយដោយភាវៈរបស់ខ្លួន ។ ព្រោះថា ទុក្ខ លោកហៅថាទុក្ខនុ៎ះឯង ។ ឈ្មោះថា មិនប្រែប្រួល ព្រោះសភាវៈមិនទទេ ។ ព្រោះថា ទុក្ខ ឈ្មោះថា មិនមែនទុក្ខមិនមាន ។ ឈ្មោះថា មិនជាយ៉ាងដទៃ ព្រោះមិនចូលដល់សភាវៈដទៃ ។ តំទុក្ខ ចូលដល់ការពោលក្នុងទុក្ខសមុទ័យជាដើមមិនបាន ។ សូម្បីក្នុងសមុទ័យជាដើម តំន័យនេះឯង ។

ចប់អដ្ឋកថា តថសូត្រទី ១០

## ចប់ធម្មចក្កប្បវត្តនវគ្គទី ២

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១អដ្ឋកថា បឋមតថាគតសូត្រ ២អដ្ឋកថា សង្កាសនសូត្រ
៣អដ្ឋកថា តថសូត្រ

# កោដិគាមវគ្គទី ៣

## អ ដ្ឋ ក ថា

### វជ្ជីសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង វជ្ជីសូត្រទី ១ ។*

*[៣៩៩] បទថា ព្រោះមិនបានត្រាស់ដឹង (អននុពោធា) បានដល់ ព្រោះមិនត្រាស់ដឹងតាម ។ បទថា មិនបានចាក់ធ្លុះ (អប្បដិវេធា) គឺ ព្រោះ មិនមានការចាក់ធ្លុះ ។*

ចប់អដ្ឋកថា វជ្ជីសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយវជ្ជីសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយវជ្ជីសូត្រទី ២ ។*

[៤០៣] *បទថា ចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ជាឈ្មោះនៃផលសមាបត្តិ និងផលបញ្ញា ។*

ចប់អដ្ឋកថា ទុតិយវជ្ជីសូត្រទី ២

# អ ដ្ឋ ក ថា

## តថសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង តថសូត្រទី ៧ ។*

[៤០៨] *បទថា ព្រោះដូច្នោះ...អរិយសច្ចៈ (តស្មា អរិយានំ សច្ចានិ)*[១] *សេចក្ដីថា សច្ចៈទាំងឡាយនោះ ជារបស់ពិត មិនប្រែប្រួល មិនមានដោយប្រការដទៃ ព្រោះហេតុណា ព្រោះហេតុនោះ លោកទើបហៅថា "សច្ចៈរបស់ព្រះអរិយៈទាំងឡាយ" ។ ក៏ព្រះអរិយៈទាំងឡាយ រមែងមិនចាក់ធ្លុះសច្ចៈទាំងឡាយដែលប្រែប្រួលជាយ៉ាងដទៃ ដោយសេចក្ដីពិត ជារបស់ព្រះអរិយៈ ។*

ចប់អដ្ឋកថា តថសូត្រទី ៧

---

*១ បាលីបិដក តស្មា អរិយសច្ចានីតិ វុច្ចតិ ។*

# អ ដ្ឋ ក ថា

## លោកសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង លោកសូត្រទី ៨ ។*

[៤០៩] *បទថា តថាគតជាអរិយៈ... ព្រោះដូច្នោះ ទើបហៅថា អរិយសច្ចៈ (តថាគតោ អរិយោ តស្មា អរិយសច្ចានិ) សេចក្តីថា អរិយសច្ចៈទាំងឡាយនោះ ឈ្មោះថា ជារបស់ព្រះអរិយៈ ។ ព្រោះព្រះតថាគត ជាព្រះអរិយៈ ទ្រង់ចាក់ធ្លុះ និងសម្តែងហើយ ព្រោះហេតុណា ព្រោះហេតុនោះ ទើបឈ្មោះថា អរិយសច្ចៈ ព្រោះជាសេចក្តីពិតរបស់ព្រះអរិយៈ ។*

ចប់អដ្ឋកថា លោកសូត្រទី ៨

# អ ដ្ឋ ក ថា

## គវម្បតិសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង គវម្បតិសូត្រទី ១០ ។*

*[៤១១] បទថា **សហជនិយ:** (សហជនិយេ) បានដល់ ក្នុងព្រះនគរដែលមានឈ្មោះថា សហជនិយ: ។ បទជាដើមថា "ម្នាលភិក្ខុទាំងឡាយ ក៏នរណា រមែងឃើញទុក្ខ អ្នកនោះឈ្មោះថា រមែងឃើញសមុទ្ទ័យ" ដូច្នេះ ព្រះដ៏មានព្រះភាគត្រាស់ហើយ ដោយអំណាចការចាក់ធ្លុះតែម្យ៉ាង ។ ក៏ក្នុងព្រះសូត្រនេះ ទ្រង់ត្រាស់ការចាក់ធ្លុះតែម្យ៉ាងប៉ុណ្ណោះ ។*

ចប់អដ្ឋកថា គវម្បតិសូត្រទី ១០

## ចប់កោដិគាមវគ្គទី ៣

## រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

១ អដ្ឋកថា បឋមវជ្ជីសូត្រ
២ អដ្ឋកថា ទុតិយវជ្ជីសូត្រ
៣ អដ្ឋកថា តថសូត្រ
៤ អដ្ឋកថា តថាគតសូត្រ
៥ អដ្ឋកថា តថសូត្រ
៦ អដ្ឋកថា លោកសូត្រ
៧ អដ្ឋកថា គវម្បតិសូត្រ

# សីសបាបណ្ណវគ្គទី ៤

## អ ដ្ឋ ក ថា

## សីសបាសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីសបាសូត្រទី ១ ។*

[៤១៣] *បទថា ស្លឹកដែលនៅឯដើម (យទិទំ ឧបរិ) គឺ ស្លឹកធ្នង់ទាំងនេះ ដែលនៅនឹងដើមធ្នង ។*

*បទថា ក្នុងព្រៃដើមធ្នង (សីសបាវនេ) បានដល់ លើដើមធ្នង់ទាំងឡាយ ។*

ចប់អដ្ឋកថា សីសបាសូត្រទី ១

# អ ដ្ឋ ក ថា

## ខទិរសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង ខទិរសូត្រទី ២ ។*

*[៤១៥] បទថា មិនបានត្រាស់ដឹងហើយ (អនភិសមេច្ច) សេចក្តីថា មិនសម្រេច និងមិនចាក់ធ្លុះដោយញាណ ។*

ចប់អដ្ឋកថា ខទិរសូត្រទី ២

# អ ដ្ឋ ក ថា

## ឧណ្ហសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧណ្ហសូត្រទី ៣ ។

[៤១៧] បទថា ចាកលោកនេះទៅកាន់បរលោក (អស្មា លោកា បរំ លោកំ) សេចក្តីថា ចាកពីលោកនេះទៅលោកដទៃ គឺ នរកខ្លះ កំណើតសត្វតិរច្ឆានខ្លះ បិត្តិវិស័យខ្លះ មនុស្សលោកខ្លះ ទេវលោកខ្លះ អធិប្បាយថា កើតក្នុងវដ្តៈទុំៈឯងរឿយៗ ។

ចប់អដ្ឋកថា ឧណ្ហសូត្រទី ៣

# អ ដ្ឋ ក ថា

## សត្តិសតសុត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង សត្តិសតសូត្រទី ៥ ។*

[៤១៩] *បទថា ភិក្ខុទាំងឡាយ ប្រការនេះគប្បីមានដូច្នោះ (ឯវំ ពេ្ចតំ ភិក្ខវេ អស្ស) សេចក្តីថា ភិក្ខុទាំងឡាយ បើហេតុនេះ គប្បីមានយ៉ាងនេះ សោត កាលទុក្ខទោមនស្សត្រូវកម្ចាត់អស់ទៅ ក៏នឹងគប្បីសម្រេចសច្ចៈនោះ ព្រមគ្នានោះឯង ។*

ចប់អដ្ឋកថា សត្តិសតសុត្រទី ៥

# អ ដ្ឋ ក ថា

## ឥន្ទខីលសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥន្ទខីលសូត្រទី ៩ ។*

[៤១៣] *បទថា រមែងត្រូវសម្លឹងមើលមុខ (មុខំ ឱលោកេន្តិ) បាន ដល់ ត្រូវតមើលអធ្យាស្រ័យ ។ អធ្យាស្រ័យ ព្រះដ៏មានព្រះភាគ ទ្រង់ បំណាងយកក្នុងពាក្យថា មុខ ក្នុងបទនេះ ។*

ចប់អដ្ឋកថា ឥន្ទខីលសូត្រទី ៩

# អ ដ្ឋ ក ថា

## វាទីសូត្រទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុង វាទីសូត្រទី ១០ ។

[៤២៥] បទថា *សិលាយូបោ* បានដល់ សសរថ្ម ។ បទថា *សោឡសកុក្កុកោ* ប្រែថា ១៦ ហត្ថ ។ បាលីថា *សោឡសកុក្កុ* ប្រែថា ១៦ ហត្ថ ក៏មាន ។ បទថា *មានឫសជ្រៅទៅខាងក្រោម (ហេដ្ឋានេមង្គមា)* សេចក្តីថា ចូលទៅកាន់រណ្តៅខាងក្រោម ។ បទថា *ខាងលើ ៨ ហត្ថ (អដ្ឋកុក្កុឧបរិនេមស្សា)* គឺ ខ្ពស់ផុតរណ្តៅ ៨ ហត្ថ ។ បទថា *យ៉ាងខ្ជាំង (កុសា)* បានដល់ មានកម្លាំង ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់នោះឯង ។

ចប់អដ្ឋកថា វាទីសូត្រទី ១០

### ចប់សីសបាបណ្ណវគ្គទី ៤

### រួមអដ្ឋកថាក្នុងវគ្គនេះ គឺ

| | |
|---|---|
| ១ អដ្ឋកថា សីសបាសូត្រ | ២ អដ្ឋកថា ខទិរសូត្រ |
| ៣ អដ្ឋកថា ទណ្ឌសូត្រ | ៤ អដ្ឋកថា សត្តិសតសូត្រ |
| ៥ អដ្ឋកថា ឥន្ទខីលសូត្រ | ៦ អដ្ឋកថា វាទីសូត្រ |

# បបាតវគ្គទី ៥

## អ ដ្ឋ ក ថា

### ចិន្តសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង ចិន្តសូត្រទី ១ ។

[៤២៦] បទថា *ស្រះបោក្ខរណី ឈ្មោះថា សុមាគធា (សុមាគធាយ បោក្ខរណិយា)* បានដល់ ស្រះបោក្ខរណីដែលមានឈ្មោះយ៉ាងនេះ ។ បទថា **គិតរឿងលោក** *(លោកចិន្តំ ចិន្តេន្តោ)* សេចក្ដីថា អង្គុយគិតរឿងលោកយ៉ាងនេះថា នរណាហ្ន៎ សាងព្រះចន្ទ ព្រះអាទិត្យ នរណាសាងផែនដីធំ នរណាសាងមហាសមុទ្រ នរណាសាងសត្វជាឱបបាតិកៈ នរណាសាងភ្នំ នរណាបង្កើតដើមស្វាយ ដើមត្នោត និងដើមដូងជាដើម ។ បទថា **មានចិត្តរាយមាយ** *(វិចេតោ)* បានដល់ ជាអ្នកមានចិត្តផ្សាយទៅ ឬថា មានចិត្តគិតទៅ ។ បទថា **បានឃើញវត្ថុដែលមិនពិត** *(ភូតំ យេវ អទ្ទស)* សេចក្ដីថា បានឮថា ពួកអសុរនោះញ៉ាំងសម្ពរិមាយា (មាយារបស់ស្ដេចអសុរ) ឲ្យប្រព្រឹត្តទៅ ហើយអធិដ្ឋាន ដោយប្រការដែលបុរសនោះ ឃើញពួកគេ

នោះ អ្នកឡើងលើដំរី និងសេះជាដើម ហើយលោតចូលទៅតាមចន្លោះក្រឪឈូក ព្រះសាស្តាទ្រង់សំដៅយកអសុរនោះ ទើបត្រាស់ថា "បានឃើញវត្ថុដែលពិតហើយនោះឯង" ។

[៤២៧] បទថា *ញ៉ាំងចិត្តរបស់ពួកទេវតាឲ្យវង្វេង (ទេវានំ យេវ មោហយមានា)* គឺ ញ៉ាំងចិត្តរបស់ពួកទេវតាឲ្យភ័ន្តច្រឡំហើយ ។ បទថា *ព្រោះហេតុនោះ (តស្មា)* សេចក្តីថា ព្រោះកាលបើគិតរឿងលោក ក៏នឹងជាអ្នកឆ្កួត ។

ចប់អដ្ឋកថា ចិន្តសូត្រទី ១

# អ ដ្ឋ ក ថា

## បបាតសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង បបាតសូត្រទី ២ ។*

[៤២៩] *បទថា កំពូលភ្នំជាព្រំវ័ណ្ឌ (បដិភាណកូដោ) សេចក្តីថា ជាព្រំវ័ណ្ឌ ដូចជាភ្នំធំមួយ ។*

ចប់អដ្ឋកថា បបាតសូត្រទី ២

# អ ដ្ឋ ក ថា

## បរិឡាហសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិឡាហសូត្រទី ៣ ។*

*[៤៣២] បទថា រូបដែលមិនគួរប្រាថ្នា (អនិដ្ឋរូបំ) បានដល់ សភាវៈ ដែលមិនគួរប្រាថ្នា ។*

ចប់អដ្ឋកថា បរិឡាហសូត្រទី ៣

# អ ដ្ឋ ក ថា

## កូដសូត្រទី ៤

*គប្បីជ្រាបវិនិច្ឆ័យក្នុង កូដសូត្រទី ៤ ។*

[៤៣៦] *បទថា មិនបាច់ធ្វើផ្ទះជាន់ក្រោម (ហេដ្ឋិមំ ឃរំ អករិត្វា) សេចក្តីថា មិនធ្វើចំណែកជាន់ក្រោមរបស់ផ្ទះ ដោយគ្រឿងឈើជាដើម នៃសសរ និងជញ្ជាំង (គឺ មិនបាច់ធ្វើគ្រឿងក្រោម ធ្វើតែគ្រឿងលើ) ។*

ចប់អដ្ឋកថា កូដសូត្រទី ៤

# អ ដ្ឋ ក ថា

## វាលសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង វាលសូត្រទី ៥ ។

[៤៣៨] បទថា សណ្ឋាគារ (សណ្ឋាគារេ) បានដល់ ក្នុងសាលាសម្រាប់រៀនសិល្បៈ ។ បទថា កំពុងធ្វើការបាញ់ព្រួញ (ឧបាសនំ ករោន្តេ) បានដល់ ហ្វឹកហាត់សិល្បៈ គឺ ការបាញ់ព្រួញ ។ បទថា មិនខុស (អសនំ អតិបាតេន្តេ) បានដល់ មិនបាញ់កូនសរឲ្យខុសឡើយ ។ បទថា ជាប់ៗ គ្នា (បោខានុបោក្ខំ) សេចក្ដីថា ព្រះថេរៈបានឃើញ រាជកុមារលិច្ឆវីទាំងឡាយ ដែលបាញ់កូនសរកូនមួយឲ្យចូលទៅជាប់ៗ គ្នា យ៉ាងនេះ គឺ កូនសរដទៃ រមែងជ្រែកកូនសរដែលជាប់រោមសត្វត្រង់ចុងនៃកូនសរនោះយ៉ាងណា ដែលឈ្មោះថា កូនសរដែលជាប់រោមសត្វត្រង់ចុងកូនសរដទៃរមែងជ្រែកកូនសរ ដែលមានរោមសត្វជាប់ចុងកូនសររបស់កូនសរទី ២ ទៀត កូនសរដែលជាប់ចុងរោមសត្វដែលបាញ់មកដទៃទៀត ក៏រមែងជ្រែកកូនសរដែលជាប់ចុងដោយរោមសត្វកូនសរដទៃ របស់កូនសរនោះទៀត ដូច្នោះ ។ បទថា យត្រ ហិ នាម កាត់បទជា យេ ហិ នាម ប្រែថា ក៏ឈ្មោះថា ពួក

ពួកណា ។ បទថា ឲ្យកើតឡើងបានលំបាកជាងគ្នា (ទុរភិសម្ភវតរំ) គឺធ្វើបានលំបាកជាង ។

បទថា បំបែកចុងរោមទ្រាយ ដោយចុងរោមទ្រាយ ដែលបែងចេញហើយជា ៧ ចំណែក (សត្តធា ភិន្នស្ស វាលស្ស កោដិយា កោដឹ បដិវិជ្ឈេយ្យ) សេចក្តីថា គប្បីបែងរោមទ្រាយមួយសរសៃជា ៧ ចំណែក ហើយកាន់យកមួយចំណែកដែលបែងអំពីរោមទ្រាយនោះ ហើយចងកណ្តាលផ្លែត្រប់ ចងរោមទ្រាយសរសៃដទៃដែលបែងហើយទៀត ត្រង់ខាងចុងកូនសរ ហើយឈរត្រង់ផ្លូវប្រមាណមួយឧសភៈ បាញ់ ចំពោះចុងរោមទ្រាយដែលចងនឹងផ្លែត្រប់នោះ ដោយចុងដែលចងទុកត្រង់កូនសរ ។ ពាក្យថា ព្រោះហេតុនោះ (តស្មា) សេចក្តីថា ព្រោះសច្ចៈ ៤ ចាក់ធ្លុះបានលំបាកយ៉ាងនេះ ។

ចប់អដ្ឋកថា វាលសូត្រទី ៥

# អ ដ្ឋ ក ថា

## បឋមឆិគ្គឡសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង *បឋមឆិគ្គឡសូត្រទី ៧* ។

[៤៤៤] បទថា **មានតែការទំពារស៊ីគ្នានិងគ្នា** (អញ្ញមញ្ញខាទិកា) បានដល់ ការទំពារស៊ីដល់គ្នានិងគ្នា ។ ពាក្យថា **ការទំពារស៊ីអ្នកមានកម្លាំងតិច** (ទុព្វលខាទិកា) បានដល់ ត្រីជាដើម ដែលមានកម្លាំងទំពារស៊ីត្រីជាដើម ដែលកម្លាំងតិចជាង ។

ចប់អដ្ឋកថា បឋមឆិគ្គឡសូត្រទី ៧

# អ ដ្ឋ ក ថា

## ទុតិយច្ឆិគ្គឡសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយច្ឆិគ្គឡសូត្រទី ៨ ។*

[៤៤៥] *បទថា* ***ផែនដីធំ (មហាបឋវី)*** *បានដល់ផែនដីធំចន្លោះចក្រវាឡ ។ បទថា* ***ជារបស់លំបាកក្រៃលែង (អធិច្ចមិទំ)*** *សេចក្តីថា ប្រសិនបើពោលថា ទឹមនោះមិនគប្បីស្អុយ ទឹកក្នុងសមុទ្រមិនរីងស្ងួត និងអណ្តើកនោះមិនស្លាប់ ការកើតឡើងដោយសេចក្តីលំបាកក្រៃលែងនេះ ក៏គប្បីមានដោយអំណាចតាមសេចក្តីប្រាថ្នាបានខ្លះ ។ ក្នុងបទថា* ***ភិក្ខុទាំងឡាយ ការបានភាពជាមនុស្ស ជារបស់លំបាកក្រៃលែងយ៉ាងនេះ (ឯវំ អធិច្ចមិទំ ភិក្ខវេ)*** *នេះ ព្រះមហាសីវត្ថេរ បានសម្តែងដល់វត្ថុឯកទាំង ៤ ។ ការបានភាពជាមនុស្ស ឈ្មោះថា បានដោយលំបាកក្រៃលែង ដូចអណ្តើកខ្វាក់នោះ ស៊ក.កចូលទៅក្នុងចន្លោះទឹម ដែលបុរសឈរនៅលើកណ្តាប់ចក្រវាលនាទិសខាងកើត បោះទម្លាក់ទៅ ។*

*ការកើតឡើងនៃព្រះតថាគត ឈ្មោះថា ជាហេតុឲ្យដល់ត្រើយ ក៏លំបាកក្រៃលែង ដូចជាអណ្តើកខ្វាក់ស៊ក.កចូលចន្លោះទឹម ដែលបុរសឈរ*

ត្រង់កណ្តាប់ចក្រវាឡនាទិសខាងត្បូង បោះទម្លាក់ទៅហើយ វិលវល់រឿយៗ សូម្បីនឹមជាដំបូងហើយ ចំណែកត្រួតចន្លោះនិងចន្លោះ ។

ក៏ការសម្តែងធម្ម និងវិន័យ ដែលព្រះតថាគតទ្រង់ប្រកាសហើយ ឈ្មោះថា ជាហេតុកើតឡើងដ៏លំបាកក្រៃលែង ដូចអណ្តើកខ្វាក់ស៊ក.ក ចូលក្នុងចន្លោះនឹម ដែលបុរសឈរត្រង់កណ្តាប់ចក្រវាឡ នាទិសខាងលិច បោះទម្លាក់ទៅហើយ វិលវល់ទៅដោយជុំវិញ សូម្បីនឹមទី ២ ក៏មានន័យដូចមុន ចំណែកការត្រួតចន្លោះនិងចន្លោះ ។

ក៏ការចាក់ធ្លុះសច្ចៈ ៤ គប្បីជ្រាបថា ជាហេតុកើតឡើងបានលំបាកក្រៃលែងជាង ដូចអណ្តើកខ្វាក់ស៊ក.កចូលក្នុងចន្លោះនឹម ដែលបុរសឈរត្រង់កណ្តាប់ចក្រវាឡនាទិសខាងជើង ទម្លាក់ទៅហើយវិលវល់ដោយជុំវិញ សូម្បីនឹមទី ៣ ក៏មានន័យដូចមុនៗ ចំណែកត្រួតចន្លោះនិងចន្លោះ ។

សូត្រទី ៩ ជាដើម មានន័យតាមដូចពោលហើយក្នុងអភិសមយ-សំយុត្តនោះឯង ។

ចប់អដ្ឋកថា ឆិគ្គឡសូត្រទី ៨

**ចប់បបាតវគ្គទី ៥**

**រួមអដ្ឋកថាក្នុងវគ្គនេះ គឺ**

១ អដ្ឋកថា ចិន្តសូត្រ
២ អដ្ឋកថា បបាតសូត្រ
៣ អដ្ឋកថា បរិឡាហសូត្រ
៤ អដ្ឋកថា កូដសូត្រ
៥ អដ្ឋកថា វាលសូត្រ
៦ អដ្ឋកថា បឋមឆិគ្គឡសូត្រ
៧ អដ្ឋកថា ទុតិយឆិគ្គឡសូត្រ

# អភិសមយវគ្គទី ៦

## អ ដ្ឋ ក ថា

### អភិសមយវគ្គទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង អភិសមយវគ្គទី ៦ ។*

[៤៤៨] *បទថា អភិសមយវគ្គ លោកពោលពិស្តារហើយក្នុង អភិ-សមយសំយុត្ត ក្នុងនិទានវគ្គនោះឯង ។*

ចប់អដ្ឋកថា អភិសមយវគ្គទី៦

# អាមកធញ្ញបេយ្យាលវគ្គ[១]

## អ ដ្ឋ ក ថា

### អាមាកធញ្ញបេយ្យាលវគ្គ

[៤៥៨] គប្បីជ្រាបវិនិច្ឆ័យក្នុង *អាមាកធញ្ញបេយ្យាលវគ្គ* ។

[៤៦០] បទថា *សត្វដែលប្រកបដោយបញ្ញាចក្ខុ ដែលជាអរិយៈ* (អរិយេន បន ញាណចក្ខុនា) សេចក្តីថា បុគ្គលអ្នកមានបញ្ញាចក្ខុ ដែលជាលោកិយៈ និងលោកុត្តរៈ ផ្តើមតាំងពីវិបស្សនា ។

[៤៦១] ក្នុងបទថា *អ្នកវៀរ ចាកចាកការផឹកទឹកស្រវឹង គឺ សុរា និងមេរ័យ ដែលជាដែលតាំងនៃសេចក្តីប្រមាទ* (សុរាមេរយមជ្ជប្បមាទដ្ឋា-នា បដិវិរតា) នេះ មានអធិប្បាយថា ដែលឈ្មោះថា សុរា មាន ៥ យ៉ាង គឺ សុរាធ្វើដោយម្សៅ ១ សុរាធ្វើដោយបាយ ១ សុរាដោយធ្វើនំ ១ សុរាដែលដាក់ដោយមេ ១ សុរាប្រកបដោយគ្រឿងផ្សំ ១ ។ ទឹកត្រាំយ៉ាងណាមួយ លោកពោលទុកយ៉ាងនេះថា ទឹកត្រាំផ្កាឈើ ទឹកត្រាំផ្លែឈើ ឈ្មោះ

---

១ អាមកធញ្ញបេយ្យាលវគ្គទី ៧-៨-៩-១០ អដ្ឋកថាកែរួមគ្នាតែម្តង ។

ថា **មេរ័យ** ។ បទថា **ទឹកស្រវឹង (មជ្ជំ)** បានដល់ សុរា និងមេរ័យទាំងពីរ ។ មយ៉ាងទៀត ទឹកស្រវឹងប្រភេទណា សូម្បីដទៃដែលផ្សេងពីសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីស្រវឹង ។ មនុស្សទាំងឡាយ រមែងផឹកសុរា និងមេរ័យនោះ ដោយចេតនាណា ចេតនានោះ ឈ្មោះថា **ជាឋានៈនៃសេចក្តីប្រមាទ** ព្រោះជាហេតុនៃសេចក្តីប្រមាទ ជាអ្នកវៀរហើយចាកការផឹកសុរា និងមេរ័យនោះ ។

[៤៦៣] បទថា **អ្នកប្រតិបត្តិដល់មាតា (មេត្តេយ្យា)** គឺ អ្នកធ្វើប្រយោជន៍ដល់មាតា អធិប្បាយថា អ្នកបដិបត្តិល្អចំពោះមាតា ។

[៤៦៤] គប្បីជ្រាបអធិប្បាយក្នុងពាក្យជាដើមថា **អ្នកប្រតិបត្តិដល់បិតា (បេត្តេយ្យា)** ។ អ្នកធ្វើប្រយោជន៍ចំពោះបិតា ឈ្មោះថា **បេត្តេយ្យៈ** ។

[៤៦៥] អ្នកដែលធ្វើប្រយោជន៍ចំពោះសមណៈទាំងឡាយ ឈ្មោះថា **សាមញ្ញៈ** ។

[៤៦៦] អ្នកដែលធ្វើប្រយោជន៍ចំពោះព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា **ព្រាហ្មញ្ញតា** ។

បទថា **បេត្តេយ្យៈ** ជាដើមនេះ ជាឈ្មោះនៃអ្នកបដិបត្តិល្អចំពោះបិតាជាដើមទាំងនោះៗ ឯង ។

[៤៦៧] ពាក្យថា **អ្នកប្រព្រឹត្តកោតក្រែងចំពោះបុគ្គលជាធំក្នុងត្រកូល (កុលេជេដ្ឋាបចាយិនោ)** សេចក្តីថា អ្នកប្រព្រឹត្តកោតក្រែង គឺ ជាអ្នកមានប្រក្រតីប្រព្រឹត្តបន្ទាបខ្លួនចំពោះបុគ្គលជាធំក្នុងត្រកូល ។

[៤៧៥] បទថា **វៀរចាកការការញាំងពីជគ្រាម និងភូតគាម (ពីជគាមភូតគាមសមារម្ភា)** សេចក្តីថា ជាអ្នកវៀរចាកការញាំងពីជគាម ៥ យ៉ាងឲ្យកម្រើក គឺ ពូជកើតពីឫស ពូជកើតពីដើម ពូជកើតពីថ្នាំង ពូជកើតពីត្រួយ ពូជកើតពីគ្រាប់ និងភូតគាមណាមួយ មានស្មៅ និងដើមឈើជាដើម វៀរចាកការវិកប្បដោយការៈ មានការកាត់ និងដុតជាដើម ។

[៤៧៦] បទថា **ជាអ្នកវៀរចាកការបរិភោគអាហារក្នុងវេលាវិកាល (វិកាលភោជនា បដិវិរតា)** គឺ (វៀរ) ចាកការបរិភោគច្រើនពេល អធិប្បាយថា វៀរចាកការបរិភោគរបស់ដែលជាយាវកាលិក តាំងពីវេលាថ្ងៃជ្រេទៅ ។

[៤៧៧] គប្បីជ្រាបអធិប្បាយក្នុងផ្កាឈើជាដើម ។ បទថា **ផ្កាឈើ (មាលា)** បានដល់ ផ្កាឈើយ៉ាងណាមួយ ។ ពាក្យថា **របស់ក្រអូប (គន្ធំ)** បានដល់ គន្ធជាតិយ៉ាងណាមួយ ។ ពាក្យថា **គ្រឿងលម្អសម្បុរ (វិលេបនំ)** បានដល់ គ្រឿងលាបជាដើម ។ ក្នុងពាក្យទាំងនោះ ឈ្មោះថា **សៀត** ឬពាក់

ព្រោះអត្ថថា ប្រដាប់ហើយ ។ អ្នកញុំាងឋានៈដែលខ្វះខាតឲ្យពេញ ឈ្មោះថា **ប្រដាប់ហើយ** ។ អ្នកត្រេកអរដោយគ្រឿងក្រអូប និងគ្រឿងលាប ឈ្មោះថា **តុបតែង** ។ អធិប្បាយថា ហេតុ លោកហៅថា ឋានៈ ។ ព្រោះដូច្នោះ មហាជនធ្វើការសៀតផ្កាឈើជាដើមទាំងនោះ ដោយចេតនានៃភាពជាអ្នកទ្រុស្តសីលណា ហើយវៀរចាកចេតនានោះ ។

[៤៧៨] ការឃើញវត្ថុដែលឈ្មោះថា ជាសត្រូវ គឺ ជាសត្រូវ ព្រោះមិនអនុលោមតាមពាក្យទូន្មាន ព្រោះហេតុនោះ ទើបឈ្មោះថា ឃើញវត្ថុដែលជាសត្រូវ ។ ការរាំ ការរេញ ការប្រគំ ដោយខ្លួនឯង ដោយអំណាចការរាំ និងការឲ្យអ្នកដទៃរាំជាដើម និងការមើលនូវការរាំជាដើម ដែលប្រព្រឹត្តទៅហើយ ទីបំផុត សូម្បីដោយអំណាចការរាំរបស់សត្វក្ងោកជាដើមដែលជាសត្រូវ ព្រោះហេតុនោះ ទើបឈ្មោះថា ការមើលរបាំ រាំ ច្រៀង និងប្រគំតន្ត្រីដែលជាសត្រូវ ។ ក៏ការរាំជាដើមដោយខ្លួនឯងក្តី ការឲ្យអ្នកដទៃរាំជាដើមក្តី ការមើលរបាំដែលគេប្រកបក្តី រមែងមិនគួរដល់ភិក្ខុ និងភិក្ខុនី ។

[៤៧៩] ទីដេកដ៏ខ្ពស់ហួសប្រមាណ លោកហៅថា **ទីដេកខ្ពស់** ។ កម្រាលដែលមិនសមគួរឈ្មោះថា **ទីដេកធំ** ។ អធិប្បាយថា អ្នកវៀរចាក

ទីដេកដែលខ្ពស់ និងទីដេកធំ ។

[៤៨០] ពាក្យថា *មាស (ជាតរូប)* គឺ មាស ។ ពាក្យថា *ប្រាក់ (រជតំ)* បានដល់ កហាបណៈ ។ បុគ្គលពួកណា សូម្បីពោលថា "មាសកលោហៈ មាសកជ័រ" បុគ្គលទាំងនោះ ជាអ្នកវៀរចាកការទទួលមាស និងប្រាក់សូម្បីទាំងពីរនោះ រមែងមិនទទួលមាស និងប្រាក់នោះ មិនឲ្យអ្នកដទៃទទួល អធិប្បាយថា រមែងមិនកាន់យក (មិនត្រេកអរ) មាស និងប្រាក់ដែលរក្សាទុកហើយ ។

[៤៨១] ពាក្យថា *វៀរចាកការទទួលធញ្ញជាតិស្រស់ (អាមកធញ្ញ-បដិគ្គណា)* សេចក្តីថា វៀរចាកការទទួលធញ្ញជាតិស្រស់សូម្បី ៧ ប្រភេទ គឺ ស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ស្រងែ ថ្កៅ ស្កួយ និងស្មៅគែលលក ។ ក៏ការទទួលធញ្ញជាតិឆៅទាំងនោះ មិនគួរតែម្យ៉ាងប៉ុណ្ណោះក៏ទេ សូម្បីការប៉ះពាល់ ក៏មិនគួរដល់ភិក្ខុទាំងឡាយដូចគ្នា ។

[៤៨២] ក្នុងពាក្យថា *វៀរចាកការទទួលសាច់ឆៅ (អាមកមំស-ប្បដិគ្គហណា)* សេចក្តីថា ការទទួលសាច់ និងត្រីឆៅ មិនគួរដល់ភិក្ខុទាំងនោះ សូម្បីការប៉ះពាល់ក៏មិនគួរ វៀរតែសាច់ និងត្រីដែលទ្រង់អនុញ្ញាតទុកដោយចំពោះ ។

[៤៨៣] ក្នុងបទថា **វៀរចាកការទទួលស្ត្រី និងកុមារី (ឥត្ថីកុមារិក-បដិគ្គហណា)** នោះ ស្ត្រីដែលទៅក្នុងចន្លោះបុរស (សង្គមជាមួយបុរស) ឈ្មោះថា ស្ត្រី ស្ត្រីក្រៅពីនេះ ឈ្មោះថា កុមារី ។ ការទទួលស្ត្រី និងកុមារីទាំងនោះក្តី ការពាល់ត្រូវក្តី មិនគួរទាំងអស់ ។

[៤៨៤] ក្នុងបទថា **វៀរចាកការទទួលទាសី និងទាសៈនេះ (ទាសី-ទាសបដិគ្គហណា)** ការទទួលស្ត្រី និងបុរសទាំងនោះ ជាទាសី និងទាសៈក៏មិនគួរ ។ ក៏កាលគេពោលថា "ខ្ញុំសូមថ្វាយកប្បិយការកៈ ខ្ញុំសូមថ្វាយញោមវត្ត" ការទទួលនោះ រមែងគួរ ។

[៤៨៥-៤៨៨] ន័យដែលសមគួរ និងមិនសមគួរ ក្នុងវត្ថុមានពពែ និងចៀមជាដើម មានស្រែ និងចំការជាទីបំផុត ក៏គប្បីពិចារណាដោយអំណាចវិន័យ ។ បុព្វណ្ណៈ (គឺធញ្ញជាតិ) រមែងដុះក្នុងទីណា ទីនោះ ឈ្មោះថា ស្រែ ។ អបរណ្ណជាតិ (គឺសណ្តែក និងល្ង) រមែងដុះក្នុងទីណា ទីនោះ ឈ្មោះថា ចំការ ។ ម្យ៉ាងទៀត បុព្វណ្ណៈ និងអបរណ្ណជាតិទាំងពីរនោះ ដុះក្នុងទីណា ទីនោះ ឈ្មោះថា ឈ្មោះថា ស្រែ ។ ឈ្មោះថា ចំការ ព្រោះជាភូមិភាគដែលមិនបានធ្វើទុក ដើម្បីត្រូវការបុព្វណ្ណៈ និងអបរណ្ណជាតិនោះ ។ ក៏ក្នុងបទនេះ សូម្បីស្រះ និងបឹងជាដើម លោកក៏សង្គ្រោះយកដោយមាតិកាថា

ស្រែ និងចំការនុ៎ះឯង ។

[៤៨៩] បទថា **ការទិញ និងការលក់ (កយវិក្កយា)** បានដល់ ទិញផង លក់ផង ។

[៤៩០] ទូតកម្ម លោកហៅថា **ភាពជាទូត** ការទទួលសំបុត្រ ឬនាំដំណឹងរបស់ពួកគ្រហស្ថហើយទៅទីនោះៗ លោកហៅថា **ទទួលបម្រើ** ។ ធម្មតាថា ការទៅដោយជើងបន្តិចបន្តួចរបស់ភិក្ខុ ដែលគេបញ្ជូនទៅកាន់ផ្ទះតូចផ្ទះធំ (ឈ្មោះថាទទួលបម្រើ) ។ ការធ្វើទាំងពីរយ៉ាងនោះ ឈ្មោះថា **ការប្រកប** ព្រោះដូច្នោះ គប្បីជ្រាបខ្លឹមសារក្នុងបទនេះ យ៉ាងនេះថា ការប្រកបទូតកម្ម និងការទទួលបម្រើ ។

[៤៩១] ការឆបោក ឈ្មោះថា **អំពើកោង** ក្នុងពាក្យជាដើមថា **កោងដោយភ្នែកជញ្ជីង** ។ ក្នុងពាក្យថាកោងនោះ **អំពើកោងដោយភ្នែកជញ្ជីង** មាន ៤ យ៉ាង គឺ ការកោងដោយរូប ការកោងដោយភាជនៈ ការកោងដោយទទួល ការកោងដោយបិទបាំង ។ បណ្តាការកោងទាំងនោះ បុគ្គលធ្វើភ្នែកជញ្ជីងពីរឲ្យដូចគ្នា កាលទទួល (កាលទិញ) រមែងកាន់យកដោយភ្នែកជញ្ជីងធំ កាលនឹងឲ្យ (លក់) ក៏ឲ្យដោយភ្នែកជញ្ជីងតូច នេះឈ្មោះថា **កោងដោយរូប** ។ កាលនឹងទទួល ក៏យកដៃសង្កត់ភ្នែកជញ្ជីងខាងក្រោយ

កាលនឹងឲ្យ ក៏យកដៃសង្កត់ខាងមុខ នេះឈ្មោះថា **កោងដោយភាជនៈ** ។ កាលនឹងទទួល ក៏ទាញខ្សែត្រង់គល់ កាលនឹងឲ្យ ក៏ទាញខ្សែខាងចុង នេះឈ្មោះថា **កោងដោយការទទួល** ។ ធ្វើក្អែកជញ្ជីងឲ្យប្រហោងក្នុង ហើយដាក់កម្ទេចដែកខាងក្នុង កាលនឹងទទួល ក៏ធ្វើជងជញ្ជីងនោះឲ្យបះខាងក្រោយ កាលនឹងឲ្យ ក៏ធ្វើជងជញ្ជីងឲ្យបះខាងមុខ នេះឈ្មោះថា **កោងដោយការបិទបាំង** ។

ថាសមាស លោកហៅថា **ភាជនៈ** ការបញ្ឆោតបន្លំដោយថាសមាសណា នោះឈ្មោះថា **ការកោងដោយភាជនៈ** ។ ដូចម្តេច? គឺ ធ្វើថាសមាសមួយហើយ ធ្វើថាសលោហៈដទៃ ២-៣ ឲ្យពណ៌ដូចមាស ។ បន្ទាប់ពីនោះ ទើបទៅជនបទ ហើយចូលទៅរកត្រកូលដែលមង្គលណាៗ នោះឯង ពោលថា ពួកលោកចូរកាន់យកថាសមាសចុះ កាលពួកគេសាកសួរដល់តម្លៃ ក៏ធ្វើដូចឲ្យថាសដែលមានតម្លៃច្រើនជាង លំដាប់នោះ កាលពួកគេពោលថា នឹងដឹងថា ថាសទាំងនេះជាមាសបានយ៉ាងណា ទើបពោលថា ចូររើសយកចុះ ហើយក៏ពណ៌ថាសមាសចុះត្រង់ថ្ម ឲ្យថាសទាំងអស់ហើយទៅ ។

ការកោងដោយគ្រឿងវាល់ មាន ៣ ប្រភេទ ដោយអំណាចប្រភេទនៃហទយៈ ប្រភេទនៃកំពូល និងប្រភេទនៃខ្សែ ។ ក្នុងការកោងទាំងនោះ

ប្រភេទនៃហទយៈ (គ្រឿងសម្រាប់វាល់វត្ថុរាវ) រមែងបានក្នុងវេលាវាល់ទឹកដោះថ្លា និងប្រេងជាដើម (ពេលទិញចូល) ក៏កាលនឹងកាន់វត្ថុទាំងនោះ ក៏ពោលថា ចូរចាក់តិចៗ ព្រោះគ្រឿងវាល់មានរន្ធខាងក្រោម ហើយឲ្យហូរចូលទៅក្នុងភាជនៈយ៉ាងច្រើន ទើបកាន់យក កាលនឹងឲ្យ (ពេលលក់) ក៏បិទរន្ធ ហើយឲ្យពេញយ៉ាងរហ័ស ទើបលក់ ។ **ប្រភេទនៃកំពូល** រមែងបានក្នុងវេលាវាល់ល្ង និងអង្ករជាដើម ក៏កាលនឹងដល់ទទួលយកល្ង និងអង្ករជាដើមទាំងនោះ ចូកយកសន្សឹមៗ ពូនឲ្យខ្ពស់ជាកំពូលទើបកាន់យក កាលនឹងលក់ ក៏ប្រញាប់កៀសកំពូលចេញទើបឲ្យ ។ **ប្រភេទនៃខ្សែ** រមែងបានក្នុងវេលាវាស់ស្រែ និងចំការ ។ ក៏កាលមិនបានវត្ថុជាសំណូកអ្វីៗ ស្រែដែលមិនធំ ក៏វាស់ឲ្យធំ ។

[៨៩២] ការធ្វើម្ចាស់របស់ មិនឲ្យជាម្ចាស់របស់ ព្រោះទទួលសំណូក ឈ្មោះថា **ការទទួលសំណូក** ។ ក្នុងហេតុទទួកសំណូកជាដើម ការឆបោកបុគ្គល ពួកដទៃដោយឧបាយទាំងនោះ ឈ្មោះថា **ការឆបោក** ។ ក្នុងសេចក្តីនេះ មានរឿងជាឧទាហរណ៍ ។

បានឮថា នាយព្រានម្នាក់ ចាប់ម្រឹគ និងកូនម្រឹគបានមក ។ អ្នកលេងម្នាក់ពោលនឹងគេថា អ្នកដ៏ចម្រើន ម្រឹគថ្លៃប៉ុន្មាន កូនម្រឹគថ្លៃប៉ុន្មាន

កាលព្រានពោលថា ម្រឹគ ២ កហាបណៈ កូនម្រឹគ ១ កហាបណៈ ទើបឲ្យប្រាក់មួយកហាបណៈ កាន់យកកូនម្រឹគទៅ ហើយត្រឡប់មកពោលថា អ្នកដ៏ចម្រើន ខ្ញុំមិនត្រូវការកូនម្រឹគទេ លោកចូរឲ្យមេម្រឹគដល់ខ្ញុំ ។

ព្រានពោលថា បើដូច្នោះ លោកចូរឲ្យ ២ កហាបណៈ ។

អ្នកលេង : សំឡាញ់ គ្រាមុន ខ្ញុំឲ្យមួយកហាបណៈហើយ មិនមែនឬ ។

ព្រាន : អើ ឲ្យហើយ ។

អ្នកលេង : អ្នកចូរយកកូនម្រឹគនេះ នោះជា ១ កហាបណៈ ដូច្នេះនិងកូនម្រឹគ មានតម្លៃ ១ កហាបណៈ រួមទាំងអស់ជា ២ កហាបណៈ ។

នាយព្រាននោះកំណត់ហើយថា គេពោលមានហេតុ ទើបបានទទួលយកកូនម្រឹគ ហើយឲ្យមេម្រឹគនោះទៅ ។

ការធ្វើវត្ថុដែលមិនមែនសង្វារ ថាជាសង្វារ មិនមែនកែវមណី ថាជាកែវមណី មិនមែនមាស ថាជាមាស ហើយបញ្ឆោតបន្លំដោយរបស់ក្លែងក្លាយ ដោយអំណាចការប្រកប ឬដោយអំណាចមាយា ឈ្មោះថា **ការកោង** ។ ការប្រកបការកោង ឈ្មោះថា **បួម** ពាក្យថា បួមនេះ ជាឈ្មោះនៃការទទួលសំណូកជាដើម ទាំងនោះឯង ។ ព្រោះដូច្នោះ គប្បីជ្រាប

ខ្លឹមសារក្នុងបទនេះ យ៉ាងនេះថា បន្ទាប់ពីការទទួលសំណូក ពីការលលួង ចាកការធ្វើបរស់បួមនុ៎ះឯង ។ អាចារ្យពួកខ្លះសម្តែងហេតុដទៃហើយ រមែង ពោលថា ការផ្លាស់ប្តូរដល់អ្នកដទៃ ឈ្មោះថា បួម ។ ក៏ពាក្យនោះ លោក សង្គ្រោះយកការឆបោកនុ៎ះឯង ។

[៤៩៣] ការកាត់ដៃជាដើម ឈ្មោះថា **ការកាត់** ក្នុងហេតុ មានការ កាត់ជាដើម ។ ការឲ្យស្លាប់ឈ្មោះថា **ការសម្លាប់** ។ ការចងដោយគ្រឿង ចង គឺ ខ្សែជាដើម ឈ្មោះថា **ការចង** ។

ឈ្មោះថា **ការវាយដណ្តើម** (យកទ្រព្យ) មាន ២ យ៉ាង គឺ ការ វាយដណ្តើមក្នុងវេលាទឹកកកធ្លាក់ ១ ការវាយដណ្តើមព្រោះការបិទបាំងដោយ ជន្ទត់ឈើ ១ ។ វេលាទឹកកកធ្លាក់ ចោរទាំងឡាយបិទបាំងដោយទឹកកក ហើយវាយកញ្ឆក់អ្នកដែលវង្វេងផ្លូវ នេះឈ្មោះថា ការវាយដណ្តើមក្នុង វេលាទឹកកកធ្លាក់ ។ ចោរទាំងឡាយបិទបាំងដោយជន្ទត់ឈើជាដើម ហើយ វាយកញ្ឆក់ នេះឈ្មោះថា ការវាយដណ្តើមព្រោះការបិទបាំងដោយជន្ទត់ ឈើ ។ ការប្លន់ពួកស្រុក និងនិគមជាដើម លោកហៅ **ការប្លន់** ។ ការ ធ្វើដ៏យ៉ាងសាហាវ គឺ ការចូលទៅក្នុងស្រុកហើយ ផ្ទង់កាំបិតត្រង់ករបស់ មនុស្សទាំងឡាយ ហើយកាន់យកវត្ថុដែលខ្លួនប្រាថ្នា ឈ្មោះថា **ការសម្លុត**

កំហែង ។ វៀរចាកការកាត់ ការសម្លាប់ ការចង វាយដណ្តើម ការប្លន់ និងការសម្លុតកំហែងនោះ យ៉ាងនេះឯង ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្តីងាយយល់ទាំងអស់នោះឯង ។

ចប់អធិប្បាយសេចក្តីក្នុងអាមកធញ្ញបេយ្យាវគ្គ

# និគមកថា

ក៏ដោយពាក្យប្រមាណប៉ុណ្ណេះ អដ្ឋកថា ឈ្មោះថា **សារត្ថប្បកាសិនី** ណាដែលល្អិតល្អន់ ដែលខ្ញុំបំណងនូវការតាំងនៅនៃព្រះសទ្ធម្ម ប្រារព្ធដើម្បីធ្វើការពណ៌នា ខ្លឹមសារនៃសំយុត្តនិកាយ ដែលមានឧបការៈច្រើនដល់វិបស្សនា មារយាទ និងបញ្ញាជាគ្រឿងត្រាស់ដឹងរបស់បុគ្គលសម្រួមទាំងឡាយ ។ ក៏អដ្ឋកថា សារត្ថប្បកាសិនីនេះ ខ្ញុំកាន់យកសារៈពីមហាអដ្ឋកថា រចនាចប់ហើយ ដោយភាណវារៈ ដោយបាលីប្រមាណ ៧៨ គាថា ។ សូម្បីបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ មានប្រមាណ ៥៩ ភាណវារៈ ខ្ញុំក៏រចនាទុកហើយ ដើម្បីត្រូវការប្រកាសខ្លឹមសារនៃសេចក្តីទាំងឡាយ ។ ព្រោះដូច្នោះ អដ្ឋកថានេះ និងបករណ៍វិសេសវិសុទ្ធិមគ្គនោះ ដោយរាប់តាមភាណវារៈ ជា ១៣៧ ។ ដោយបុណ្យ ដែលខ្ញុំជាអ្នកកាន់សារៈនៃមូលត្ថកថារបស់ព្រះថេរៈទាំងឡាយអ្នកអាស្រ័យមហាវិហារ រចនាអដ្ឋកថានេះ មានប្រមាណ ១៣៧ ដោយភាណវារៈ ដែលប្រកាសលទ្ធិហើយយ៉ាងនេះ សន្សំហើយ សូមមនុស្សលោកទាំងពួង ចូរមានសុខចុះ ។ ដោយបុណ្យនោះ ដែលព្រះថេរៈ ឈ្មោះថា **ភទន្តជោតិបាល** អ្នកមានសីលបរិសុទ្ធ អ្នកមាន

ញាណដែលប្រាកដហើយ ជាអ្នកប្រាថ្នាសេចក្តីរុងរឿងនៃព្រះសាសនា អ្នកមានគុណដ៏ល្អស្អាត អារាធនាខ្ញុំហើយ ដើម្បីរចនាអដ្ឋកថានៃសុភាសិតវារស្រេចហើយ សូមសាធុជនចូរមានសេចក្តីសុខចុះ ។

អដ្ឋកថាសំយុត្តនិកាយ ដែលឈ្មោះថា **សារត្ថប្បកាសិនី** ព្រះថេរៈដែលគ្រូទាំងឡាយស្គាល់នាមថា **ពុទ្ធឃោសៈ** អ្នកប្រដាប់ដោយសេចក្តីបរិសុទ្ធ សទ្ធា បញ្ញា និងសេចក្តីព្យាយាមយ៉ាងក្រៃលែង អ្នកមានគុណសមុទ័យ មានសីល មារយាទ សេចក្តីស្មោះត្រង់ និងសេចក្តីទន់ភ្លន់ជាដើម ដែលខ្លួនឲ្យកើតឡើងហើយ អ្នកអាចឈានចុះកាន់លទ្ធិរបស់ខ្លួន និងអ្នកដទៃបាន ជាអ្នកប្រកបដោយបញ្ញា និងភាពឈ្លាសវៃ ជាអ្នកវេយ្យាករណ៍ធំ ដោយភាពជាអ្នកមានបញ្ញាមិនទើសទាក់ក្នុងសាសនារបស់ព្រះសាស្តា មានបរិយត្តិ គឺ ព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា អ្នកប្រកបដោយពាក្យសម្តីរៀបរយ ពោលពីរោះ បន្លឺឡើងបានសប្បាយ ឲ្យកើតករណសម្បត្តិ អ្នកមានប្រក្រតីពោលពាក្យដែលគួរ និងរួចផុត អ្នកមានវាទៈដ៏ប្រសើរ ជាមហាកវី ជាអ្នកប្រដាប់វង្សនៃព្រថេរៈទាំងឡាយដែលអាស្រ័យក្នុងមហាវិហារ អ្នកមានប្រាជ្ញាតាំងមាំល្អហើយក្នុងឧត្តរិមនុស្សធម៌ដ៏ប្រសើរ ដោយគុណ មានអភិញ្ញា ៦ ជាដើម មានបដិសម្ភិទាបែកធ្លាយហើយជាបរិវារ

លោកជាប្រទីបនៃវង្សព្រះថេរៈ ជាអ្នកប្រាជ្ញដ៏ធំ និងបរិសុទ្ធ រចនាហើយ ។

សូម្បីព្រះនាមថា ពុទ្ធៈ ដូច្នេះ របស់ព្រះមានព្រះភាគ
អ្នកមានហឫទ័យបរិសុទ្ធ អ្នកមុតមាំ ជាអ្នកចម្រើន
បំផុតក្នុងលោក អ្នកស្វែងរកប្រយោជន៍ដ៏ធំ នៅប្រព្រឹត្ត
ទៅក្នុងលោកដ៏ពេលណា សូមអដ្ឋកថាឈ្មោះថា សារត្ថ-
ប្បកាសិនីនេះ ដែលសម្តែងន័យហើយ ដើម្បីសេចក្តី
បរិសុទ្ធនៃសីល ដល់កុលបុត្តទាំងឡាយអ្នកស្វែងរក
គុណជាគ្រឿងរលាស់ចេញចាកលោក ចូរតាំងនៅក្នុង
លោកដ៏ពេលនោះ ចុះ ។

## ចប់អដ្ឋកថាសំយុត្តនិកាយ ឈ្មោះសារត្ថប្បកាសិនី

## និង

## ចប់អដ្ឋកថា មហាវារវគ្គ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 1.000 US |
| ភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ<br>នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក | $ 300 US |
| -ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 US |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង<br>ព្រមទាំងបុត្ត និងចៅ | $ 70 US |
| -ឧបាសក វ៉ាន់ ស៊ីមវ៉ា ឧបាសិកា តាំង សានីតា<br>ព្រមទាំងបុត្ត | $ 30 US |
| -កុមារី តាំង សុមាវតី | $ 10 US |